សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

**Université Royale de Droit et des Sciences Economiques**

**Royal University of Law and Economics**

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **គង់ សោភា**

សាស្ត្រាចារ្យណែនាំ

លោក **នឹង ស៊ុំនៀង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២

ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **គង់ សោភា** ជានិស្សិតថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជំនាន់ទី១៦ នៃ ***សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច*** ។

## សូមលំអោនកាយសម្តែងនូវកត្តញ្ញូតាធម៌យ៉ាងជ្រាលជ្រៅបំផុតចំពោះ

លោកឪពុក **ម៉ុន គង់** និងអ្នកម្តាយ **អានចន្ធា** ដែលលោកអ្នកមានគុណទាំងពីរបានផ្តល់កំណើត និងបានចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងការរស់នៅប្រចាំថ្ងៃទាំងសម្លៀកបំពាក់ ប្រាក់កាស ចំណីអាហារចំពោះនាងខ្ញុំជាកូន និងបានផ្តល់នូវការទូន្មានប្រៀនប្រដៅជាមួយនឹងដំបូន្មានល្អៗ ប្រកបដោយព្រហ្មវិហារធម៌តាំងពីកូនតូចរហូតដល់ធំដឹងក្តី។ លោកទាំងពីរខិតខំព្យាយាមធ្វើការងាររកកម្រៃយ៉ាងលំបាក មិនថាឆ្លងកាត់នូវឧបសគ្គធំប៉ុណ្ណាក៏លោកទាំងពីរមិនដែលរុញរាឡើយ លោកទាំងពីរតស៊ូជំនះដើម្បីឱ្យកូនៗបានល្អ។ បើគ្មានលោកទាំងពីរទេយើងខ្ញុំក៏គ្មានថ្ងៃនេះដែរ។

នាងខ្ញុំក៏សូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះបងប្រុស បងស្រី និងម្តាយមីងរបស់នាងខ្ញុំ ដែលពួកគាត់បានជួយជ្រោមជ្រែងផ្តល់ជាកម្លាំងចិត្ត ផ្តល់ជាថវិការ និងផ្តល់ជាទីស្នាក់អាស្រ័យដល់នាងខ្ញុំឱ្យបានមករៀនបន្តនៅសាកលវិទ្យាល័យ ប្រសិនបើគ្មានអ្នកទាំងអស់គ្នាទេនោះ នាងខ្ញុំក៏មិនអាចបានបន្ត ការសិក្សាមកដល់ពេលនេះបានដែរ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះថ្នាក់ដឹកនាំកម្ពុជា ដែលលោកបានដឹកនាំប្រទេសប្រកបដោយសុខសន្តិភាព ហើយព្រមទាំងជួយលើកស្ទួយវិស័យអប់រំឱ្យមានភាពល្អប្រសើរ ប្រសិនបើប្រទេសគ្មានសន្តិភាពនាងខ្ញុំក៏មិនបានសិក្សាមកដល់ថ្ងៃនេះដែរ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ឯកឧត្តមសាកលវិទ្យាធិការ និងលោកគ្រូអ្នកគ្រូសាស្ត្រាចារ្យទាំងអស់ដែលលោកបានខិតខំបង្ហាត់បង្រៀនដល់នាងខ្ញុំក៏ដូចជា និស្សិតគ្រប់គ្នាអស់ពីកម្លាំងកាយកម្លាំងចិត្ត ព្រមទាំងអប់រំទូន្មាន ប្រៀនប្រដៅ ដល់រូបនាងខ្ញុំឱ្យក្លាយខ្លួនទៅជាពលរដ្ឋល្អនៅក្នុងសង្គម ប្រសិនបើគ្មានអ្នកទាំងអស់គ្នាទេនាងខ្ញុំក៏គ្មានថ្ងៃនេះដែរ។

នាងខ្ញុំសូមគោរព និងថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុត ចំពោះលោកគ្រូសាស្ត្រាចារ្យ **ងីង ស៊ីន្មៀង** ដែលលោកបានលះបង់កម្លាំងកាយចិត្ត ព្រមទាំងពេលវេលាដ៏មានតម្លៃរបស់លោកជួយបង្ហាត់បង្រៀន ផ្តល់ដំបូន្មានល្អៗ ដើម្បីឱ្យនាងខ្ញុំក្លាយទៅជាសិស្សល្អ ពលរដ្ឋល្អ តាំងពីឆ្នាំទី២ រហូតដល់ពេលនេះ និងធ្វើការណែនាំសារណាមួយនេះតាំងពីដើមរហូតដល់ចប់ ។

នាងខ្ញុំជាកូន និងជាសិស្សចងចាំជានិច្ចនៅក្នុងក្រអៅបេះដូង នូវមហាគុណទាំងអស់នេះ នាងខ្ញុំនឹងតបស្នងសងគុណចំពោះអ្នកមានគុណទាំងពីរ គឺលោកឪពុក អ្នកម្តាយ និងសាស្ត្រាចារ្យ ដោយក្តីគោរព និងស្រឡាញ់ជាទីបំផុត។

ជាចុងបញ្ចប់ នាងខ្ញុំសូមប្រសិទ្ធិពរដល់លោកអ្នកមានគុណទាំងអស់ សូមឱ្យជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លាងឃ្លាតឡើយ។

# អារម្ភកថា

នាងខ្ញុំជានិស្សិតនៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ជំនាន់ទី ១៦ បានឆ្លងកាត់ការសិក្សាផ្នែកនីតិសាស្ត្រអស់រយៈពេល ៤ ឆ្នាំមកហើយ។ មិនថាឆ្លងកាត់ឧបសគ្គលំបាកយ៉ាងណា នាងខ្ញុំមិនព្រមបោះបង់ការសិក្សាចោលនោះឡើយ ព្រោះនាងខ្ញុំយល់ថា ការសិក្សា គឺពិតជាសំខាន់ខ្លាំងណាស់ដល់មនុស្សគ្រប់ៗរូបនាពេលបច្ចុប្បន្ននេះ។ ជាការពិតណាស់ កាលណា យើងមានចំណេះដឹង គឺយើងអាចធ្វើអ្វីៗបានដោយងាយស្រួល ហើយជាពិសេសយើងអាចស្វែងរកការងារបានសមរម្យ មានជីវភាពធូរធារ អាចជួយក្រុមគ្រួសារ ក៏ដូចជាជួយដល់សង្គមជាតិទាំងមូលផងដែរ។ យ៉ាងណាមិញ មកដល់ពេលនេះនាងខ្ញុំបានខិតខំអស់ពីកម្លាំងកាយចិត្ត ដើម្បីស្វែងរកចំណេះដឹង ហើយនាងខ្ញុំក៏បាន និងកំពុងធ្វើការស្រាវជ្រាវសរសេរសារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រនៅឆ្នាំ២០១៦នេះ។ នាងខ្ញុំមានមោទនភាពយ៉ាងខ្លាំងបំផុត ដែលនាងខ្ញុំអាចមានថ្ងៃនេះ ដែលទីបំផុតនាងខ្ញុំអាចទទួលបាននូវលទ្ធផលល្អប្រសើរពីការសិក្សា។

ជាមួយគ្នានេះដែរ ក្នុងចំណោមមុខវិជ្ជាជាច្រើន ដែលនាងខ្ញុំធ្លាប់បានសិក្សាកន្លងមក មុខវិជ្ជាដែលនាងខ្ញុំយកមកសរសេរនោះ គឺទាក់ទងនឹងនីតិវិធីព្រហ្មទណ្ឌ។ នាងខ្ញុំបានជ្រើសរើសយកប្រធានបទមួយគឺ *"នីតិវិធីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ"* មកធ្វើការសិក្សាស្រាវជ្រាវ ។

មូលហេតុ ដែលនាងខ្ញុំសម្រេចជ្រើសរើសយកប្រធានបទមួយនេះមកសិក្សាស្រាវជ្រាវ និងចងក្រងឡើង ព្រោះនាងខ្ញុំចង់ឱ្យនិស្សិតជំនាន់ក្រោយបានយល់ច្បាស់អំពីចំណុចមួយចំនួន ដែលមាននៅក្នុងនីតិវិធីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ និងដើម្បីទុកជាឯកសារមួយសម្រាប់បំពេញនូវតម្រូវការរបស់សិស្សប្អូនជំនាន់ក្រោយៗ ដែលមានបំណងចង់ស្រាវជ្រាវបន្តទៅលើអ្វី ដែលទាក់ទងនឹងប្រធានបទនេះ។ ម្យ៉ាងទៀត អ្វីដែលសំខាន់នោះ គឺនាងខ្ញុំផ្ទាល់មានចំណាប់អារម្មណ៍ទៅលើប្រធានបទនេះ ផងដែរ។ ទន្ទឹមនឹងនេះ នាងខ្ញុំជឿជាក់ថា នៅក្នុងការសរសេរសារណារបស់នាងខ្ញុំនេះ គឺច្បាស់ជានៅមានភាពខ្វះចន្លោះចៀសមិនរួចឡើយ ទាំងខ្លឹមសារ ក៏ដូចជាកំហុសអក្ខរាវិរុទ្ធ។ ដូច្នេះហើយ រាល់កំហុសឆ្គងដែលបានកើតឡើងនេះ នាងខ្ញុំសូមអភ័យទោសទុកជាមុនពីសំណាក់គណៈកម្មការ សាស្ត្រាចារ្យ អស់លោក លោកស្រី និងមិត្តអ្នកអានគ្រប់មជ្ឈដ្ឋានទាំងអស់។ នាងខ្ញុំសង្ឃឹមថានឹងទទួលបាននូវការអភ័យទោសពីសំណាក់អ្នកទាំងអស់គ្នា។

នាងខ្ញុំសូមស្វាគមន៍ទទួលនូវការរិះគន់ ដើម្បីស្ថាបនាពី លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ អស់លោក លោកស្រី និងមិត្តអ្នកអានគ្រប់ពេលវេលា។

ជាចុងបញ្ចប់ នាងខ្ញុំសូមគោរពជូនពរដល់ លោកគ្រូ អ្នកគ្រូដែលជាគណៈកម្មការ លោកគ្រូសាស្ត្រាចារ្យណែនាំ អស់លោក លោកស្រី និងមិត្តអ្នកអានទាំងអស់ជួបតែសំណាងល្អ ទទួលបាននូវភាពជោគជ័យគ្រប់ភារកិច្ច ព្រមទាំងជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# ឯកសារយោង

- រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣
- ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- កតិកាសញ្ញាជាសាកលស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយរបស់អង្គការសហប្រជាជាតិ ឆ្នាំ១៩៦៦
- សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨
- សៀវភៅនីតិវិធីព្រហ្មទណ្ឌរបស់លោកសាស្ត្រាចារ្យ អៀង សំណាង បោះពុម្ព ឆ្នាំ២០១៥
- ឯកសារបានមកពីការផ្សព្វផ្សាយច្បាប់ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ រៀបចំឡើងដោយក្រសួងយុត្តិធម៌ សហការជាមួយទូរទស្សន៍ជាតិកម្ពុជា (ទទក) ។
- ប្រភេទដីកាមួយចំនួនរបស់អយ្យការ និងចៅក្រមស៊ើបសួរ ដែលយកមកប្រើប្រាស់នៅក្នុងនីតិវិធីនៃការស៊ើបអង្កេតនៅសាលាដំបូង ។

# វាក្យស័ព្ទគតិយុត្ត

**-ការស៊ើបអង្កេត** គឺជាការស្រាវជ្រាវប្រមូលភស្តុតាង ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ និងព្រះរាជអាជ្ញា។ ការស៊ើបអង្កេតនេះ ត្រូវបានចែកចេញជាការស៊ើបអង្កេតជាក់ស្តែង និងការស៊ើបអង្កេតបឋម។

**-ការស៊ើបអង្កេតជាក់ស្តែង** គឺជាការស្រាវជ្រាវប្រមូលភស្តុតាង ដែលធ្វើឡើងនៅពេលមានបទល្មើសជាក់ស្តែង (បទល្មើសដែលកំពុងប្រព្រឹត្ត ឬទើបនឹងប្រព្រឹត្តរួចភ្លាម)។

**-ការស៊ើបអង្កេតបឋម** គឺជាការស្រាវជ្រាវប្រមូលភស្តុតាង ដែលធ្វើឡើងនៅពេលមានបទល្មើសមិនជាក់ស្តែង។

**-ការស៊ើបសួរ** គឺជាការស្រាវជ្រាវប្រមូលភស្តុតាង ដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ ដោយមានគោលបំណងស្វែងរកភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុកទៅលើជនត្រូវចោទ ដែលមានទិសដៅស្វែងរកឱ្យឃើញការពិតនៃរឿង។

**-ជនល្មើស** គឺជាជនដែលប្រព្រឹត្តអំពើណាមួយល្មើសនឹងច្បាប់។ ជនល្មើស ជាជនដែលប្រព្រឹត្តបទល្មើសជាក់ស្តែង។

**-ជនសង្ស័យ** គឺជាជនដែលត្រូវបានគេសង្ស័យថា បានប្រព្រឹត្តបទល្មើសដោយផ្ទាល់ ឬបានចូលរួមប្រព្រឹត្តបទល្មើស។ ពាក្យនេះ ត្រូវបានប្រើនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬព្រះរាជអាជ្ញាខណៈពេលដែលមិនទាន់មានការចោទប្រកាន់របស់ព្រះរាជអាជ្ញា។

**- ជនជាប់ចោទ** គឺជាជនដែលត្រូវបានព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់ថា បានប្រព្រឹត្តបទល្មើសតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដើម្បីផ្តល់សិទ្ធិ អំណាចឱ្យទៅចៅក្រមស៊ើបសួរ បើកការស៊ើបសួរ ដើម្បីស្វែងរកឱ្យឃើញនូវការពិត។

**-ជនត្រូវចោទ** គឺជាជនដែលត្រូវបានព្រះរាជអាជ្ញា ធ្វើការចោទប្រកាន់នៅចំពោះមុខតុលាការព្រហ្មទណ្ឌ។ មានន័យថាជាជនដែលត្រូវបានព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ពីបទល្មើសណាមួយនៅចំពោះមុខអង្គជំនុំជម្រះក្នុងពេលបើកសវនាការជំនុំជម្រះ។

**-ពិរុទ្ធជន** គឺជាជនដែលត្រូវបានតុលាការព្រហ្មទណ្ឌ ប្រកាសថាមានទោស តែសាលក្រមដែលតុលាការបានចេញនោះមិនទាន់ចូលជាស្ថាពរ។

**-ទណ្ឌិត** គឺជាជនដែលត្រូវបានតុលាការព្រហ្មទណ្ឌ ប្រកាសថាមានទោស ហើយសាលក្រមនោះបានចូលជាស្ថាពរ។

# បញ្ជីឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១
## កំណត់ហេតុរបស់នគរបាលយុត្តិធម៌ និងដីការបស់អយ្យការ

- ពាក្យបណ្ដឹង
- កំណត់ហេតុបណ្ដឹង
- លិខិតកោះហៅ
- កំណត់ហេតុសួរចម្លើយ
- កំណត់ហេតុស្ដាប់ចម្លើយ
- កំណត់ហេតុការស្ដាប់បំភ្លឺ
- កំណត់ហេតុការស្ដាប់បំភ្លឺរបស់កសិណសាក្សី
- របាយការណ៍
- របាយការណ៍សំយោគ
- សំណើសុំដីកាបញ្ជាឱ្យចូលខ្លួន
- កំណត់ហេតុទទួលវត្ថុតាង
- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ

## ឧបសម្ព័ន្ធទី២
## កំណត់ហេតុ និងដីកាគម្រូរបស់អយ្យការ

- ដីកាបញ្ជាឱ្យចូលខ្លួន
- ដីកាតម្កល់រឿងទុកឥតចាត់ការ
- កំណត់ហេតុស្ដីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួន
- ដីកាសម្រេចបញ្ចូលសំណុំរឿងព្រហ្មទណ្ឌ
- ដីកាសម្រេចបំបែកសំណុំរឿង
- ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់
- ដីកាឆែកឆេរលំនៅឋាន
- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ
- ដីកាសន្និដ្ឋានសុំឱ្យឃុំខ្លួនបណ្ដោះអាសន្ន
- កំណត់ហេតុទទួលវត្ថុតាង
- ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម
- ដីកាសន្និដ្ឋានស្ថាពរ

## ឧបសម្ព័ន្ធទី៣
## កំណត់ហេតុ និងដីកាគម្រូរបស់ចៅក្រមស៊ើបសួរ

- កំណត់ហេតុស្ដីពីការបង្ហាញខ្លួនលើកដំបូង
- កំណត់ហេតុស្ដីពីការពិភាក្សាដេញដោលចំពោះមុខ
- កំណត់ហេតុស្ដីពីការសួរចម្លើយជនត្រូវចោទ
- ដីកាសម្រេចឱ្យឃុំខ្លួនបណ្ដោះអាសន្ន
- ដីកាបង្គាប់ឱ្យឃុំខ្លួន
- ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន
- លិខិតជូនដំណឹង ឬជូនពត៌មានដល់តំណាងអយ្យការ
- ដីកាកោះ
- ដីកាចាត់ឱ្យស៊ើបសួរជំនួស
- ដីកាបញ្ជូន
- កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី
- កំណត់ហេតុស្ដីពីការស្ដាប់ចម្លើយសាក្សី
- កំណត់ហេតុស្ដីពីការសួរចម្លើយតទល់
- ដីកាទទួលស្គាល់មេធាវី ឬអ្នកការពារ
- ដីកាបង្គាប់ឱ្យចូលខ្លួន
- ដីកាបង្គាប់ឱ្យនាំខ្លួន
- ដីកាបង្គាប់ឱ្យចាប់ខ្លួន
- ដីកាបញ្ជូនឱ្យឆ្លើយ
- ដីកាបញ្ជូនសំណុំរឿងឱ្យពិនិត្យ
- ដីកាសម្រេចលើកលែងការចោទប្រកាន់
- ដីកាសម្រេចរក្សាជនត្រូវចោទក្នុងឃុំជាបណ្ដោះអាសន្ន
- ដីកាបញ្ជូនរឿងទៅជំនុំជម្រះ
- បញ្ជីរាយនាមអ្នកជាប់ទាក់ទិន

# សេចក្តីផ្តើម

ប្រទេសកម្ពុជាធ្លាប់បានឆ្លងកាត់នូវសង្គ្រាមរ៉ាំរ៉ៃជាច្រើនលើកច្រើនសារ ជាពិសេស គឺនៅសម័យកម្ពុជាប្រជាធិបតេយ្យ (ប៉ុលពត) អស់រយៈពេល ៣ឆ្នាំ ៥ខែ ២០ថ្ងៃ ប្រជាជនរងទុក្ខវេទនាទាំងផ្លូវកាយ ទាំងផ្លូវចិត្ត ដោយសារមានការបង្ខិតបង្ខំឱ្យធ្វើការហួសកម្លាំង ហូបចុកមិនគ្រប់គ្រាន់ គ្មានសិទ្ធិសេរីភាពពេញលេញ។ មិនតែប៉ុណ្ណោះ នៅក្នុងសម័យនោះ ប្រជាជនជាច្រើនលាននាក់ត្រូវបានស្លាប់បាត់បង់ជីវិត ព្រាត់ប្រាស់គ្រួសារ និងបន្សល់ទុកនូវក្មេងកំព្រា ស្ត្រីមេម៉ាយ ជនពិការ ព្រមទាំង និស្សិត បញ្ញាវន្តត្រូវបានសម្លាប់ស្ទើរទាំងអស់ ចំណែកឯហេដ្ឋារចនាសម្ព័ន្ធត្រូវបានខ្ទេចខ្ទាំ វត្តអារាមស្ងាត់ជ្រងំ ទីក្រុងទាំងមូលក្លាយជាទីក្រុងគ្មានមនុស្សរស់នៅ ទាំងអស់នេះ គឺជាប្រវត្តិសាស្ត្រដ៏ឈឺចាប់ និងគួរឱ្យរន្ធត់យ៉ាងខ្លាំង។

ក្រោយថ្ងៃរំដោះ ៧មករា ឆ្នាំ១៩៧៩ ប្រទេសកម្ពុជាទទួលបានភាពល្អប្រសើររួចផុតពីការកាប់សម្លាប់ និងរួចផុតពីទារុណកម្មយ៉ាងឃោរឃៅ។ ប្រទេសកម្ពុជាចាប់ផ្តើមផ្លាស់ប្តូរបន្តិចម្តងៗរហូតដល់ មានការផ្លាស់ប្តូររបបនយោបាយ ដោយប្រកាន់យករបបប្រជាធិបតេយ្យសេរីពហុបក្ស និងបង្កើតឱ្យមានរបបរាជានិយមឡើងវិញ។

នាពេលបច្ចុប្បន្នប្រទេសកម្ពុជាគឺទទួលបាននូវភាពល្អប្រសើរឡើងវិញ មានភាពរីកចម្រើនស្ទើរគ្រប់វិស័យដោយផ្អែកលើឆន្ទៈដ៏មុះមុត ប្តូរផ្តាច់សាមគ្គីភាព និងឯភាពជាតិក្នុងការកសាងប្រទេសជាតិឱ្យមានការអភិវឌ្ឍ។ ទន្ទឹមនឹងនេះដែរ ប្រជាជនទាំងអស់មានសិទ្ធិសេរីភាពពេញលេញ មានច្បាប់ការពារមិនបណ្តោយឱ្យមានការកាប់សម្លាប់ ឬជិះជាន់សិទ្ធិគ្នាបានទេ។ បុគ្គលគ្រប់រូបគឺមានសិទ្ធិស្មើៗគ្នាចំពោះមុខច្បាប់ និងមានសិទ្ធិទទួលបាននូវយុត្តិធម៌គ្រប់ៗគ្នា។ច្បាប់បានកំណត់យ៉ាងច្បាស់ថា គ្មានបុគ្គលណាម្នាក់អាចប្រព្រឹត្តអំពើណាមួយធ្វើឱ្យប៉ះពាល់ដល់សិទ្ធិ សេរីភាពរបស់អ្នកដទៃ និងប៉ះពាល់ដល់សន្តិសុខសណ្តាប់ធ្នាប់សង្គមបានឡើយ។ ប្រសិនបើ មានបុគ្គលណាមួយប្រព្រឹត្តអំពើដែលច្បាប់ហាមឃាត់ បុគ្គលនោះនឹងត្រូវទទួលទណ្ឌកម្មទៅតាមប្រភេទ នៃអំពើរបស់ខ្លួន ដែលមានចែងនៅក្នុងច្បាប់។ ក៏ប៉ុន្តែ មិនមែនគ្រាន់តែដឹង ឬឮថាបុគ្គលនោះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌភ្លាមសមត្ថកិច្ចអាចចាប់យកបុគ្គលនោះទៅដាក់ទោសនោះទេ ព្រោះថាបុគ្គលគ្រប់រូបមានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ។

ជាធម្មតា កាលណាមានបទល្មើសមួយកើតឡើង ស្ថាប័នមានសមត្ថកិច្ចត្រូវចាប់ផ្តើមធ្វើការស៊ើបអង្កេតស្វែងរកបទល្មើសយ៉ាងម៉ត់ចត់ទៅតាមការកំណត់របស់ច្បាប់នីតិវិធីព្រហ្មទណ្ឌ។ ការស៊ើបអង្កេតនេះ គឺធ្វើឡើងក្នុងគោលបំណងស្វែងរកនូវការពិតនៃរឿង និងស្វែងរកអត្តសញ្ញាណរបស់ជនដែលត្រូវបានគេសង្ស័យថាបានប្រព្រឹត្តបទល្មើស។

នៅក្នុងដំណើរការ នៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ គឺជាដំណាក់កាលមួយដែលធ្វើឡើងដើម្បីបង្ហាញឱ្យច្បាស់លាស់ថាមានបទល្មើសកើតឡើងពិតមែន ឬក៏យ៉ាងណា ឬប្រសិនបើស្វែងរកឃើញថាមានបទល្មើសកើតមានហើយ គឺត្រូវស៊ើបអង្កេតឱ្យឃើញថានរណាជាជនបង្កពិតប្រាកដ និងជនណាដែលជាប់ពាក់ព័ន្ធនៅក្នុងរឿងនេះ។ ការធ្វើការស៊ើបអង្កេត គឺស្ថិតនៅក្នុងដំណាក់កាលមួយឈរនៅកណ្តាល គឺដើម្បីស្វែងរកការពិតជូនជនដែលជាប់សង្ស័យ ក៏ដូចជាជនរងគ្រោះ ឬជនដែលជាប់ពាក់ព័ន្ធផងដែរ។ ប្រសិនបើមានបុគ្គលណាមួយត្រូវបានគេសង្ស័យថាបានប្រព្រឹត្តបទល្មើស បុគ្គលនោះ គឺជាកម្មវត្ថុនៃការស៊ើបអង្កេតយ៉ាងម៉ត់ចត់ពីសំណាក់ស្ថាប័នមានសមត្ថកិច្ច ដើម្បីស្វែងរកភស្តុតាងថា បុគ្គលរូបនោះបានប្រព្រឹត្តបទល្មើសដូចដែលគេសង្ស័យដែរឬអត់។ យ៉ាងណាមិញ នីតិវិធីនៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌត្រូវបានឆ្លងកាត់ដំណាក់កាល ៣សំខាន់ៗដូចជា៖

- **ដំណាក់កាលស៊ើបអង្កេតរបស់នគរបាលយុត្តធម៌ (ជំពូកទី១)**
- **ដំណាក់កាលចំណាត់ការលើសំណុំរឿង (ជំពូកទី២) និង**
- **ដំណាក់កាល នៃការស៊ើបសួរ (ជំពូកទី៣) ។**

តើនគរបាលយុត្តិធម៌មានសិទ្ធិ អំណាច តួនាទី និងសមត្ថកិច្ចយ៉ាងដូចម្តេចខ្លះ ក្នុងការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ?

តើស្ថាប័នណា ដែលមានអំណាចក្នុងការធ្វើចំណាត់ការលើសំណុំរឿង? ការធ្វើចំណាត់ការលើសំណុំរឿងមានលក្ខណៈយ៉ាងណាខ្លះ?

តើនៅក្នុងដំណាក់កាលស៊ើបសួរត្រូវបានស៊ើបសួរដោយនរណា? ហើយការស៊ើបសួរត្រូវធ្វើឡើងយ៉ាងដូចម្តេច ដើម្បីឱ្យធានាបាននូវប្រសិទ្ធិភាពក្នុងការស៊ើបអង្កេត និងស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋ?

តើនៅក្នុងដំណាក់កាលនីមួយៗមានទំនាក់ទំនងគ្នាយ៉ាងដូចម្តេច?

ខាងក្រោមនេះ យើងនឹងបង្ហាញឱ្យបានដឹងពីសំណួរដែលបានចោទសួរ តាមរយៈប្រធានបទមួយស្តីអំពី នីតិវិធីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ដោយផ្អែកតាមច្បាប់ផ្សេងៗ ជាពិសេសក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ដែលមានដូចតទៅ៖

# ជំពូកទី១

# ដំណាក់កាលស៊ើបអង្កេតរបស់នគរបាលយុត្តិធម៌

នគរបាលយុត្តិធម៌ គឺជាជំនួយការរបស់អំណាចតុលាការ។ នគរបាលយុត្តិធម៌មានភារកិច្ច ធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុ ជាអ្នកកំណត់អត្តសញ្ញាណរបស់ ជនល្មើស ចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាងទៀតផង[1]។ នគរបាលយុត្តិធម៌ គឺជាជំនួយការរបស់ស្ថាប័នតុលាការ មានន័យថា នគរបាលយុត្តិធម៌ គឺជាជំនួយការរបស់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ នៅក្នុងការត្រួតពិនិត្យ បទឧក្រិដ្ឋ បទមជ្ឈិម បទលហុ កំណត់អត្តសញ្ញាណជនល្មើស និងតាមចាប់ជនល្មើស ព្រមទាំងប្រមូលភស្តុតាងផ្សេងៗ ដែលពាក់ព័ន្ធទៅនឹងបទល្មើសបញ្ជូនទៅព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ដើម្បីចាត់ការបន្តតាមនីតិវិធីច្បាប់។

តើសមាសភាពរបស់នគរបាលយុត្តិធម៌មានអ្វីខ្លះ?

## ១.១. សមាសភាពនគរបាលយុត្តិធម៌

សមាសភាពនគរបាលយុត្តិធម៌រួមមាន៖

១. មន្ត្រីនគរបាលយុត្តិធម៌

២. ភ្នាក់ងារនគរបាលយុត្តិធម៌

៣. មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យធ្វើការពិនិត្យបទល្មើសក្នុងរង្វង់សមត្ថកិច្ចរបស់ខ្លួន[2]។ ទាំងនេះ គឺជាសមាសភាពរបស់នគរបាលយុត្តិធម៌ ដែលត្រូវបានធ្វើការបែងចែកទៅតាមការកំណត់នៅក្នុងស្មារតី នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

### ១.១.១. មន្ត្រីនគរបាលយុត្តធម៌

មន្ត្រីនគរបាលយុត្តិធម៌ គឺជាអ្នកដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតនៅក្នុងបទល្មើសព្រហ្មទណ្ឌក្រោមការដឹកនាំរបស់ព្រះរាជអាជ្ញា។

តើមន្ត្រីដែលមានលក្ខណៈសម្បត្តិបែបណាខ្លះ ដែលមាននីតិសម្បទាគ្រប់គ្រាន់ ដើម្បីក្លាយជាមន្ត្រីនគរបាលយុត្តិធម៌?

#### ១.១.១.១. សម្បទាជាមន្ត្រីនគរបាលយុត្តិធម៌

សម្បទាជាមន្ត្រីនគរបាលយុត្តិធម៌គឺទទួលបានតាមរយៈការប្រលងយកសញ្ញាប័ត្រជាន់ខ្ពស់របស់នគរបាលយុត្តិធម៌ និងតាមរយៈឋានន្តរស័ក្តិ និងមុខងារ។

---

[1]-មាត្រា៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[2]-មាត្រា៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**ក. ការប្រលងយកសញ្ញាប័ត្រជាន់ខ្ពស់របស់នគរបាលយុត្តិធម៌**

សញ្ញាប័ត្រជាន់ខ្ពស់ នៃនគរបាលយុត្តិធម៌ត្រូវផ្តល់ជូន បន្ទាប់ពីឆ្លងកាត់ការប្រលងបែបវិជ្ជាជីវៈ ដែលរួមមានវិញ្ញាសារជាមូលដ្ឋានដូចខាងក្រោម៖

-វិញ្ញាសាស្តីពីនីតិព្រហ្មទណ្ឌ, នីតិវិធីព្រហ្មទណ្ឌនិង

-វិញ្ញាសាស្តីពីករណីកិច្ចសាស្ត្រដូចដែលមានចែងនៅក្នុងក្រមសីលធម៌ ដែលបានតាក់តែងដោយអង្គការសហប្រជាជាតិ។

សញ្ញាប័ត្រនេះត្រូវចុះហត្ថលេខារួមដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីដែលពាក់ព័ន្ធ និងមានបោះត្រាផងដែរ[3]។

ចំណែកឯគណៈមេប្រយោគ នៃការប្រលងស្ថិតក្រោមអធិបតីរបស់ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬចៅក្រមអយ្យការអមតុលាការកំពូលដែលទទួលមុខងារនេះ។

- ទាក់ទងនឹងមន្ត្រី នៃនគរបាលជាតិ គណៈមេប្រយោគមានសមាសភាពដូចតទៅ៖

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាង ២ (ពីរ) រូប របស់ក្រសួងមហាផ្ទៃ។

- ទាក់ទងនឹងយោធិន នៃកងរាជអាវុធហត្ថគណៈមេប្រយោគមានសមាសភាពដូចតទៅ៖

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាង ២ (ពីរ) រូបមកពីក្រសួងការពារជាតិ។

បែបបទនៃការចេញសញ្ញាប័ត្រ ត្រូវកំណត់ដោយប្រកាសរួមមួយរវាងរដ្ឋមន្ត្រីពាក់ព័ន្ធ[4]។

**ខ. ឋានន្តរស័ក្តិ និងមុខងារ**

មានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌គឺអ្នកដែលមានឋានន្តរស័ក្តិ និងមុខងារដូចខាងក្រោម៖

១. មន្ត្រីនគរបាលជាតិមានបន្តរសក្តិចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបម្រើការងារយ៉ាងតិចបំផុត ២ (ពីរ) ឆ្នាំក្នុងនគរបាលជាតិរួចហើយ បន្ទាប់ពីបានទទួលសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

[3]-មាត្រា៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[4]-មាត្រា៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

២. នាយទាហាននៃកងរាជអាវុធហត្ថ ដែលបានបម្រើការងារយ៉ាងតិចបំផុត ២ (ពីរ) ឆ្នាំ ក្នុងកងរាជអាវុធហត្ថរួចហើយបន្ទាប់ពីបានទទួលសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

៣. អ្នកមានបនន្ទុរស័ក្តិ និងមុខងារដូចខាងក្រោម៖

ក. អភិបាល និងអភិបាលរង ខេត្ត ក្រុង, អភិបាល និងអភិបាលរង ស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់។

ខ. ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសន្តិសុខ និងប្រធាន អនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

គ. ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតនៅក្រោមឱវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ។

ឃ. ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែកនៃ៖

-នាយកដ្ឋាននគរបាលព្រំដែន (ចំពោះបទល្មើសឆ្លងដែន)

-មន្ទីរប្រឆាំងគ្រឿងញៀន

-នាយកដ្ឋាននគរបាលទេសចរណ៍

-ស្នងការពិសេសការពារបេតិកភ័ណ្ឌ។

ង. ស្នងការ ស្នងការរងនគរបាលខេត្ត ក្រុង។

ច. ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត ក្រុងដូចជា៖

-ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតធ្ងន់ និងការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល។

-ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន។

-ការិយាល័យនគរបាលសេដ្ឋកិច្ច

-ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រព្រហ្មទណ្ឌ

-ការិយាល័យប្រឆាំងគ្រឿងញៀន

-ការិយាល័យប្រឆាំងភេរវកម្ម និង

-ការិយាល័យជនបរទេស។

ឆ. អធិការ និងអធិការរង ប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌនៃអធិការដ្ឋាននគរបាលស្រុក ខណ្ឌ។

ជ. ប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរ ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរ(ចំពោះបទល្មើសចរាចរ)។ ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ និងប្រធាន និងអនុប្រធានផ្នែក នៃការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ (ចំពោះបទល្មើសអាវុធជាតិផ្ទុះ)។ ប្រធាន និងអនុប្រធានអង្គភាព ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍ និងប្រធាន និងអនុប្រធានផ្នែកនៃការិយាល័យនគរបាលទេសចរណ៍។

ឈ. ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំសង្កាត់ (ចំពោះបទល្មើសព្រហ្មទណ្ឌ)។

ញ. មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ដ. មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំខេត្ត ក្រុង ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឋ. មេបញ្ជាការ និងមេបញ្ជាការរងកងរាជអាវុធហត្ថប្រចាំស្រុក ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឌ. ប្រធាន និងអនុប្រធានការិយាល័យ និងប្រធាន និងអនុប្រធានផ្នែកនៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

ឍ. ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ដែលត្រូវបានបង្កើតឡើងក្នុងករណីចាំបាច់។

រដ្ឋមន្ត្រីជាអណាព្យាបាលនៃមន្ត្រីនគរបាល ឬអាណាព្យាបាល នៃនាយទាហានកងរាជអាវុធហត្ថទាំងឡាយ ដែលមាននៅក្នុងចំណុចទី ១,២, និងទី៣ មានភារកិច្ចតែងតាំងមន្ត្រីនគរបាល និងនាយទាហានកងរាជអាវុធហត្ថទាំងឡាយ ដែលត្រូវបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមជាមួយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[5]។

[5]-មាត្រា៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**ឧទាហរណ៍:** បើមន្ត្រីខាងនគរបាលចេញពីកងរាជអាវុធហត្ថ ត្រូវមានប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងការពារជាតិ ជាមួយនឹងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ បើមន្ត្រីខាងនគរបាលចេញពីខាងក្រសួងមហាផ្ទៃ ត្រូវមានប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាមួយនឹងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

ទោះបីជាមានគុណសម្បត្តិ និងមានប្រកាសរួមចេញពីក្រសួងសាមីរួចរាល់ក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌មិនអាចទៅបំពេញមុខងារបានទេ។ ដើម្បីអាចបំពេញមុខងារបាន មន្ត្រីនគរបាលយុត្តិធម៌នីមួយៗត្រូវធ្វើសម្បថថាខ្លួននឹងបំពេញនូវមុខងាររបស់ខ្លួន។ សម្បថត្រូវធ្វើនៅមុខសាលាឧទ្ធរណ៍។ សម្បថមិនចាំបាច់ធ្វើជាថ្មីម្តងទៀតឡើយ នៅពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត។ រូបមន្ត នៃសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[6]។

### ១.១.២. ភ្នាក់ងារនគរបាលយុត្តិធម៌

#### ១.១.២.១. សម្បទាជាភ្នាក់នគរបាលយុត្តិធម៌

ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវមានគុណសម្បត្តិដូចខាងក្រោម៖

១. នាយនគរបាល និងនាយនគរបាលរងដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។

២. ភ្នាក់ងារនគរបាលជាតិផ្សេងទៀត។

៣. នាយទាហាននៃកងរាជអាវុធហត្ថ ដែលមិនមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។

៤. យោធិនផ្សេងទៀត នៃកងរាជអាវុធហត្ថ[7]។

ភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវធ្វើសម្បថថាបំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់។ សម្បថនេះត្រូវធ្វើឡើងនៅចំពោះមុខសាលាដំបូង ហើយសម្បថពុំចាំបាច់ធ្វើឡើងវិញទៀតឡើយ នៅពេលដែលបានទទួលនូវគុណសម្បត្តិជាភ្នាក់ងារនគរបាលយុត្តិធម៌នាពេលក្រោយទៀត។ រូបមន្ត នៃសម្បថត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌[8]។ មានន័យថា ភ្នាក់ងារនគរបាលយុត្តិធម៌ ដែលទើបនឹងទទួលការតែងតាំង មុននឹងចូលបំពេញមុខងាររបស់ខ្លួនត្រូវធ្វើសម្បថនៅចំពោះមុខសាលាដំបូងរាជធានី-ខេត្ត ជាមុនសិន។ ការធ្វើសម្បថនេះ បង្ហាញឱ្យឃើញពីការប្តេជ្ញាចិត្តដោយការទទួលខុសត្រូវខ្ពស់របស់នគរបាលយុត្តិធម៌ទាំងអស់ ដែលមានតួនាទីរក្សានូវសណ្តាប់ធ្នាប់ជូនដល់សង្គមជាតិ ព្រោះនៅក្នុងការបង្រ្កាប និងធ្វើការទប់ស្កាត់នូវបទល្មើស ផ្សេងៗ

[6]-មាត្រា៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[7]-មាត្រា៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[8]-មាត្រា៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដែលបានកើតឡើងនៅក្នុងសង្គមនោះ នគរបាលយុត្តិធម៌ទាំងអស់មានតួនាទីយ៉ាងសំខាន់នៅក្នុងការទប់ស្កាត់ បង្ក្រាប នូវរាល់បទល្មើសទាំងឡាយ ដោយមានស្ថាប័នតុលាការជាអ្នកវិនិច្ឆ័យក្តីដោយយោងតាមគោលការណ៍ច្បាប់ទៅលើជន ដែលបានប្រព្រឹត្តអំពើល្មើសនឹងច្បាប់ព្រហ្មទណ្ឌ ដែលទង្វើនេះធ្វើឱ្យសង្គមបាត់បង់នូវសណ្តាប់ធ្នាប់ និងធ្វើឱ្យប្រជាពលរដ្ឋរស់នៅប្រកបដោយភាពព្រួយបារម្ភព្រោះតែជនខិនខូចមួយចំនួនតូចដែលប្រព្រឹត្តអំពើផ្ទុយនឹងច្បាប់។

ភ្នាក់ងារនគរបាលយុត្តិធម៌មានតួនាទីពិនិត្យបទល្មើសជាអាទិ៍ បទលហុ និងជាជំនួយការរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការបំពេញមុខងារ។ ចំពោះការពិនិត្យបទល្មើស ភ្នាក់ងារនគរបាលយុត្តិធម៌ធ្វើរបាយការណ៍ ហើយរបាយការណ៍នោះ មានតម្លៃត្រឹមតែជាពត៌មានធម្មតាប៉ុណ្ណោះ។ ក្នុងករណីណាក៏ដោយភ្នាក់ងារនគរបាលយុត្តិធម៌ពុំអាចបំពេញកិច្ចទាំងឡាយ ដែលត្រូវរក្សាទុកជូនតែមន្ត្រីនគរបាលយុត្តិធម៌។ កិច្ចទាំងឡាយណាដែលត្រូវបានបំពេញដោយបំពានលើការហាមឃាត់នេះ ត្រូវចាត់ទុកជាមោឃៈ[9]។

រាល់កំហុសទាំងឡាយ ដែលបានប្រព្រឹត្តដោយភ្នាក់ងារនគរបាលយុត្តិធម៌នៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឱ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

យោងតាមករណីនីមួយៗ អគ្គព្រះរាជអាជ្ញាប្រកាសប្រាប់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីចាប់ផ្តើមខាងវិន័យ។ អគ្គព្រះរាជអាជ្ញា ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្តនៃនិតិវិធីវិន័យ[10]។

ទណ្ឌកម្មខាងវិន័យរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្ត។

កាលណា ភ្នាក់ងារនគរបាលយុត្តិធម៌ប្រព្រឹត្តបទល្មើសនៅក្នុងការបំពេញមុខងាររបស់ខ្លួនតុលាការកំពូលអាចផ្ទេរអំណាចទៅយុត្តាធិការផ្សេងចាត់ការវិញបាន ដើម្បីជាប្រយោជន៍ល្អដល់រដ្ឋបាលតុលាការ។ ការសុំដកសិទ្ធិនេះ ត្រូវបានធ្វើឡើងដោយព្រះរាជអាជ្ញា[11]។

### ១.១.៣. មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ ដែលមាននីតិសម្បទាពិសេស

#### ១.១.៣.១. សម្បទាជាមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដែលមាននីតិសម្បទាពិសេស

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈ ដែលច្បាប់ដោយឡែកប្រគល់អំណាចឱ្យពិនិត្យបទល្មើសត្រូវដាក់ឱ្យស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញាក្នុងពេលបំពេញមុខងារនេះ។

[9]-មាត្រា៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[10]-មាត្រា៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[11]-មាត្រា៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចំពោះបែបបទ និងនីតិវិធី នៃការផ្តល់នីតិសម្បទា ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ។

**ឧទាហរណ៍:១**-បើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះធ្វើការនៅក្រសួងកិច្ចការនារី ដូចនេះ ពួកគាត់ត្រូវបានតែងតាំងដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកិច្ចការនារី។

**២**-បើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនោះធ្វើការនៅក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ ដូចនេះ ពួកគាត់ត្រូវបានតែងតាំងដោយប្រកាសរួមរវាងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ។

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតត្រូវស្បថថា បំពេញមុខងាររបស់ខ្លួនដោយស្មោះត្រង់។ សម្បថត្រូវធ្វើនៅចំពោះមុខសាលាដំបូង ហើយរូបមន្ត នៃសម្បថត្រូវកំណត់ដោយប្រកាសរបស់ក្រសួងយុត្តិធម៌។

ចំពោះការពិនិត្យបទល្មើស មន្ត្រីរាជការទាំងនេះ ធ្វើរបាយការណ៍ ហើយរបាយការណ៍នេះមានតម្លៃត្រឹមតែជាពត៌មានធម្មតាប៉ុណ្ណោះ។

រាល់កំហុសទាំងឡាយដែលប្រព្រឹត្តដោយមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀតនៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឱ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញា ប្រកាសប្រាប់រដ្ឋមន្ត្រី ដែលមន្ត្រីឬភ្នាក់ងារនោះនៅក្រោមឱវាទដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។ អគ្គព្រះរាជអាជ្ញា ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការបន្ត នៃនីតិវិធីវិន័យ។ ទណ្ឌកម្មខាងវិន័យ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសត្រូវបានប្រព្រឹត្ត[12]។ មានន័យថា ទោះបីមន្ត្រីរាជការបានទទួលវិន័យក៏ដោយក៏បណ្តឹងអាជ្ញាមិនរលត់ដែរ។

## ១.២.សមត្ថកិច្ចដែនដីរបស់នគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តធម៌ម្នាក់ៗមានសម្តកិច្ចនៅក្នុងព្រំប្រទល់ដែនដី នៃអង្គភាពដែលខ្លួនត្រូវបានចាត់តាំងឱ្យទៅបម្រើការងារ។ នៅរាជធានីភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ចនៅលើវិសាលភាពនៃទីក្រុងទាំងមូល ទោះបីជាអង្គភាពដែលខ្លួនផ្លាស់ទៅកាន់នោះ នៅទីកន្លែងណាក៏ដោយ។ សេចក្តីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបញ្ជាក់មណ្ឌលរដ្ឋបាល ដែលមន្ត្រីនោះ ត្រូវចាត់តាំងឱ្យទៅបម្រើការងារ។ សេចក្តីសម្រេចនេះ ត្រូវផ្តល់ដំណឹងដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍[13]។

---

[12]-មាត្រា៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[13]-មាត្រា៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

យ៉ាងណាមិញ កាលណាមានករណីបទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង ហើយប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ ធ្វើប្រតិបត្តិការលើវិសាលភាពនៃដែនដីជាតិទាំងមូល។ ការអនុញ្ញាតអាចធ្វើដោយផ្ទាល់មាត់បាន ប៉ុន្តែការអនុញ្ញាតនេះត្រូវតែចុះនិទ្ទេសនៅក្នុងលិខិតស៊ើបអង្កេត។

ក្នុងក្របខ័ណ្ឌ នៃការស៊ើបសួរ កាលណាចៅក្រមស៊ើបសួរចេញដីកាចាត់ឱ្យស៊ើបសួរជំនួសក្នុងករណីបន្ទាន់ ចៅក្រមអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តធម៌ ធ្វើប្រតិបត្តិការនៅលើវិសាលភាពដែនដីទាំងមូល។

កាលណា ធ្វើប្រតិបត្តិការនៅក្រៅមណ្ឌលរបស់ខ្លួននោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវសុំជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចខាងដែនដី។ ចៅក្រម ដែលបានអនុញ្ញាតឱ្យមានការពន្លាតសមត្ថកិច្ច ត្រូវជូនពត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដី[14]។

**<u>ឧទាហរណ៍:</u>** មានបទល្មើសមួយកើតឡើងនៅខេត្តកំពង់ចាម នៅពេលនោះជនសង្ស័យបានរត់គេចខ្លួនទៅដល់ខេត្តបាត់ដំបង។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចនៅក្នុងខេត្តកំពង់ចាមអាចពន្លាតសមត្ថកិច្ចដែនដី ដើម្បីបំពេញភារកិច្ច តាមចាប់ជនសង្ស័យនោះនៅខេត្តបាត់ដំបងបាន ដោយត្រូវអនុវត្តតាមនីតិវិធីខាងលើ ជាដំបូង ត្រូវតែសុំការឯកភាពពីព្រះរាជអាជ្ញាខេត្តកំពង់ចាមសិន ទោះបីការអនុញ្ញាតនោះធ្វើឡើងដោយផ្ទាល់មាត់ក៏ដោយ មុននឹងចាប់ផ្តើមបេសកកម្មរបស់ខ្លួន។ ពេលនោះ ព្រះរាជអាជ្ញាខេត្តកំពង់ចាមនឹងធ្វើការជូនដំណឹងទៅព្រះរាជអាជ្ញាខេត្តបាត់ដំបងឱ្យបានដឹងពីករណី ដែលខ្លួនបានអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ចុះទៅអនុវត្តបេសកកម្ម។ បន្ទាប់មក មន្ត្រីនគរបាលយុត្តិធម៌អាចអនុវត្តបេសកកម្មក្នុងខេត្តបាត់ដំបង ដោយត្រូវមានកិច្ចសហការជាមួយមន្ត្រីនគរបាល ដែលមានទីតាំងនៅខេត្តបាត់ដំបង ដើម្បីតាមចាប់ជនសង្ស័យរួចបញ្ជូនមកខេត្តកំពង់ចាមវិញ។

## ១.៣. តួនាទី និងសិទ្ធិ អំណាចមន្ត្រីនគរបាលយុត្តិធម៌

### ១.៣.១. ការពិនិត្យស្វែងរកបទល្មើស

មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិ អំណាចក្នុងការពិនិត្យ ស្វែងរកបទល្មើស ដោយខ្លួនឯង ឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញា កាលណា បានដឹងហេតុការណាមួយថាមាន បទឧក្រិដ្ឋកម្ម ឬ

[14]-មាត្រា៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

បទមជ្ឈិមកើតឡើងដោយមិនចាំបាច់មានអ្នកប្ដឹងឡើយ។ មន្ត្រីនគរបាលយុត្តិធម៌ ក៏អាចពិនិត្យស្វែងរកបទល្មើសតាមរយៈការទទួលពាក្យបណ្ដឹងទាមទារ និងបណ្ដឹងបរិហារ។

**១.៣.១.១. បណ្ដឹងទាមទារ (បណ្ដឹងរដ្ឋប្បវេណី)**

បណ្ដឹងទាមទារ (បណ្ដឹងរដ្ឋប្បវេណី) គឺជាបណ្ដឹងធ្វើឡើងក្នុងគោលបំណងទាមទារ នូវសំណងជួសជុល នៃការខូចខាត ដែលបណ្ដាលមកពីអំពើល្មើស ដល់ភាគីដែលទទួលរងគ្រោះ។ សំណង ដែលភាគីរងគ្រោះអាចទាមទារបាន មានសំណងជួសជុលការខូចខាតខាងទ្រព្យសម្បត្តិ ឬសម្ភារៈ និងសំណងជម្ងឺចិត្តជាដើម។

**១.៣.១.២. បណ្ដឹងបរិហារ**

បណ្ដឹងបរិហារ គឺសំដៅលើបណ្ដឹងវែកមុខបទល្មើស ឬបកអាក្រាតបទល្មើស ដើម្បីឱ្យស្ថាប័នមានសមត្ថកិច្ចធ្វើការពិនិត្យ និងសម្រេចស្វែងរកភស្តុតាងនៅក្នុងបទល្មើស ហើយតាមចាប់ជនល្មើសមកផ្ដន្ទាទោសតាមច្បាប់។ នៅក្នុងបណ្ដឹងបរិហារនេះដែរ ក៏អាចធ្វើឡើងដោយតតីយជនដែលគាត់បានដឹងបានឃើញអំពីហេតុការណ៍នៃបទល្មើស។ នៅក្នុងចំណុចនេះ គឺបានបង្ហាញយ៉ាងច្បាស់ថា ជនគ្រប់រូប គឺសុទ្ធតែអាចធ្វើបណ្ដឹងបរិហារទៅកាន់មន្ត្រីនគរបាលយុត្តិធម៌បាន កាលណាគាត់បានដឹង និងបានឃើញអំពើល្មើសកើតឡើងពិតប្រាកដ។ ក្នុងគោលបំណងមួយ ដើម្បីឱ្យសមត្ថកិច្ចធ្វើការតាមចាប់ខ្លួនជនល្មើសមកដាក់ទោសតាមច្បាប់។ មួយវិញទៀត បណ្ដឹងបរិហារអាចធ្វើឡើងដោយមន្ត្រីសាធារណៈផងដែរ ដែលច្បាប់នីតិវិធីព្រហ្មទណ្ឌបានកំណត់នៅក្នុង មាត្រា ៤២ ថា " អាជ្ញាធរសាធារណៈ ឬមន្ត្រីគ្រប់រូបដែលនៅក្នុងការបំពេញមុខងាររបស់ខ្លួន បានដឹងអំពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬដល់មន្ត្រីនគរបាលយុត្តិធម៌ ដោយត្រូវបញ្ជូននូវពត៌មានកំណត់ហេតុ លិខិត និងវត្ថុតាងទាំងអស់ ដែលទាក់ទងនឹងបទល្មើសនោះភ្ជាប់មកជាមួយផង"[15]។

ដូចនេះ បណ្ដឹងអាចទទួលពីជនរងគ្រោះ ដែលជាអ្នកប្ដឹងទៅកាន់មន្ត្រីនគរបាលយុត្តិធម៌ និងអាចទទួលតាមរយៈតតីយជនធ្វើការប្ដឹងបរិហារ។ ពាក់ព័ន្ធនឹងបណ្ដឹងនេះ អាចទទួលតាមរយៈជារបាយការណ៍របស់ភ្នាក់ងារនគរបាលយុត្តិធម៌ ដែលជាជំនួយការរបស់មន្ត្រីនគរបាលយុត្តិធម៌។

**១.៣.២.ការធ្វើកំណត់ហេតុ និងបញ្ជីបណ្ដឹង**

មន្ត្រីនគរបាលយុត្តិធម៌មានតួនាទីក្នុងការទទួលពាក្យបណ្ដឹង។

គ្រប់បណ្ដឹងទាំងអស់ ដែលទទួលដោយមន្ត្រីនគរបាលយុត្តិធម៌នោះ តម្រូវឱ្យមានធ្វើកំណត់ហេតុ។ មានន័យថា កាលណាមន្ត្រីនគរបាលយុត្តិធម៌បានទទួលពាក្យបណ្ដឹងហើយនោះ

[15] មាត្រា៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

គាត់ត្រូវធ្វើកំណត់ហេតុ ហើយកំណត់ហេតុ ត្រូវស្រង់ដោយត្រឹមត្រូវនូវ សេចក្ដីរាយការណ៍របស់អ្នកប្ដឹង។ នៅក្នុងករណីចាំបាច់មួយ ប្រសិនបើ អ្នកដែលប្ដឹងមកមិនចេះភាសាខ្មែរទេ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែភាសាម្នាក់ដែលត្រូវស្បថតាមជំនឿ ឬសាសនាថាខ្លួននឹងបកប្រែភាសាឱ្យបានត្រឹមត្រូវតាមសេចក្ដីរាយការណ៍។ នៅក្នុងករណីណាក៏ដោយ អ្នកបកប្រែភាសាមិនអាចត្រូវបានជ្រើសរើសក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការបានឡើយ។ កាលណាអ្នកបកប្រែក្នុងចំណោមគ្នាឯងនោះ គឺនាំឱ្យមានមោឃៈភាពនៃកំណត់ហេតុ។

កំណត់ហេតុស្ដីអំពីការដាក់ពាក្យប្ដឹងត្រូវមានចុះសេចក្ដីដូចតទៅ៖

-ឈ្មោះ និងឋានៈរបស់មន្ត្រីបគរបាលយុត្តិធម៌

-អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌

-កាលបរិច្ឆេទ។

ទំព័រនីមួយៗត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌ និងដោយអ្នកប្ដឹង។

ការឆូត ការថែម និងការយោង ត្រូវតែមានបញ្ជាក់ដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌ និងអ្នកប្ដឹង នៅរឹមទំព័រ។

មុននឹងចុះហត្ថលេខា ឬផ្ដិតម្រាមដៃ អ្នកប្ដឹងត្រូវអានកំណត់ហេតុឡើងវិញ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ ត្រូវអានខ្លឹមសារកំណត់ហេតុដោយសម្លេងខ្លាំងៗ[16]។

ជាមួយគ្នានេះដែរ ដើម្បីធានានូវប្រសិទ្ធិភាព និងដើម្បីឱ្យអាជ្ញាធរតុលាការ ជាពិសេសគឺព្រះរាជអាជ្ញា ដែលមានតួនាទីសំខាន់ ជាអ្នកសម្របសម្រួលដឹកនាំការងាររបស់មន្ត្រីនគរបាលយុត្តធម៌ ដូចនេះ នៅគ្រប់អង្គភាពរបស់នគរបាលយុត្តិធម៌ត្រូវតែមានបញ្ជីទទួលពាក្យបណ្ដឹងមួយ។ នៅគ្រប់ពេល ដែលមានការដាក់ពាក្យប្ដឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងបញ្ជីនូវនិទ្ទេសសំខាន់ៗមួយចំនួនដូចតទៅ៖

-អត្តសញ្ញាណរបស់អ្នកប្ដឹង

-កាលបរិច្ឆេទនៃការដាក់ពាក្យប្ដឹង

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើកំណត់ហេតុស្ដីពីការដាក់ពាក្យប្ដឹង។

-ប្រភេទនៃអំពើដែលប្ដឹង

[16]-មាត្រា៧២នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

-ចំណាត់ការលើបណ្តឹងដូចជាបញ្ជូនទៅព្រះរាជអាជ្ញា ឬក៏ផ្តើមធ្វើការស៊ើបអង្កេត។ បញ្ជីបណ្តឹងត្រូវតែកាន់កាប់ជាអចិន្ត្រៃយ៍សម្រាប់ជូនអាជ្ញាធរតុលាការតាមតម្រូវការ[17]។

**១.៣.៣. ការធ្វើចំណាត់ការលើពាក្យប្តឹង**

មន្ត្រីនគរបាលយុត្តិធម៌មានកាតព្វកិច្ចធ្វើចំណាត់ការលើបណ្តឹងភ្លាមៗក្រោយពេល ដែលទទួលបាននូវពាក្យបណ្តឹង ថាត្រូវធ្វើការស៊ើបអង្កេត ឬក៏បញ្ជូនកំណត់ហេតុស្តីពី ការដាក់ពាក្យប្តឹងនោះទៅព្រះរាជអាជ្ញាដើម្បីចាត់ការ។ មុនធ្វើការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចសុំសេចក្តីណែនាំពីព្រះរាជអាជ្ញា។ កាលណា បានទទួលពាក្យបណ្តឹងបរិហារ ដែលមានបង្ហាញមូលហេតុជាក់ច្បាស់ សមហេតុផល មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនពត៌មានដល់ព្រះរាជអាជ្ញា និងសុំការណែនាំ[18]។

ដូចនេះ ប្រសិនបើ ក្នុងករណីទទួលពាក្យបណ្តឹងទាមទារ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការទទួលពាក្យបណ្តឹង ហើយគាត់អាចចាត់ការទៅលើពាក្យបណ្តឹងដោយឯកឯង ថាត្រូវបើកការស៊ើបអង្កេតជាបឋម។ ប៉ុន្តែ បើក្នុងករណីទទួលពាក្យបណ្តឹងបរិហារវិញ មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនពត៌មាន ឬរាយការណ៍ជូនព្រះរាជអាជ្ញា និងសុំការណែនាំរបស់ព្រះរាជអាជ្ញា។

ក្នុងករណីណាក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌មិនអាចតំកល់រឿងព្រហ្មទណ្ឌណាមួយទុកឥតចាត់ការបានទេ ទោះបីជាក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះ ឬ ក៏មានការដកពាក្យប្តឹងក៏ដោយ។

មន្ត្រីនគរបាលយុត្តិធម៌ ដែលរក្សាទុកកំណត់ហេតុ ឬវត្ថុតាងដោយចេតនា ឬក៏លាក់បំបាំងដល់អាជ្ញាធរតុលាការអំពីអត្ថិភាព នៃកំណត់ហេតុ ឬវត្ថុតាង ត្រូវចាត់ទុកថាមន្ត្រីនគរបាលនោះបានប្រព្រឹត្តបទល្មើស ដែលត្រូវផ្តន្ទាទោសតាមក្រមព្រហ្មទណ្ឌ ពាក់ព័ន្ធនឹងជំពូកស្តីពីការស្រាវជ្រាវរកភស្តុតាង[19]។

**១.៤. ការស៊ើបអង្កេត**

- **គោលការណ៍ទូទៅ នៃការស៊ើអង្កេត**

ជាគោលការណ៍ ការស៊ើបអង្កេតត្រូវតែជាការសម្ងាត់[20]។ មានន័យថា នៅគ្រប់ដំណាក់កាលនៃការស៊ើបអង្កេតរបស់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ ត្រូវបានរក្សាការសម្ងាត់ នេះជាការចាំបាច់មួយ ដែលតម្រូវឱ្យអ្នកដែលមានកាតព្វកិច្ចចូលរួមនៅក្នុងការស៊ើបអង្កេតនេះ ត្រូវអនុវត្តឱ្យបានត្រឹមត្រូវ និងហ្មត់ចត់បំផុត ដោយត្រូវចៀសវាងឱ្យបាននូវការធ្វេសប្រហែសនានា ដែលជាហេតុនាំឱ្យមានការបែកធ្លាយការសម្ងាត់ពត៌មាន នៃការស៊ើបអង្កេត ដែលជាបច្ច័យអាក្រក់មួយ

[17]-មាត្រា៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[18]-មាត្រា៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[19]-មាត្រា៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[20]-មាត្រា៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដល់ការស៊ើបអង្កេត។ ដូចនេះហើយ បានជាស្មារតីនៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងកំណត់អំពីគោលការណ៍ នៃការស៊ើបអង្កេត ឱ្យមានលក្ខណៈរក្សាការសម្ងាត់ឱ្យខានតែបាន ដោយតម្រូវឱ្យបុគ្គលទាំងឡាយ ដែលចូលរួមក្នុងការស៊ើបអង្កេតជាពិសេស ព្រះរាជអាជ្ញា មេធាវី ក្រឡាបញ្ជីនគរបាល កងរាជ អាវុធហត្ថ មន្ត្រីរាជការជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គល ដែលមានសមត្ថកិច្ចដទៃទៀត ត្រូវរក្សាការសម្ងាត់វិជ្ជាជីវៈ[21]។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ករណីរក្សាការសម្ងាត់នេះមិនចងកាតព្វកិច្ចឱ្យព្រះរាជអាជ្ញាដាច់ខាតត្រូវតែគោរពនោះទេ ព្រោះជាទូទៅរាល់គោលការណ៍របស់ច្បាប់តែងតែមានចែងពីគោលការណ៍ទូទៅ និងករណីអញ្ញត្រកម្ម។ ករណីនេះ ក៏ដូចគ្នាដែរ ព្រះរាជអាជ្ញាអាចមានសិទ្ធិធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈបាន ដោយបង្ហាញនូវពត៌មានទាំងឡាយដើម្បីការពារខ្លួន នៅក្នុងករណីដែលយល់ថា ពត៌មាននោះជាពត៌មានមិនពិត។ មានន័យថា ការគោរពនូវការសម្ងាត់វិជ្ជាជីវៈមិនមែនជាឧបសគ្គដល់ការប្រើប្រាស់សិទ្ធិការពារខ្លួនឡើយ។ ដោយព្រះរាជអាជ្ញា ត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈបាន កាលណាខ្លួនយល់ឃើញថាពត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះជាពត៌មាន ដែលមាន ប្រយោជន៍។

ជាទូទៅ នៅក្នុងការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ចែកចេញជាពីរធំៗគឺ ការស៊ើបអង្កេតករណីជាក់ស្តែង និងការស៊ើបអង្កេតបឋម។ អំណាចទាំងឡាយ ដែលផ្តល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ខុសគ្នាទៅតាមពេលដែលមន្ត្រីនោះ បម្រើការងារក្នុងក្របខណ្ឌ នៃការស៊ើបអង្កេតករណីជាក់ស្តែង ឬក្នុងក្របខណ្ឌនៃការស៊ើបអង្កេតជាបឋម។ ក្នុងន័យនេះមានន័យថា ការស៊ើបអង្កេតទាំងពីរនេះ គឺមិនដូចគ្នាទេ ទាំងនីតិវិធី ទាំងអំណាចប្រើប្រាស់ដោយមន្ត្រីនគរបាលយុត្តិធម៌ ក្នុងក្របខណ្ឌ នៃការស៊ើបអង្កេតនេះក៏ខុសគ្នាដែរ។

តើក្នុងក្របខណ្ឌ និងស្ថានភាពដូចម្តេច ដែលនគរបាលយុត្តិធម៌អាចបើកការស៊ើបអង្កេតករណីជាក់ស្តែង និងបើកការស៊ើបអង្កេតបឋម?

### ១.៤.១. ការស៊ើបអង្កេតបឋម

ការស៊ើបអង្កេតបឋម គឺជាការស្រាវជ្រាវប្រមូលភស្តុតាង ដែលធ្វើឡើងនៅពេលដែលមានបទល្មើសមិនជាក់ស្តែង។

នៅក្នុងការស៊ើបអង្កេតបឋម កាលណាបានដឹងពីអំពើដែលជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា។ ម្យ៉ាងទៀត ចំពោះថិរវេលា នៃការស៊ើបអង្កេតបឋម គឺមិនមានកំណត់ពេលវេលាជាក់លាក់ទេ។ នៅក្នុងនីតិវិធី នៃការស៊ើបអង្កេតបឋម គឺមានវិធានមួយចំនួនដែលបានអនុវត្តដូចគ្នាទៅនឹងការស៊ើបអង្កេតករណីជាក់ស្តែង ហើយមានវិធានមួយចំនួនទៀតមានលក្ខណៈខុសគ្នាទៅ

[21]-សេចក្តីពន្យល់នៅក្នុងសៀវភៅ នីតិវិធីព្រហ្មទណ្ឌ របស់ អនុបណ្ឌិត អៀង សំណាង បោះពុម្ពឆ្នាំ២០១៥

នឹងការស៊ើបអង្កេតករណីជាក់ស្តែងដែរ ព្រោះថាអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងលក្ខខណ្ឌនៃការស៊ើបអង្កេតបឋមត្រូវបានកំណត់តឹងរឹងជាងការស៊ើបអង្កេតករណីជាក់ស្តែង។

**១.៤.១.១. ការបើកការស៊ើបអង្កេតបឋម**

កាលណាបានដឹងពីអំពើដែលអាចជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ មន្ត្រីនគរបាលយុត្តធម៌អាចធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា[22]។

**<u>ឧទាហរណ៍:</u>** មន្ត្រីនគរបាលគាត់បានដឹងតាមរយៈសារពត៌មានក្នុងករណីឧក្រិដ្ឋកម្មមួយកើតឡើងទាក់ទងនឹងអំពើមនុស្សឃាត ដូចនេះ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការបើកការស៊ើបអង្កេតបឋមលើករណីនេះបានដោយឯកឯង ឬតាមការសុំរបស់ព្រះរាជអាជ្ញា ព្រោះវាមិនមែនជាករណីបទល្មើសជាក់ស្តែង។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន[23]។

ប្រសិនបើ ត្រូវធ្វើការត្រួតពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រ ដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូប ដែលមានមុខវិជ្ជាជំនាញ។ ប្រសិនបើ បុគ្គលនោះមិនទាន់បានចុះបញ្ជីអ្នកជំនាញ ដែលបញ្ជីនេះត្រូវបានបង្កើតដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ដែលបែបបទ នៃការចុះឈ្មោះ ឬក៏លុបឈ្មោះចេញពីបញ្ជីកំណត់ដោយប្រកាសក្រសួងយុត្តិធម៌[24]។

មន្ត្រីនគរបាលយុត្តិធម៌ ពុំមានអំណាចបង្គាប់ឱ្យស្តាប់ និងថតសម្លេងការសន្ទនាតាមទូរស័ព្ទបានឡើយ ហើយមន្ត្រីនគរបាលយុត្តិធម៌ពុំមានអំណាចបង្គាប់ឱ្យចាប់ និងថតនូវការឆ្លើយឆ្លង ដែលចេញតាមមធ្យាបាយទូរគមនាគមន៍ ជាអាទិ៍ សារតាមទូរសា ឬសារតាមអិនធឺណេត[25]។

**១.៤.១.២. ការឆែកឆេរ**

កាលណា ការស៊ើបអង្កេតជាបឋមនោះ ទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរ និងចាប់យកវត្ថុតាង។

យ៉ាងណាមិញ មុននឹងធ្វើការឆែកឆេរ ជាដំបូង គឺត្រូវតែទទួលការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង។ ការយល់ព្រមត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ សរសេរដោយផ្ទាល់ដៃរបស់អ្នកកាន់កាប់ទីកន្លែង។ ប្រសិនបើ អ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរទេនោះ ត្រូវសរសេរឱ្យបានច្បាស់លាស់ក្នុងកំណត់ហេតុថា អ្នកកាន់កាប់ទីកន្លែងនោះមិនចេះអក្សរ ហើយយល់ព្រមឱ្យឆែកឆេរ។

[22]-មាត្រា១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[23]-មាត្រា៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[24]-មាត្រា៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[25]-មាត្រា១០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក្នុងករណី ដែលអ្នកកាន់កាប់ទីកន្លែងមិននៅ (អវត្តមាន) ឬបដិសេធការឆែកឆេរ ប្រធានសាលាដំបូង ដែលមានសមត្ថកិច្ចដែនដី អាចចេញដីកាអនុញ្ញាតឱ្យឆែកឆេរ តាមការស្នើសុំរបស់ព្រះរាជអាជ្ញា។ បន្ទាប់មក ព្រះរាជអាជ្ញាត្រូវដឹកនាំដោយផ្ទាល់នូវការឆែកឆេរនោះ។ ការឆែកឆេរត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើចំពោះមុខសាក្សីពីរនាក់។ សាក្សីនេះដែរ ត្រូវបានចាត់តាំងឡើងដោយព្រះរាជអាជ្ញា។ សាក្សីដាច់ខាតមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះឡើយ។

ការឆែកឆេរមិនអាចចាប់ផ្ដើមមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ល្ងាចបានឡើយ[26]។

#### ១.៤.១.៣. ការបញ្ជាឱ្យចូលខ្លួន

មន្ត្រីនគរបាលយុត្តិធម៌ មានអំណាចក្នុងការកោះហៅ និងស្ដាប់ចម្លើយបុគ្គលគ្រប់រូប ដែលត្រូវបានសង្ស័យថាបានចូលរួមក្នុងបទល្មើស ឬបុគ្គល ដែលអាចផ្ដល់ពត៌មានស្ដីពីរឿងហេតុបាន។

បុគ្គលដែលបានកោះហៅនោះ ត្រូវតែចូលមកបង្ហាញខ្លួន។ ក្នុងករណី មានការរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចបញ្ជាឱ្យចូលខ្លួន។

ការបញ្ជាឱ្យចូលខ្លួននេះត្រូវតែមានចុះអត្តសញ្ញាណអ្នកពាក់ព័ន្ធ ចុះកាលបរិច្ឆេទ និងចុះហត្ថលេខា ដោយព្រះរាជអាជ្ញា និងមានបោះត្រាផងដែរ។

ការបញ្ជាឱ្យចូលខ្លួនត្រូវបានអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះឱ្យចូលខ្លួន[27]។

#### ១.៤.១.៤. កំណត់ហេតុស្រង់ចម្លើយ

កាលណា មន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្ដាប់ចម្លើយបុគ្គលដែលពាក់ព័ន្ធ ការស្ដាប់ចម្លើយនីមួយៗត្រូវមានធ្វើកំណត់ហេតុ។ ការធ្វើកំណត់ហេតុ ត្រូវដកស្រង់ដោយត្រឹមត្រូវទៅតាមចម្លើយរបស់បុគ្គលដែលពាក់ព័ន្ធ ដែលបានផ្ដល់នោះ។ នៅក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែ ដែលបានស្បថតាមសាសនា និងជំនឿរបស់ខ្លួនថាខ្លួននឹងបកប្រែឱ្យបានត្រឹមត្រូវ។ ជាមួយគ្នានេះដែរ អ្នកបកប្រែមិនត្រូវបានធ្វើការជ្រើសរើសនៅក្នុងចំណោមនគរបាល ឬកងរាជអាវុធហត្ថ ឬបុគ្គលពាក់ព័ន្ធនៅក្នុងរឿងជាមួយគ្នា ដែលកំពុងធ្វើការស៊ើបអង្កេតឡើយ។

#### ១.៤.១.៥. ការឃាត់ខ្លួនជនជាប់សង្ស័យ

កាលណា ការស៊ើបអង្កេតបឋមទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម នោះបទបញ្ញត្តិ នៃជំពូកទី៣ ស្ដីពីការឃាត់ខ្លួន និងជំពូកទី៤ ស្ដីពីការបញ្ជូនខ្លួននៃមាតិកាទី២ ស្ដីពីការស៊ើបអង្កេតជាក់ស្ដែង

[26]-មាត្រា១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[27]-មាត្រា១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក្នុងគន្លី នៃក្រមនេះ ត្រូវយកមកអនុវត្ត[28]។ មានន័យថា មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិឃាត់ខ្លួនជនជាប់សង្ស័យបានដោយអនុវត្តនីតិវិធីឃាត់ខ្លួននៅក្នុងដំណាក់កាល នៃការស៊ើបអង្កេតជាក់ស្តែងបានកាលណាការស៊ើបអង្កេតបឋមទាក់ទងនឹងបទឧក្រិដ្ឋ ឬបទមជ្ឈិម។

សរុបមក ការស៊ើបអង្កេតបឋម មន្ត្រីនគរបាលយុត្តិធម៌ត្រូវគោរពតាមវិធាន និងទម្រង់ដែលមានបញ្ញត្តិនៅមាត្រា ៩៦ ៩៧ ១០០ ១០៥ ១១៣ និង ១១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ បើមិនគោរពទេនាំឱ្យមានមោឃៈភាព នៃនីតិវិធី[29]។

ក្រោយពេលបញ្ចប់នូវការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា។ កាលណា បុគ្គលណាមួយ ដែលត្រូវបានបញ្ជូនទៅព្រះរាជអាជ្ញាត្រូវតែបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅជាមួយ ដើម្បីឱ្យព្រះរាជអាជ្ញាធ្វើការពិនិត្យ[30]។

កំណត់ហេតុ ដែលធ្វើដោយមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសដូចជា៖

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌

-អង្គភាពរបស់មន្ត្រីនគរបាលយុត្តិធម៌

-កាលបរិច្ឆេទ។

ទំព័រនីមួយៗ ត្រូវចុះហត្ថលេខាដោយមន្ត្រីនគរបាលយុត្តិធម៌។ ពាក្យឆូតលុប និងការយោងត្រូវមានបញ្ជាក់យល់ព្រម ដោយមានចុះហត្ថលេខារបស់មន្ត្រីនគរបាលយុត្តិធម៌នៅរឹមទំព័រ។

កំណត់ហេតុស្តីពីការស្តាប់ចម្លើយ ឬស្តីពីការឃាត់ខ្លួន ត្រូវមានចុះអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ[31]។

### ១.៤.២. ការស៊ើបអង្កេតជាក់ស្តែង

ការស៊ើបអង្កេតក្នុងករណីជាក់ស្តែង គឺជាការស្រាវជ្រាវប្រមូលភស្តុតាង នៅពេលដែលមានបទល្មើសជាក់ស្តែងកើតឡើង។

តើយើងអាចកំណត់បានយ៉ាងដូចម្តេចអំពីបទល្មើសជាក់ស្តែង?

#### ១.៤.២.១. និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺ៖

-បទល្មើសដែលកំពុងប្រព្រឹត្ត[32]

---

[28]-មាត្រា១១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[29]-សៀវភៅនីតិវិធីព្រហ្មទណ្ឌ សាស្ត្រាចារ្យ អ៊ាន សំអាត បោះពុម្ពឆ្នាំ២០១៤

[30]-មាត្រា១០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[31]-មាត្រា១០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

-បទល្មើសដែលទើបនឹងប្រព្រឹត្តរួចភ្លាម[33]។

ត្រូវចាត់ទុកថាជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណា នៅក្រោយពេលមានបទល្មើសរួចបន្តិចមកៈ

-ជនដែលគេសង្ស័យ ត្រូវបានសាធារណៈជនស្រែកដេញប្រផាប់ ចាប់ប្រភីង[34]

-បុគ្គល ដែលត្រូវគេរកឃើញមានវត្ថុ ឬ មានស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស[35]។

**<u>ឧទាហរណ៍:</u>** ក្រោយពេលដែលបានប្រព្រឹត្តបទល្មើសបន្តិចមកភ្លាម បានដឹងអំពីករណីឃាតកម្មកើតឡើងនៅទីកន្លែងណាមួយ នៅពេលនោះគេឃើញថា ជនរងគ្រោះត្រូវបានជនល្មើសសម្លាប់ដោយប្រើកាំបិតកាប់ជននោះបណ្តាលឱ្យស្លាប់ ក្រោយពីបានពិនិត្យរួចហើយ នគរបាលយុត្តិធម៌បានចាប់ផ្តើមបន្តការស៊ើបអង្កេត លុះបន្តិចមកស្រាប់តែបានឃើញជនម្នាក់ ដែលនៅក្នុងស្ថានភាពមួយ គឺគាត់មានអាវប្រលាក់ឈាម និងដៃកាន់កាំបិទសុទ្ធតែឈាម ហើយស្ថានភាពនៅក្បែរនោះផង គឺស្ថានភាពរបស់គាត់នាំឱ្យគេអាចសន្និដ្ឋានបានថា គាត់បានប្រព្រឹត្តបទល្មើសជាក់ស្តែង។

មួយវិញទៀត ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ បើទោះបីជាស្ថិតនៅក្រៅករណីខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយ ដែលបានប្រព្រឹត្តនៅក្នុងទីកន្លែង ដែលអ្នកកាន់កាប់នៅទីនោះសុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវតែរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌[36]។

កាលណា មានមានសកម្មភាពណាមួយ ដែលមានក្នុងចំណុចខាងលើ គឺអាចសន្និដ្ឋានបានថាមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង។

---

[32]-បទល្មើសដែលកំពុងប្រព្រឹត្ត គឺ ស្ថានភាពដែលយើងមើលឃើញជាក់ស្តែងនឹងមុខ។

[33]-បទល្មើសដែលទើបនឹងប្រពឹត្តរួចភ្លាម គឺមានន័យថាក្រោយពេល ដែលប្រព្រឹត្តបទល្មើសរួចហើយភ្លាម ហើយត្រូវបានគេឃើញនៅ កន្លែងកើតហេតុតែម្តង។

[34]-ដេញប្រផាប់ចាប់ប្រភីង មានន័យថា ការដេញចាប់យ៉ាងប្រកិត ហើយចាប់ជននោះបាន។

[35]-មាត្រា៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[36]-មាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក្នុងករណី បទឧក្រិដ្ឋ ឬបទមជ្ឈឹមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត។ នៅក្នុងចំណុចនេះ បានបង្ហាញថា ច្បាប់បានប្រគល់សិទ្ធិ អំណាចជូនប្រជាពលរដ្ឋជាពិសេស ក្នុងការចូលរួមចាប់ជនល្មើស ក្នុងករណីមានភាពអសកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌[37]។

### ១.៤.២.២. វិធានការស្រាវជ្រាវ

#### ក. វិធានការដំបូង

ក្នុងករណីមាន បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា។ បន្ទាប់មក មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះទៅកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស និងធានារ៉ាប់រងរក្សាទុកនូវតម្រុយ នៃភស្តុតាងទាំងឡាយណា ដែលអាចនឹងបាត់បង់។ ក្នុងពេលនោះដែរ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅទីណាឆ្ងាយពីកន្លែងបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។

ប្រសិនបើ យល់ឃើញថាមានផលប្រយោជន៍ ព្រះរាជអាជ្ញាចុះទៅកាន់កន្លែងកើតហេតុ និងដឹកនាំគ្នាស៊ើបអង្កេត។

ប្រសិនបើ មានការបន្ទាន់ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រត្តិបតិបត្តិការលើវិសាលភាពទាំងមូល នៃដែនដីជាតិដោយគោរពតាមលក្ខខណ្ឌទាំងឡាយ នៃការពន្លាតសមត្ថកិច្ចដែនដី[38]។

បន្ទាប់មក មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន[39]។

#### ខ. ការឆែកឆេរ

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក្តី ឬជាលាយលក្ខណ៍អក្សរក្តី។ ការឆែកឆេរ ត្រូវធ្វើចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់។ សាក្សីត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌។ សាក្សីមិនអាចជានគរបាលយុត្តិធម៌ ឬជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការ ក្នុងការឆែកឆេរនោះបានឡើយ។

[37]-មាត្រា៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[38]-មាត្រា៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[39]-មាត្រា៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចផ្តើមធ្វើការឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង១៨ (ដប់ប្រាំបី) ល្ងាចបានឡើយលើកលែងតែៈ

-ក្នុងករណីមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

-ក្នុងករណីចាត់ទុកជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

-ក្នុងករណីមានសម្រែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង

-ក្នុងករណី ឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោង ដែលបើកចំហរដល់សាធារណៈជនដូចជា ភោជនីយដ្ឋាន ឬក្លឹបរាំកម្សាន្ត។

-ក្នុងករណី ឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយប្រើប្រាស់គ្រឿងញៀន។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរ ដែលនៅក្នុងនោះមានចុះអំពីៈ

-ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោង នៃការអនុញ្ញាតនោះ

-ការអនុញ្ញាតរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរនៅការិយាល័យមេធាវីបានទេ។ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាន ហើយការឆែកឆេរត្រូវធ្វើចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី។

ម្យ៉ាងវិញទៀតនោះ មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរនៅក្នុងអគារសារពត៌មានសហគ្រាស នៃសារពត៌មានសរសេរ ឬសហគ្រាសសារពត៌មានសោតទស្សន៍បានតែចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលធានារ៉ាប់រងកុំឱ្យការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារពត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយពត៌មាននេះដោយមិនត្រឹមត្រូវ[40]។

**គ. ការចាប់យកវត្ថុតាង និងការបិទស្លាកបោះត្រាលើវត្ថុតាង**

មន្ត្រីនគរបាលយុត្តិធម៌ មានអំណាចចាប់យកវត្ថុតាង កាលណា ពេលធ្វើការឆែរឆេរនោះបានរកឃើញភស្តុតាង ដែលពាក់ព័ន្ធនឹងបទល្មើស និងបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ។

ក្រោយពីបានបង្ហាញវត្ថុដែលចាប់បានទៅកាន់សាក្សីពីរនាក់ និងអ្នកកាន់កាប់ទីកន្លែងមើលរួចហើយ មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការចាប់យក ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់។ កំណត់ហេតុស្តីពីការចាប់យកត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់[41]។

[40]-មាត្រា៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[41]-មាត្រា៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**ឃ. ការបញ្ជាឱ្យចូលខ្លួន និងការស្តាប់ចម្លើយ**

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលអាចផ្តល់ពត៌មានស្តីអំពីរឿងហេតុបាន។ បុគ្គលដែលបានកោះហៅនោះត្រូវតែចូលបង្ហាញខ្លួន។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដើម្បីឱ្យព្រះរាជអាជ្ញាចេញបញ្ជាឱ្យចូលខ្លួន។ បញ្ជាឱ្យចូលខ្លួននេះត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផងដែរ។ ការបញ្ជាឱ្យចូលខ្លួន គឺអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈ ដើម្បីបង្ខំបុគ្គលនោះឱ្យចូលបង្ហាញខ្លួន[42]។

នៅពេលដែលធ្វើការស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុឱ្យបានគ្រប់ជ្រុងជ្រោយ។

កំណត់ហេតុ ត្រូវដកស្រង់តាមឱ្យបានត្រឹមត្រូវ នូវសេចក្តីរាយការណ៍របស់បុគ្គលដែលផ្តល់ចម្លើយ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចរកអ្នកបកប្រែ ដែលស្បថថានិយាយការពិតស្របតាមជំនឿ ឬសាសនារបស់ខ្លួន។ អ្នកបកប្រែ មិនអាចជ្រើសរើសយកពីក្នុងចំណោមនគរបាលកងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទងក្នុងរឿងជាមួយគ្នាទេ។

នៅតាមទំព័រនីមួយៗ នៃកំណត់ហេតុ ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយបុគ្គលដែលបានឆ្លើយ។ ហើយបុគ្គល ដែលផ្តិតម្រាមដៃនេះដែរ មុននឹងចុះហត្ថលេខា ឬផ្តិតម្រាមដៃត្រូវតែអានកំណត់ហេតុឡើងវិញ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំឡេងខ្លាំងៗ នូវខ្លឹមសារកំណត់ហេតុ។ ក្នុងករណីដែលអ្នកឆ្លើយមិនចេះភាសាខ្មែរទេនោះ មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែបាន។ កាលណា បុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតមេដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[43]។

**ខ. ការឃាត់ខ្លួនជនជាប់សង្ស័យ**

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់ នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថាបានចូលរួមក្នុងបទល្មើស។ មន្ត្រីនគរបាលយុត្តិធម៌ ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ពត៌មានស្តីពីរឿងហេតុបានដែរ ប្រសិនបើមានលក្ខខណ្ឌដូចខាងក្រោម៖

-បុគ្គលដែលអាចផ្តល់ពត៌មានប្រកែកមិនព្រមផ្តល់ពត៌មាន

-មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ។

---

[42]-មាត្រា៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[43]-មាត្រា៩៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ខ.១. ថិរវេលា នៃការឃាត់ខ្លួន

ការឃាត់ខ្លួនមានថិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង។ ថិរវេលាត្រូវចាប់គិតពីម៉ោង ដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ប៉ុន្តែចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយ ដែលបង្ហាញឱ្យឃើញថាមានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យាពេលឃាត់ខ្លួនបានប្រសិនបើវិធានការនេះជាការចាំបាច់ ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ។ ការពន្យាត្រូវសុំទៅព្រះរាជអាជ្ញា ដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព។ ការអនុញ្ញាតឱ្យពន្យាពេលឃាត់ខ្លួនត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង។ ការពន្យាគឺជាវិធានការពិសេស ហើយការពន្យានេះមិនអាចឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោងឡើយ ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន។

### ខ.២. វិធាន នៃការឃាត់ខ្លួនអនីតិជន

កាលណា មានការឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនពត៌មានតាមគ្រប់មធ្យោបាយដល់ឪពុក ម្ដាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជន[44]។

ការពន្យាពេលមិនអាចត្រូវបានយល់ព្រមបានទេ ប្រសិនបើ បុគ្គលដែលឃាត់ខ្លួននោះជាអនីតិជន។

វិធានការឃាត់ខ្លួនអនីតិជន គឺមិនដូចគ្នាទៅនឹងការឃាត់ខ្លួននីតិជនឡើយ។ អនីតិជនចែកចេញជាបីប្រភេទដូចខាងក្រោម៖

- **អនីតិជនមានអាយុក្រោម ១៤ ឆ្នាំ**

អនីតិជនមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវបានគេឃាត់ខ្លួនបានឡើយ។

- **អនីតិជនមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ**

-ចំពោះបទឧក្រិដ្ឋ អនីតិជន ដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ។

-ចំពោះបទមជ្ឈិម អនីតិជន ដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ។

- **អនីតិជនមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ**

-ចំពោះបទឧក្រិដ្ឋ អនីតិជន ដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ។

-ចំពោះបទមជ្ឈិម អនីតិជន ដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ មិនអាចត្រូវបានគេឃាត់ខ្លួនហួសពីរយៈពេល ៣៦ ម៉ោងឡើយ[45]។

---

[44]-មាត្រា១០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**ខ.៣. កំណត់ហេតុស្តីពីការឃាត់ខ្លួន**

កាលណា មានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែឱ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនដល់បុគ្គលនោះ ដោយប្រាប់ឱ្យបានដឹងពីមូលហេតុ នៃសេចក្តីសម្រេចឃាត់ខ្លួននេះ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រាប់ដល់សាមីខ្លួនឱ្យបានដឹងផងដែរ អំពីសិទ្ធិដែលបានឱ្យដោយច្បាប់ដូចជា សិទ្ធិមានជំនួយរបស់មេធាវីជាដើម។

ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌អាចហៅរកអ្នកបកប្រែ។ មន្ត្រីនគរបាលយុត្តធម៌ធ្វើកំណត់ហេតុស្តីពីការឃាត់ខ្លួនជាបន្ទាន់ដោយមានចុះសេចក្តីដូចតទៅៈ

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន

-ការឱ្យដំណឹងអំពីសិទ្ធិ(ជំនួយរបស់មេធាវីក្នុងពេលឃាត់ខ្លួន)

-ជាយថាហេតុ ឈ្មោះអ្នកបកប្រែ។

កំណត់ហេតុនេះ ត្រូវមានចុះហត្ថលេខា ឬផ្តិតម្រាមដៃរបស់ជនឃាត់ខ្លួន ក្រោយពីបានអានកំណត់ហេតុរួច ឬបើសាមីខ្លួនមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវអានកំណត់ហេតុឱ្យស្តាប់។ ប្រសិនបើ ជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្តិតម្រាមដៃទេមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស។ កំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង[46]។

ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ អាចសុំជំនួយរបស់គ្រូពេទ្យមកពិនិត្យសុខភាពបុគ្គល ដែលឃាត់ខ្លួនគ្រប់ពេលវេលា ដើម្បីផ្ទៀងផ្ទាត់មើលថា តើស្ថានភាពសុខភាពនៃបុគ្គលឃាត់ខ្លួននេះសមស្របនឹងការឃាត់ខ្លួនដែរឬទេ។

ប្រសិនបើ គ្រូពេទ្យយល់ឃើញថា ស្ថានភាពសុខភាពរបស់បុគ្គលនោះពុំសមស្របជាមួយនឹងការឃាត់ខ្លួនទេនោះ មន្ត្រីនគរបាលយុត្តិធម៌ រាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា។ គ្រូពេទ្យចេញវិញ្ញាបនបត្របញ្ជាក់សុខភាព ដែលត្រូវភ្ជាប់មកជាមួយសំណុំរឿង។ មន្ត្រីនគរបាលយុត្តិធម៌ចុះនិទ្ទេសនៅលើកំណត់ហេតុអំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោង នៃការពិនិត្យសុខភាព។ ព្រះរាជអាជ្ញា អាចចុះទៅកាន់ទីកន្លែងផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌ នៃការឃាត់ខ្លួន[47]។

[45]-មាត្រា៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[46]-មាត្រា៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[47]-មាត្រា៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

នៅក្នុងករណី ដែលមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវតែឱ្យដំណឹងជាបន្ទាន់អំពីសេចក្តីសម្រេចរបស់ខ្លួនដល់បុគ្គល ដែលត្រូវបានឃាត់ខ្លួន។ មន្ត្រីនគរបាលក៏ត្រូវប្រាប់ឱ្យបានដឹងផងដែរ នូវមូលហេតុ នៃសេចក្តីសម្រេចឃាត់ខ្លួននោះ ព្រមទាំងប្រាប់ឱ្យសាមីខ្លួនបានដឹងអំពីសិទ្ធិ ដែលអាចមានមេធាវីនៅពេលឃាត់ខ្លួននោះ ព្រោះនៅក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ ដោយគិតចាប់ផ្តើមពីការឃាត់ខ្លួនមកនោះ បុគ្គលដែលត្រូវបានឃាត់ខ្លួនអាចមានសិទ្ធិសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ ដែលខ្លួនជ្រើសរើសកុំឱ្យតែជននោះមានការទាក់ទងនៅក្នុងរឿងជាមួយ[48]។ ជននេះ ត្រូវបានទទួលដំណឹងពីការស្នើសុំជ្រើសរើសតាមគ្រប់មធ្យោបាយ និងជាបន្ទាន់។ ជននេះ អាចចូលទៅកន្លែងឃាត់ខ្លួន និងទាក់ទងជាមួយសាមីខ្លួនបានក្នុងរយៈពេល៣០នាទី ហើយការសន្ទនានេះ គឺត្រូវបានរក្សានូវការសម្ងាត់។ ក្រោយការសន្ទនារួចជននេះត្រូវធ្វើកំណត់សម្គាល់ដោយត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។

### ខ.៤. បញ្ជី និងកំណត់ហេតុសរុប នៃការឃាត់ខ្លួន

នៅក្នុងកន្លែងនីមួយៗរបស់នគរបាល ឬកងរាជអាវុធហត្ថ ដែលសម្រាប់ទទួលជន ដែលត្រូវឃាត់ខ្លួនត្រូវមានបញ្ជីស្តីពីការឃាត់ខ្លួនមួយ។

គ្រប់ការឃាត់ខ្លួនត្រូវមានចុះនៅក្នុងបញ្ជីដោយមានសេចក្តីដូចតទៅ៖

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យធ្វើការឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្តើមឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួនជាយថាហេតុ

-ឈ្មោះរបស់គ្រូពេទ្យ ដែលបានពិនិត្យបុគ្គលឃាត់ខ្លួនជាយថាហេតុ

-ប្រភេទនៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន។

បញ្ជីនេះត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការតាមត្រូវការ[49]។ ម្យ៉ាងវិញទៀតគ្រប់ការឃាត់ខ្លួនត្រូវតែមានធ្វើកំណត់ហេតុសរុប នៃការឃាត់ខ្លួន។

កំណត់ហេតុសរុបត្រូវមានចុះនិទ្ទេសដូចតទៅ៖

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ ដែលបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គល ដែលត្រូវឃាត់ខ្លួន

[48]-មាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[49]-មាត្រា១០១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

-មូលហេតុ នៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោង ដែលផ្តើមការឃាត់ខ្លួន

-បែបបទ នៃការជូនដំណឹង ( អនីតិជនដែលត្រូវបានឃាត់ខ្លួន)

-ឈ្មោះគ្រូពេទ្យ ដែលបានពិនិត្យបុគ្គលឃាត់ខ្លួន

-អត្តសញ្ញាណរបស់ជនដែលបានសន្ទនាជាមួយបុគ្គលឃាត់ខ្លួន (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន)

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលជាយថាហេតុបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន

-ថិរវេលា នៃការស្តាប់ចម្លើយនីមួយៗ នៃការសម្រាក ដែលនៅចន្លោះការស្តាប់ចម្លើយនីមួយៗ។

-ថ្ងៃ ខែ ឆ្នាំ និងម៉ោង នៃការឃាត់ខ្លួន

-ប្រភេទ នៃសេចក្តីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលបញ្ចប់ការឃាត់ខ្លួន

-លក្ខខណ្ឌ នៃការប្រព្រឹត្តទៅ នៃការឃាត់ខ្លួន ព្រមទាំងឧប្បត្តិហេតុជាយថាហេតុ។

កំណត់ហេតុសរុប នៃការឃាត់ខ្លួនត្រូវភ្ជាប់ជាមួយសំណុំរឿង[50]។

**ច. ថិរវេលា នៃការស៊ើបអង្កេតជាក់ស្តែង**

ថិរវេលា នៃការស៊ើបអង្កេតបទល្មើសជាក់ស្តែង មិនអាចលើសពី ៧ (ប្រាំពីរ) ថ្ងៃ គិតចាប់ពីថ្ងៃប្រព្រឹត្តបទល្មើស។ កិច្ចស៊ើបអង្កេតត្រូវប្រព្រឹត្តទៅជាប់ជានិច្ចនៅក្នុងថិរវេលានេះ។

ប្រសិនបើ ការស៊ើបអង្កេតមិនបានបញ្ចប់ក្នុងរយៈពេល៧ថ្ងៃទេនោះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំយោបល់ពីព្រះរាជអាជ្ញា[51]។

**ឆ. ការបញ្ជូនខ្លួន**

នៅពេលផុតកំណត់ នៃរយៈពេល នៃការឃាត់ខ្លួនបុគ្គល ដែលត្រូវបានឃាត់ខ្លួននោះ ត្រូវបញ្ជូនខ្លួនទៅព្រះរាជអាជ្ញា ឬដោះលែងឱ្យមានសេរីភាពឡើងវិញ។ សេចក្តីសម្រេចនេះ ធ្វើឡើងដោយព្រះរាជអាជ្ញា។

កាលណា បុគ្គលដែលឃាត់ខ្លួន ត្រូវបញ្ជូនទៅព្រះរាជអាជ្ញានោះ បុគ្គលនេះត្រូវបានគេនាំខ្លួនភ្លាមយកទៅចំពោះមុខព្រះរាជអាជ្ញា។

ប្រសិនបើ ការបង្ហាញខ្លួនបុគ្គល ដែលត្រូវបានឃាត់ខ្លួនពុំអាចធ្វើឡើងនៅថ្ងៃតែមួយបានដោយសារមានមូលហេតុពិសេស ដែលបណ្តាលមកពីការលំបាកក្នុងការដឹកជញ្ជូន ឬចម្ងាយផ្លូវ នៃការដឹកជញ្ជូននោះ រយៈពេលបន្ថែមអាចផ្តល់ឱ្យដោយព្រះរាជអាជ្ញាបាន។

---

[50]-មាត្រា១០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[51]-មាត្រា១០៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

នៅក្នុងគ្រប់ករណីទាំងអស់ ការបង្ហាញខ្លួនបុគ្គល ដែលត្រូវបានឃាត់ខ្លួនត្រូវធ្វើឡើងនៅក្នុងរយៈពេលដ៏ឆាប់បំផុតតាមការដែលអាចធ្វើទៅបាន។

មូលហេតុ នៃការឃើតឃាំងត្រូវចុះក្នុងកំណត់ហេតុ ដែលត្រូវប្រគល់ជូនព្រះរាជអាជ្ញាដោយមន្ត្រីនគរបាលយុត្តិធម៌[52]។

**ង. ការបញ្ជូនកំណត់ហេតុទៅព្រះរាជអាជ្ញា**

ក្រោយពេលបញ្ចប់ការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌បញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា។

កាលណា បុគ្គលណាមួយត្រូវបញ្ជូនទៅព្រះរាជអាជ្ញានោះ ការបញ្ជូនកំណត់ហេតុ និងវត្ថុតាង ត្រូវធ្វើជាមួយការបញ្ជូនខ្លួនបុគ្គលនោះដែរ[53]។ មានន័យថា នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្រាវជ្រាវ ប្រមូលភស្តុតាង និងធ្វើកំណត់ហេតុកសាងសំណុំរឿងចប់សព្វគ្រប់ហើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនកំណត់ហេតុ វត្ថុតាង និងជនសង្ស័យទៅព្រះរាជអាជ្ញា ដើម្បីឱ្យព្រះរាជអាជ្ញាធ្វើការពិនិត្យទៅលើសំណុំរឿងនោះ និងធ្វើចំណាត់ការបន្ត។ ព្រោះថា ព្រះរាជអាជ្ញាគឺជាម្ចាស់បណ្តឹងអាជ្ញា និងជាតួអង្គដែលមានសិទ្ធិ អំណាចក្នុងការធ្វើចំណាត់ការលើសំណុំរឿង។

[52]-មាត្រា១០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[53]-មាត្រា១០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# ជំពូកទី២

# ដំណាក់កាលធ្វើចំណាត់ការលើសំណុំរឿង

## ២.១.តួនាទី និងសិទ្ធិ អំណាចរបស់អង្គការអយ្យការ

អង្គការអយ្យការ គឺជាតំណាងឱ្យសង្គម តំណាងឱ្យផលប្រយោជន៍ទូទៅ ជាម្ចាស់បណ្ដឹងអាជ្ញា និងជាភាគីនៅក្នុងរឿងព្រហ្មទណ្ឌ។ នៅក្នុងមាត្រា ២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា អង្គការអយ្យការធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យតុលាការអនុវត្តច្បាប់។ អង្គការអយ្យការធានារ៉ាប់រង ចំពោះការអនុវត្តសេចក្ដីសម្រេចខាងបទល្មើសព្រហ្មទណ្ឌ ព្រមទាំងធានាយកចិត្តទុកដាក់ទៅលើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។ នៅក្នុងការបំពេញនូវភារៈកិច្ចរបស់ខ្លួន ចៅក្រមអយ្យការ មានសិទ្ធិកេណ្ឌកងកម្លាំងសាធារណៈដោយផ្ទាល់ ជាជំនួយរបស់ខ្លួន នៅក្នុងការបំពេញមុខងាររបស់ខ្លួនក៏ដូចជានីតិវិធីតុលាការចំពោះចំណាត់ការក្នុងសំណុំរឿង។

### ២.១.១. ការធ្វើចំណាត់ការលើសំណុំរឿង

ជាគោលការណ៍ ក្រោយពេលដែលបានទទួលនូវពត៌មានទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌណាមួយនោះ នៅមុនពេលធ្វើចំណាត់ការនៅលើសំណុំរឿងដែលទទួលបាននោះ ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការស៊ើបអង្កេតស្រាវជ្រាវស្វែងរកបទល្មើស និងស្វែងរកពត៌មានបន្ថែមទៀត ដើម្បីអាចជាមូលដ្ឋានដ៏សំខាន់មួយសម្រាប់វាយតម្លៃ ព្រមទាំងធ្វើការថ្លឹងថ្លែងដោយកំណត់ចំណាំនៅលើសំណុំរឿងនោះឱ្យបានច្បាស់លាស់ មុននឹងធ្វើការចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ។

#### ២.១.១.១. គោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់

ព្រះរាជអាជ្ញាធ្វើការថ្លឹងថ្លែងអំពីចំណាត់ការនៅលើពាក្យបណ្ដឹងផ្សេងៗ ដែលខ្លួនបានទទួលដោយផ្ទាល់ ឬតាមរយៈមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក។ ព្រះរាជអាជ្ញា អាចធ្វើការសម្រេចចិត្តដោយត្រូវតម្កល់រឿងទុកឥតចាត់ការ ប្រសិនបើ ខ្លួនយល់ឃើញថាករណីនោះមិនមាននូវធាតុផ្សំបទល្មើសគ្រប់គ្រាន់ ដើម្បីធ្វើការចោទប្រកាន់ទេ ឬអាចធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌណាមួយ ក្នុងករណីដែលខ្លួនយល់ឃើញថាបទល្មើសនោះគឺមានធាតុផ្សំគ្រប់គ្រាន់ដែលអាចធ្វើការចោទប្រកាន់ទៅលើជនដែលប្រព្រឹត្តអំពើល្មើសនោះបាន[54]។

គោលការណ៍នៅចំណុចនេះបានបង្ហាញពីការកំណត់នូវកាលានុវត្តភាព នៃការចោទប្រកាន់ ដែលតាមរយៈគោលការណ៍នេះបានផ្ដល់សិទ្ធិឱ្យព្រះរាជអាជ្ញានូវសេរីភាព និងឆន្ទានុសិទ្ធិ នៅក្នុង

[54]-មាត្រា៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ការចោទប្រកាន់ ដោយផ្អែកទៅលើទម្ងន់ទោស និងមូលហេតុផ្សេងៗ ដែលអាចធ្វើជាធាតុផ្សំដទៃទៀតដូចជា កាលៈទេសៈនៃការប្រព្រឹត្ត និងភាពរីករាលដល់សណ្តាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយនៅក្នុងសង្គម និងធាតុដទៃទៀត ដែលអាចប្រមូលបាននៅក្នុងការស៊ើបអង្កេត។ ហេតុដូចនេះ វិធានត្រូវបានអនុវត្តនៅក្នុងប្រទេសមួយចំនួន ដែលទាមទារឱ្យព្រះរាជអាជ្ញាសម្រេចធ្វើការចោទប្រកាន់នៅរាល់ពេលដែលខ្លួនដឹងថាមានបទល្មើស។

ម៉្យាងទៀត គោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់នេះ ក៏បានផ្តល់សិទ្ធិដោយអនុញ្ញាតឱ្យព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការបានដែរ បើទោះបីជាអំពើដែលបរិហារនោះជាបទល្មើសក៏ដោយ ព្រោះគ្មានមូលហេតុគ្រប់គ្រាន់ ដែលអាចទុកជាធាតុផ្សំបទល្មើសបាន[55]។

## ២.២. ការអនុវត្តគោលការណ៍កាលានុវត្តភាព នៃការចោទប្រកាន់

### ២.២.១.ការតម្កល់រឿងទុកឥតចាត់ការ

កាលណា បណ្តឹងមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវជូនដំណឹងដល់អ្នកប្តឹង អំពីសេចក្តីសម្រេចរបស់ខ្លួន នៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុតរយៈពេល ២ (ពីរ) ខែ គិតពីថ្ងៃចុះពាក្យបណ្តឹងនៅក្នុងបញ្ជីបណ្តឹង ដែលបញ្ជីបណ្តឹងនោះ គឺមាននៅតាមតុលាការជាន់ដំបូងនីមួយៗ ដែលត្រូវបានបង្កើតឱ្យមានបញ្ជីអយ្យការមួយសម្រាប់ចុះបណ្តឹង ដែលប្តឹងដោយផ្ទាល់ ដល់ព្រះរាជអាជ្ញា ឬដែលបញ្ជូនមកតាមរយៈមន្ត្រីនគរបាលយុត្តិធម៌[56]។

យោងតាមគោលការណ៍កាលានុវត្តភាព នៃបណ្តឹងអាជ្ញា បានអនុញ្ញាតឱ្យព្រះរាជអាជ្ញាអាចតម្កល់រឿងទុកឥតចាត់ការបាន ទោះបីអំពើដែលបានប្តឹង ឬបរិហារមកនោះជាបទល្មើសព្រហ្មទណ្ឌក៏ដោយប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថាអំពើនោះមិនមានភាពរីករាលដល់សង្គម ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈធ្ងន់ធ្ងរ ឬការប្រព្រឹត្ត នៅក្នុងកាលៈទេសៈពិសេសណាមួយ ដែលគួរតែអនុគ្រោះបាន។

#### ២.២.១.១. មូលហេតុ នៃការតម្កល់រឿងទុកឥតចាត់ការ

មូលហេតុនៃការតម្កល់រឿងទុកឥតចាត់ការមានច្រើន ប៉ុន្តែមិនបានធ្វើការកំណត់ជាក់លាក់ដោយច្បាប់ទេ តែយើងអាចផ្អែកទៅលើស្មារតី នៃក្រមនីតិវិធីព្រហ្មទណ្ឌបាន។

ខាងក្រោមនេះជាមូលហេតុមួយចំនួន នៃការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាមានដូចជា៖

-ការមិនអាចកំណត់អត្តសញ្ញាណរបស់ចារី ឬពុំមានបន្ទុកគ្រប់គ្រាន់ដើម្បីបង្ហាញពី

[55]-សៀវភៅនីតិវិធីព្រហ្មទណ្ឌ របស់អនុបណ្ឌិត អៀង សំណាង បោះពុម្ពឆ្នាំ២០១៥ ទំព័រ៦៩

[56]- មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ពិរុទ្ធភាពរបស់ចារី ហើយការស្រាវជ្រាវបន្ថែមដោយនគរបាលយុត្តិធម៌ ហាក់បីដូចជាមិនទទួលបានផល ឬគ្មានប្រយោជន៍ ដើម្បីទទួលបាននូវធាតុផ្សំផ្សេងៗទៀត ដែលជាមូលហេតុចម្បង នៃការចោទប្រកាន់។

-អំពើដែលបង្ហាញមកនោះមិនបង្កើតបានជាបទល្មើសព្រហ្មទណ្ឌ។

-បទល្មើសមិនមានលក្ខណៈគ្រប់គ្រាន់ ដូចជាធាតុផ្សំ នៃសំណុំរឿងមិនអនុញ្ញាតឱ្យកំណត់អំពីធាតុផ្សំ នៃបទល្មើស ឬមានមូលហេតុមកពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌ (អនីតិជនអាយុក្រោម ១៤ ឆ្នាំ ការបញ្ជារបស់ច្បាប់ ឬអាជ្ញាធរធម្មានុរូបភាព ការការពារខ្លួនស្របច្បាប់ និងស្ថានភាពចាំបាច់)។

-ការរលត់បណ្តឹងអាជ្ញាជាដើម។

ជាចុងក្រោយ និងជាចំណុចបង្ហាញពីគោលការណ៍កាលានុវត្តភាពការចោទប្រកាន់ គឺការតម្កល់រឿងទុកឥតចាត់ការ ទោះបីជាបទល្មើសនោះ អ្នកដែលបានប្រព្រឹត្តល្មើសត្រូវបានគេស្គាល់មុខក៏ដោយ ប៉ុន្តែព្រះរាជអាជ្ញាយល់ឃើញថា ការតម្កល់រឿងទុកឥតចាត់ការនេះមានលក្ខណៈត្រឹមត្រូវតាមកាលៈទេសៈដើម្បីជាផលប្រយោជន៍ទូទៅ ព្រោះថាព្យសនកម្ម ដែលកើតមានដោយសារបទល្មើសនោះមានតម្លៃតិចតួចពេក ឬហេតុផលមួយទៀតដូចជា ភាពរឹករវដល់សណ្តាប់ធ្នាប់សាធារណៈ គឺមានលក្ខណៈមិនធ្ងន់ធ្ងរ ឬជនល្មើសបានប្រព្រឹត្តបទល្មើសជាលើកដំបូង ដែលទំហំនៃព្យសនកម្មមានតិចតួច ហើយជនល្មើសបានជួលជុល នូវការខូចខាតឱ្យដល់ជនរងគ្រោះបានរួចរាល់ជាដើម[57]។

### ២.២.១.២. នីតិវិធី នៃការតម្កល់រឿងទុកឥតចាត់ការ

#### ក. ការជូនដំណឹង

កាលណា បណ្តឹងមួយត្រូវបានតម្កល់ទុកឥតចាត់ការ ព្រះរាជអាជ្ញាត្រូវឱ្យដំណឹងដល់អ្នកប្តឹង អំពីសេចក្តីសម្រេចរបស់ខ្លួននៅក្នុងរយៈពេលយ៉ាងខ្លីបំផុត ហើយយ៉ាងយូរបំផុត ២ (ពីរ) ខែគិតពី ថ្ងៃចុះពាក្យប្តឹងក្នុងបញ្ជី។

#### ខ. ការប្តឹងតវ៉ា និងរយៈពេល នៃការប្តឹងតវ៉ា

ការតម្កល់រឿងទុកឥតចាត់ការត្រូវតែមានសំអាងច្បាប់ និងសំអាងហេតុ។ ការតម្កល់រឿងទុកឥតចាត់ការនេះគ្មានអាជ្ញាអស់ជំនុំទេ។

ព្រះរាជអាជ្ញាអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនវិញ ក្នុងខណៈដែលបណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ។

---

[57]-សៀវភៅនីតិវិធីព្រហ្មទណ្ឌ របស់អនុបណ្ឌិត អៀង សំណាង បោះពុម្ពឆ្នាំ២០១៥ ទំព័រ៧០

ប្រសិនបើ អ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការទេ សាមីខ្លួនអាចធ្វើការតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍បាន។

ការតវ៉ា គឺមានរយៈពេល ២ (ពីរ) ខែ គិតចាប់ពីថ្ងៃទទួលដំណឹងអំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ការតវ៉ានេះ ត្រូវធ្វើតាមបណ្តឹងសមញ្ញនៅអង្គការអយ្យការ ដែលពាក់ព័ន្ធ។ បន្ទាប់មក សំណុំរឿងត្រូវបានបញ្ជូនភ្លាមៗទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដោយតំណាងអយ្យការអមសាលាដំបូង។

ប្រសិនបើ យល់ឃើញថា ការតវ៉ានេះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ចេញអធិបញ្ជាដល់ព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធ្វើអធិបញ្ជាតាមការណែនាំជាលាយលក្ខណ៍អក្សរ។ ប្រសិនបើ ករណីដែលអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថាការកម្កល់រឿងទុកឥតចាត់ការនោះមានមូលហេតុត្រឹមត្រូវនោះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការ ។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ត្រូវឱ្យដំណឹងអំពីសេចក្តីសម្រេចនេះដល់អ្នកតវ៉ា[58]។

ក្នុងករណី ដែលពាក្យប្តឹងស្ថិតនៅដោយគ្មានចម្លើយ ឬត្រូវបានតម្កល់ទុកឥតចាត់ការដោយព្រះរាជអាជ្ញា ជនរងគ្រោះអាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍តាមនីតិវិធីដូចបានរៀបរាប់ខាងលើ[59]។

### ២.២.២. ការសម្រេចចោទប្រកាន់

ការចោទប្រកាន់ខាងបទព្រហ្មទណ្ឌអាចធ្វើតាមរយៈ៖

-ការបើកការស៊ើបសួរ

-នីតិវិធីបង្ហាញខ្លួនភ្លាម ឬ

-តាមនីតិវិធីបង្គាប់ឱ្យចូលខ្លួនភ្លាម[60]។

#### ២.២.២.១. ការបើកការស៊ើបសួរ

ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ។

ការបើកការស៊ើបសួរត្រូវបានបើកតាមដីកាបញ្ជូនរឿងឱ្យស៊ើបសួរ ដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ការបើកការស៊ើបសួរ អាចប្រឆាំងលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន (ជនដែលគេមិនស្គាល់អត្តសញ្ញាណ)។

---

[58]- មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[59]- មាត្រា៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[60]- មាត្រា៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន៖

-សេចក្តីសង្ខេប នៃអង្គហេតុ

-ការកំណត់ឈ្មោះបទល្មើស

-ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស និង

-ឈ្មោះបុគ្គល ដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។

ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេដីកាបញ្ជូនរឿងឱ្យស៊ើបសួរនេះត្រូវទុកជាមោឃៈ[61]។

ខ្លឹមសារ នៃចំណុចខាងលើនេះ មានន័យថា ក្នុងករណីបទឧក្រិដ្ឋ ព្រះរាជអាជ្ញាដាច់ខាតត្រូវតែបើកការស៊ើបសួរ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅដល់ចៅក្រមស៊ើបសួរដែលតាមរយៈដីកានេះ បានបើកសិទ្ធិឱ្យដល់ចៅក្រមស៊ើបសួរមានសិទ្ធិបើកការស៊ើបសួរបាន។ ចំពោះបទមជ្ឈិម ព្រះរាជអាជ្ញាក៏អាចបើកការស៊ើបសួរបានដែរ ប្រសិនបើ មូលហេតុមួយចំនួនដូចខាងក្រោមត្រូវបានបំពេញមានដូចជា៖

-អត្តសញ្ញាណរបស់ចារីមិនត្រូវបានគេស្គាល់

-សំណុំរឿងមិនទាន់មូលសព្វគ្រប់ ដោយភស្តុតាង ដែលប្រមូលបានពុំទាន់មានលក្ខណៈគ្រប់គ្រាន់។

-បទមជ្ឈិម ដែលត្រូវបានចោទប្រកាន់នោះ គឺមានលក្ខណៈស្មុគស្មាញពិបាកនឹងដោះស្រាយ ឬជនល្មើសមានគ្នាច្រើន ដែលបានប្រព្រឹត្តបទល្មើស។

ការបើកការស៊ើបសួរ ត្រូវបានធ្វើឡើង ទៅតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដែលត្រូវប្តឹងទៅចៅក្រមស៊ើបសួរ។ ដីកានេះ គឺជានីតិវិធីដែលមានសារៈសំខាន់បំផុត ដែលផ្តល់ឱ្យចៅក្រមស៊ើបសួរនូវសមត្ថកិច្ចដើម្បីប្រើប្រាស់ទាំងអស់ដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ[62]។

ទម្រង់ នៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរមាន៖

-សេចក្តីសង្ខេប នៃអង្គហេតុ

-ការកំណត់ឈ្មោះបទល្មើស

-ការបង្ហាញនូវអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

-ឈ្មោះ ឬក៏អត្តសញ្ញាណរបស់បុគ្គល ដែលត្រូវរងការស៊ើបសួរ

[61]- មាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[62]- មាត្រា៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

-កាលបរិច្ឆេទ និងហត្ថលេខារបស់តំណាងអយ្យការ។

ក្រោយពីបានទទួលនូវពាក្យបណ្តឹងហើយ បើព្រះរាជអាជ្ញាយល់ឃើញថា អំពើដែលគេប្តឹងមកនោះមាននូវមូលដ្ឋានគ្រប់គ្រាន់អាចចោទប្រកាន់បាន ព្រះរាជអាជ្ញានឹងធ្វើការចោទប្រកាន់ដើម្បី បើកការស៊ើបសួរទៅតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ការបើកការស៊ើបសួរគឺជាការប្តឹង ទៅចៅក្រមស៊ើបសួរឱ្យធ្វើការស៊ើបសួរទៅលើអង្គហេតុណាមួយ ប្រឆាំងទៅលើបុគ្គលម្នាក់ ឬច្រើននាក់ ដោយមានចង្អុលបង្ហាញប្រាប់នូវឈ្មោះ ឬប្រឆាំងទៅលើជន ដែលគេមិនស្គាល់ពីអត្តសញ្ញាណ ដែលហៅថាអញ្ញាតជននោះបានដែរ។

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាការបញ្ជាក់ពីការផ្តល់សមត្ថកិច្ចការងារជូនដល់ចៅក្រមស៊ើបសួរ ដែលនៅក្នុងពេលនេះចៅក្រមស៊ើបសួរមានសិទ្ធិអំណាចយ៉ាងធំធេង នៅក្នុងចំណាត់ការដោះស្រាយរឿងក្តីព្រហ្មទណ្ឌ ដោយធ្វើការស៊ើបសួរស្វែងរកទាំងភស្តុតាងដាក់បន្ទុក និងទាំងភស្តុតាងដោះបន្ទុកទៅលើជនល្មើស នៅក្នុងគោលដៅស្វែងរកឱ្យឃើញការពិតនៃរឿង។

### ២.២.២.២. ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធី នៃការសម្រេចធ្វើការចោទប្រកាន់ ដោយព្រះរាជអាជ្ញា។

ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជានីតិវិធីមួយ ដែលអាចយកទៅអនុវត្តបានចំពោះបទមជ្ឈិមតូចតាច និងគ្រប់បទលហុ ហើយសំណុំរឿងនេះមានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបាន។

ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ត្រូវបានធ្វើឡើងតាមរយៈដីកាមួយ ដែលមានឈ្មោះថាដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។ ដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាឱ្យជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង។ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមាន៖

-អត្តសញ្ញាណ នៃជនជាប់ចោទ

-សេចក្តីសង្ខេប នៃអង្គហេតុ

-ឈ្មោះបទល្មើស

-អត្ថបទច្បាប់ ដែលកំណត់ និងបង្ក្រាបបទល្មើស។

ដីកានេះត្រូវចង្អុលប្រាប់ពីតុលាការ ព្រមទាំងទីកន្លែងកាលបរិច្ឆេទ និងម៉ោងរយៈពេល នៃសវនការ។ ដីកានេះ ត្រូវបញ្ជាក់ថាជនជាប់ចោទអាចពឹងមេធាវីការពារខ្លួនបាន[63]។

[63]- មាត្រា៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ២.២.២.៣. នីតិវិធីបង្ហាញខ្លួនភ្លាម

ព្រះរាជអាជ្ញា អាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាម នៅមុខតុលាការជាន់ដំបូង ប្រសិនបើមានគ្រប់លក្ខខណ្ឌដូចតទៅ៖

-បទល្មើស ជាបទល្មើសជាក់ស្តែងតាមអត្ថន័យ នៃមាត្រា៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) និងមាត្រា៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះ។

-បទល្មើសត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ ឆ្នាំ និងយ៉ាងច្រើន ៥ ឆ្នាំ

-ជនជាប់ចោទជានីតិជន

-រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន[64]។

កាលណា សម្រេចថាត្រូវប្រើនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមព្រះរាជអាជ្ញាត្រូវតែ៖

-ពិនិត្យអត្តសញ្ញាណបុគ្គល ដែលគេបញ្ជូនមកឱ្យខ្លួន

-ឱ្យដំណឹងដល់ជននោះ អំពីរឿងរ៉ាវ ដែលចោទប្រកាន់ និងឈ្មោះបទល្មើស

-ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើ សាមីខ្លួនចង់និយាយ

-ធ្វើកំណត់ហេតុ ស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។

ព្រះរាជអាជ្ញា ប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិសុំពឹងមេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

មេធាវីជ្រើសរើស ឬចាត់តាំង ត្រូវបានទទួលដំណឹងភ្លាម។ មេធាវី អាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទបាន។

និទ្ទេស នៃទម្រង់ការទាំងនេះ ត្រូវចុះនៅក្នុងកំណត់ហេតុ បើពុំដូចច្នោះទេ នីតិវិធីត្រូវទុកជាមោឃៈ។

តុលាការជាន់ដំបូង ត្រូវបានទទួលបណ្តឹងតាមកំណត់ហេតុ ស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។ ជនជាប់ចោទ ត្រូវបង្ខាំងទុកដោយមានកម្លាំងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ដែលត្រូវបើកសវនការនៅក្នុងថ្ងៃនោះតែម្តង។

នៅពេលបង្ហាញខ្លួននេះ តុលាការក្រោយពីបានផ្ទៀងផ្ទាត់មើលអត្តសញ្ញាណរបស់ជនជាប់ចោទ និងធ្វើរបាយការណ៍សង្ខេបរឿងរ៉ាវ ដែលបានចោទប្រកាន់ ត្រូវប្រាប់ដល់ជនជាប់ចោទថាសាមីខ្លួនអាចមានរយៈពេល ដើម្បីរៀបចំការពារខ្លួន។

ប្រសិនបើ ជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងក្តីនោះមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេនោះ សំណុំរឿងត្រូវលើកទៅពេលសវនការក្រោយ។

[64]- មាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ក្នុងករណីនេះដែរ តុលាការអាចបង្គាប់ឱ្យឃុំខ្លួនជនជាប់ចោទជាបណ្ដោះអាសន្ន ដោយសាលក្រម ដែលមានបញ្ជាក់ពីសំអាងហេតុ។ ចំណែកឯ ខ្លឹមសារនៅក្នុងសាលក្រមនោះ តុលាការត្រូវយោងតាមលក្ខខណ្ឌ នៃមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបញ្ញត្តិអំពីមូលហេតុ នៃការឃុំខ្លួនបណ្ដោះអាសន្ន។

សាលក្រមលើសេចក្តី នៃនិតិវិធីបង្គាប់ឱ្យចូលខ្លួននេះ ត្រូវតែប្រកាសនៅក្នុងរយៈពេលដែលមិនអាចលើសពី ២ សប្ដាហ៍ ដោយគិតពីថ្ងៃចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការ។

ផ្ទុយទៅវិញ ប្រសិនបើតុលាការដែលបានទទួលបណ្ដឹងតាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម យល់ឃើញថា លក្ខខណ្ឌ នៃការបង្ហាញខ្លួនភ្លាម ដែលមានចែងនៅក្នុងមាត្រា ៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌមិនត្រូវបានបំពេញទេ ឬដោយសារមានភាពស្មុគស្មាញ នៃសំណុំរឿង ដែលតម្រូវឱ្យធ្វើការស្រាវជ្រាវបន្ថែមនោះ តុលាការត្រូវបញ្ជូនសំណុំរឿងនោះទៅព្រះរាជអាជ្ញាដើម្បី បើកការស៊ើបសួរតាមរយៈ***ដីកាសន្និដ្ឋានរឿងឱ្យស៊ើបសួរ*** ទៅចៅក្រមស៊ើបសួរ។

ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តង នៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នេះទេ ជានជាប់ចោទត្រូវតែដោះលែងឱ្យមាននូវសេរីភាពវិញដោយឯកឯង[65]។

[65]- មាត្រា៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# ជំពូកទី៣
# ដំណាក់កាល នៃការស៊ើបសួរ

## ៣.១. តួនាទី និងសិទ្ធិអំណាចរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ គឺជាចៅក្រមអសនៈ ដែលបំពេញមុខងារស៊ើបសួរនៅសាលាដំបូង។ ចៅក្រមស៊ើបសួរមានតួនាទីស្រាវជ្រាវ ដើម្បីបង្ហាញការពិត នៃរឿងតាមរយៈការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុក[66]។

ជាគោលការណ៍ ការស៊ើបសួរគឺត្រូវបានធ្វើឡើងដោយចៅក្រមស៊ើបសួរ នៃ***មន្ទីរស៊ើបសួរ*** នៃតុលាការជាន់ដំបូង។

មន្ទីរស៊ើបសួរ គឺជាយុត្តាធិការ នៃសាលាដំបូង ដែលមានសិទ្ធិអំណាចស៊ើបសួរនៅគ្រប់រឿងក្តីទាំងឡាយ ដែលបានធ្វើការប្តឹងចោទបើកឱ្យមានការស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងរបស់ព្រះរាជអាជ្ញា។ ហើយមន្ទីរស៊ើបសួរនេះ ត្រូវបានចាត់តាំងដោយប្រធានតុលាការសាលាដំបូង ដែលជ្រើសរើសនូវចៅក្រមមួយរូបក្នុងចំណោមចៅក្រមអសនៈ នៃសាលាដំបូងនោះ។

ក្នុងករណីដែលចៅក្រមស៊ើបសួរណាម្នាក់ពុំអាចបំពេញមុខងាររបស់ខ្លួនបានទេ ដោយសារការឈប់សម្រាកព្យាបាលជម្ងឺ ឬដោយមានមូលហេតុដទៃទៀត ចៅក្រមស៊ើបសួរផ្សេងទៀត នៃតុលាការដដែលត្រូវបានចាត់តាំងជាបណ្តោះអាសន្ន ដោយប្រធានតុលាការ ដើម្បីបំពេញមុខងារស៊ើបសួរ។

ក្នុងករណី ពុំមានចៅក្រមស៊ើបសួរទេ ចៅក្រមផ្សេងទៀត នៃតុលាការដដែលអាចត្រូវបានចាត់តាំងជាបណ្តោះអាសន្ន ដោយប្រធានតុលាការ ដើម្បីបំពេញមុខងារស៊ើបសួរ[67]។

ជនរងគ្រោះ នៃបទឧក្រិដ្ឋ ឬបទមជ្ឈិម អាចដាក់ពាក្យប្តឹងជូនចៅក្រមស៊ើបសួរដែលមានសមត្ថកិច្ច ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីដាក់ឱ្យដំណើរការនូវបណ្តឹងអាជ្ញា។ ពាក្យប្តឹង អាចក្នុងនាមជាជនរងគ្រោះដោយមេធាវី[68]។

កាលណា ប្រធានតុលាការធ្វើសេចក្តីសម្រេច ដោយជ្រើសតាំងចៅក្រមរូបណាមួយឱ្យបំពេញកិច្ចស៊ើបសួរនូវរឿងក្តីណាមួយនោះ សេចក្តីសម្រេចនេះ គឺបិទផ្លូវតវ៉ា មានន័យថា មិនអាចប្តឹងជំទាស់បានឡើយ។ ជាមួយគ្នានេះដែរ ចៅក្រមរូបណាមួយ ដែលទទួលបន្ទុកធ្វើការស៊ើបសួរនូវរឿងក្តីណាមួយនោះ ចៅក្រមស៊ើបសួររូបនោះមិនអាចធ្វើជាចៅក្រមជំនុំជម្រះនូវរឿងក្តី ដែលខ្លួនបានស៊ើបសួរនោះទេ[69]។

---

[66]- មាត្រា១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[67]- មាត្រា៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[68]- មាត្រា១៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[69]- មាត្រា៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៣.១.១.ការបើកការស៊ើបសួរ

ការស៊ើបសួរ ត្រូវបានបើកតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា។ ក្នុងន័យនេះ បានបង្ហាញពីការស៊ើបសួរអាចត្រូវបានបើកប្រឆាំងនឹងបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន។

នៅពេល ដែលចៅក្រមស៊ើបសួរទទួលបណ្តឹងអំពីអង្គហេតុ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាហើយនោះ ចៅក្រមស៊ើបសួរត្រូវសួរតែអំពីអង្គហេតុដែល មានតែប៉ុណ្ណោះ។ ប្រសិនបើ លេចចេញអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌនៅក្នុងពេលស៊ើបសួរ ចៅក្រមស៊ើបសួរត្រូវជូនពត៌មានអំពីអង្គហេតុនេះ ទៅព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញាអាចប្តឹង សុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ តែបើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាច ស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។ ប៉ុន្តែ ចៅក្រមស៊ើបសួរមិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿង ឱ្យស៊ើបសួរបន្ថែមទេ ប្រសិនបើ អង្គហេតុថ្មីនោះជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលចែងនៅ ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូង[70]។

<u>**ឧទាហរណ៍:**</u> ប្រសិនបើ ព្រះរាជអាជ្ញាបានធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក្នុងករណីបទល្មើសមនុស្សឃាតដោយអចេតនា ដូចនេះ ចៅក្រមស៊ើបសួរមានសិទ្ធិស៊ើបត្រឹមតែជុំវិញបញ្ហាបទល្មើសមនុស្សឃាតដោយអចេតនាតែប៉ុណ្ណោះ មិនអាចធ្វើការស៊ើបសួររកបទល្មើសផ្សេងទៀតទេ។

ដីកាបញ្ជូនរឿងឱ្យស៊ើបសួររួមមាន៖

-សេចក្តីសង្ខេបអង្គហេតុ

-ការកំណត់ឈ្មោះបទល្មើស

-ការបង្ហាញអត្ថបទច្បាប់ ដែលកំណត់ និងបង្ក្រាបបទល្មើស និង

-ឈ្មោះបុគ្គល ដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន។

ដីការបញ្ជូនរឿងឱ្យស៊ើបសួរត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខា។

ទម្រង់ការនេះមានលក្ខណៈដាច់ខាតត្រូវតែគោរព បើពុំដូច្នេះទេដីកាបញ្ជូនរឿងឱ្យស៊ើបសួរនឹងត្រូវទុកជាមោឃៈ[71]។

---

[70]- មាត្រា១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[71]- មាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៣.១.២. វិធានការនិរន្តរាយ

ចៅក្រមស៊ើបសួរ អាចកោះអញ្ជើញ ឬស្វែងរកបុគ្គល ដែលមិនព្រមឆ្លើយតបតាមការកោះហៅដោយប្រើប្រាស់អំណាចចេញដីកា ៤ ប្រភេទគឺ ដីកាបង្គាប់ឱ្យចូលខ្លួន ដីកាបង្គាប់ឱ្យនាំខ្លួន ដីកាបង្គាប់ឱ្យចាប់ខ្លួន និងដីកាបង្គាប់ឱ្យឃុំខ្លួន។

#### ៣.១.២.១. ដីកាបង្គាប់ឱ្យចូលខ្លួន

ចៅក្រមស៊ើបសួរ មានអំណាចចេញដីកាបង្គាប់ឱ្យចូលខ្លួន។ ដីកាបង្គាប់ឱ្យចូលខ្លួន គឺជាដីកាបញ្ជាដល់ជនណាម្នាក់ឱ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឱ្យចូលខ្លួន អាចចេញទៅលើជនត្រូវចោទ ឬទៅលើជនណាម្នាក់ ដែលមានតម្រុយពិរុទ្ធភាព[72]។

ដីកាបង្គាប់ឱ្យចូលខ្លួននេះមាននិទ្ទេសដូចខាងក្រោមៈ

-អត្តសញ្ញាណ នៃបុគ្គលដែលពាក់ព័ន្ធ

-បទល្មើស ដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

-ថ្ងៃ ខែ ម៉ោងនិងទីកន្លែង ដែលត្រូវចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើប

-ឈ្មោះ និងឋានៈរបស់ចៅក្រម ដែលចេញដីកា។

ដីកានេះត្រូវមានចុះកាលបរិច្ឆេទ និងចុះត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ[73]។

ដីកាបង្គាប់ឱ្យចូលខ្លួននេះ គឺបានដាក់កំហិតឱ្យជនត្រូវចោទចូលមកបង្ហាញខ្លួនតាមកាលបរិច្ឆេទ និងម៉ោងច្បាស់លាស់ ដើម្បីឱ្យចៅក្រមស៊ើបសួរយកចម្លើយពីករណីរឿង ដែលបានកើតឡើង។

បន្ទាប់ពីចៅក្រមស៊ើបសួរបានចេញដីកាបង្គាប់ឱ្យចូលខ្លួនហើយ ត្រូវឱ្យដំណឹងទៅបុគ្គលពាក់ព័ន្ធ គឺមន្ត្រីនគរបាលយុត្តិធម៌ ។ មន្ត្រីនគរបាល មានភារកិច្ចអនុវត្តដីកាបង្គាប់ឱ្យចូលខ្លួន ដោយស្វែងរក និងកោះអញ្ជើញបុគ្គល ដែលពាក់ព័ន្ធឱ្យបានដឹងពីដីកានេះ។ ក្រោយពីបុគ្គល ដែលពាក់ព័ន្ធទទួលនូវចុងដីកានេះហើយ ត្រូវបញ្ជូនទៅឱ្យចៅក្រមស៊ើបសួរវិញ។

ដីកានេះបង្គាប់ឱ្យចូលខ្លួនដោយមិនបង្ខិតបង្ខំទេ ជនដែលត្រូវបានបង្គាប់ឱ្យចូលខ្លួន នឹងត្រូវចូលមកបង្ហាញខ្លួនទៅតាមពេលកំណត់នោះដោយសេរី។

បើជនត្រូវចោទមិនចូលមកកាន់តុលាការតាមកំណត់ នៃដីកានោះចំនួន ២ ដង ដោយគ្មានមូលហេតុត្រឹមត្រូវ ចៅក្រមស៊ើបសួរនឹងចេញដីកានាំខ្លួន។

---

[72]- មាត្រា១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[73]- មាត្រា១៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៣.១.២.២. ដីកាបង្គាប់ឱ្យនាំខ្លួន

ដីកាបង្គាប់ឱ្យចូលខ្លួន គឺការបញ្ជាដល់កម្លាំងសាធារៈឱ្យចាប់ និងនាំខ្លួនបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឱ្យនាំខ្លួន អាចត្រូវចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ ដែលមានតម្រុយពិរុទ្ធភាព[74]។

ដីកាបង្គាប់ឱ្យនាំខ្លួនមាននិទ្ទេសដូចខាងក្រោម៖

-អត្តសញ្ញាណ នៃបុគ្គលដែលពាក់ព័ន្ធ

-បទល្មើស ដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស

-ថ្ងៃ ខែ ម៉ោងនិងទីកន្លែង ដែលត្រូវចូលមកបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើប

-ឈ្មោះ និងឋានៈរបស់ចៅក្រម ដែលចេញដីកា។

ដីកានេះត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ ព្រមទាំងមានបោះត្រាផង[75]។

ដីកាបង្គាប់ឱ្យនាំខ្លួនមានលក្ខណៈដាច់ខាត និងចាប់បង្ខំ នៅពេលដែលជនត្រូវចោទមិនចូលខ្លួនតាមសម្រួល។ ជនត្រូវចោទ ត្រូវបាននាំខ្លួនជាបន្ទាន់នៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកានេះអាចប្រើបានចំពោះសាក្សីផងដែរ គឺនៅពេលណា ដែលសាក្សីបានទទួលដីកាត្រឹមត្រូវ ហើយចូលមកបំភ្លឺនៅចំពោះមុខចៅក្រមស៊ើបសួរ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរអាចប្រើអំណាចរបស់ខ្លួន ដោយចេញដីកាបង្គាប់ឱ្យនាំខ្លួនជនជាប់សង្ស័យមកចំពោះមុខខ្លួនបាន។

ការអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនត្រូវប្រគល់ទៅឱ្យមន្ត្រីនគរបាលយុត្តធមិ។ ប៉ុន្តែនៅក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យនាំខ្លួន ត្រូវធ្វើការផ្សព្វផ្សាយដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ដែលអាចធ្វើបាន។ ក្នុងពេលបំពេញបេសកកម្មនេះ ដើមដីកាត្រូវប្រគល់ជាបន្ទាន់ដល់មន្ត្រីនគរបាលយុត្តិធមិ ដែលទទួលបន្ទុកអនុវត្តដីកានេះ។ មន្ត្រីនគរបាលយុត្តិធមិ មិនអាចចូលទៅក្នុងលំនៅដ្ឋានរបស់បុគ្គល ដែលពាក់ព័ន្ធ មុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ បានឡើយ។ ប្រសិនបើ ជួបប្រទះនូវការលំបាកនោះ មន្ត្រីនគរបាលយុត្តិធមិ ត្រូវរាយការណ៍ពីបញ្ហាលំបាកទាំងនេះជូនទៅចៅក្រមស៊ើបសួរ ដែលចេញដីកាបង្គាប់ឱ្យនាំខ្លួននោះ។

នៅពេលអនុវត្តបេសកកម្មនេះ មន្ត្រីនគរបាលយុត្តិធមិត្រូវនាំខ្លួនបុគ្គល ដែលពាក់ព័ន្ធទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ប្រសិនបើ មានមូលហេតុ នៃកាលៈទេសៈមានដូចជាលំបាកនៅក្នុងការដឹកជញ្ជូន ដែលជាហេតុមិនអាចនាំខ្លួនបុគ្គល ដែលពាក់ព័ន្ធទៅបង្ហាញខ្លួនដល់

---

[74]- មាត្រា១៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[75]- មាត្រា១៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចៅក្រមស៊ើបសួរក្រោយពេលចាប់ខ្លួនបានភ្លាមៗ ហើយបុគ្គលនោះ ត្រូវតែនាំខ្លួនទៅក្នុងអង្គភាពនគរបាល ឬកងរាជអាវុធហត្ថក្នុងមណ្ឌលឃុំខ្លួន ឬនៅក្នុងពន្ធនាគារ។ បុគ្គលនេះ ត្រូវតែនាំខ្លួនទៅបង្ហាញខ្លួនយ៉ាងយូរបំផុតថ្ងៃបន្ទាប់ ដល់ចៅក្រមស៊ើបសួរ ឬអ្នកជំនួស ករណីដែលការបង្ហាញខ្លួនមិនបានប្រព្រឹត្តទៅនៅថ្ងៃបន្ទាប់ទេនោះ បុគ្គលពាក់ព័ន្ធត្រូវបានដោះលែងឱ្យមានសេរីភាពវិញ[76]។ ម្យ៉ាងវិញទៀត កាលណាបុគ្គលម្នាក់ ដែលត្រូវបានចាប់ខ្លួន ដោយអនុវត្តដីកាបង្គាប់ឱ្យនាំខ្លួនត្រូវបានឃុំខ្លួននោះ ថិរវេលា នៃការឃុំខ្លួននេះត្រូវរាប់បញ្ចូលទៅក្នុងថិរវេលា នៃការឃុំខ្លួនបណ្ដោះអាសន្ន ប្រសិនបើមាន[77]។

### ៣.១.២.៣. ដីកាបង្គាប់ឱ្យចាប់ខ្លួន

ដីកាបង្គាប់ឱ្យចាប់ខ្លួន គឺជាការបញ្ជាដល់កម្លាំងសាធារណៈឱ្យស្វែងរកចាប់ខ្លួន និងនាំខ្លួនបុគ្គល ដែលពាក់ព័ន្ធទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន[78]។

ដូចនេះ ដីកានេះមានតួនាទី៣យ៉ាងគឺ ស្វែងរក ចាប់ខ្លួន និងឃុំខ្លួន។ នៅពេល ដែលដីកាបង្គាប់ឱ្យចាប់ខ្លួនបានចេញហើយ បុគ្គលដែលត្រូវបានស្វែងរកនោះ ត្រូវបានសមត្ថកិច្ចរកឃើញ និងចាប់ខ្លួនពុំចាំបាច់ចេញដីកាបង្គាប់ឱ្យឃុំខ្លួនទៀតទេ ព្រោះដីកាបង្គាប់ឱ្យចាប់ខ្លួន មានតម្លៃស្មើនឹងបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនបុគ្គលនោះ។

ដីកានេះអាចចេញបានតែលើបុគ្គលដែលរត់គេចខ្លួន ឬក្នុងករណីបុគ្គលនោះរត់ចេញទៅក្រៅប្រទេសកម្ពុជា ឬរស់នៅកន្លែងដែលមិនស្គាល់ក្នុងលក្ខខណ្ឌដែលអំពើដែលត្រូវបង្ក្រាបនោះជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ។ ពោលគឺ នៅពេលដែលចៅក្រមស៊ើបសួរ បានចេញដីកាបង្គាប់ឱ្យនាំខ្លួនទៅឱ្យកងកម្លាំងសាធារណៈនាំខ្លួនជនត្រូវចោទឱ្យចូលមកតុលាការដោយមានកំណត់កាលបរិច្ឆេទច្បាស់លាស់ ប៉ុន្តែ លុះដល់ថ្ងៃកំណត់ជនត្រូវចោទបានរត់គេចខ្លួនមិននៅផ្ទះ ចៅក្រមស៊ើបសួរត្រូវចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ឬដីកាស្វែងរកចាប់ខ្លួនប្រសិនបើមានបញ្ជាក់ពីអាជ្ញាធរមូលដ្ឋានថា ជនត្រូវចោទបានរត់គេចខ្លួនពីលំនៅឋានរបស់ខ្លួនមិនដឹងទៅទីកន្លែងណា។

មុននឹងចេញដីកាបង្គាប់ឱ្យចាប់ខ្លួន ចៅក្រមស៊ើបសួរ ត្រូវតែទទួលយោបល់ពីព្រះរាជអាជ្ញាជាមុនសិន។ ចៅក្រមស៊ើបសួរ ត្រូវចេញដីកានេះដោយមានថែងមូលហេតុ ក្រោយពីបានទទួលយោបល់ពីព្រះរាជអាជ្ញា។ ព្រះរាជអាជ្ញា ធានារ៉ាប់រងផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន[79] នេះគឺជា

---

[76]- សៀវភៅនីតិវិធីព្រហ្មទណ្ឌ របស់អនុបណ្ឌិត អៀង សំណាង បោះពុម្ពឆ្នាំ ២០១៥ ទំព័រទី១១៣

[77]- មាត្រា១៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[78]- មាត្រា១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[79]- មាត្រា១៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

មូលហេតុ ដែលដីកាទាំងនេះអាចត្រូវបានផ្សព្វផ្សាយជាអន្តរជាតិ ដោយមានអន្តរាគមន៍របស់មន្ត្រីនគរបាលយុត្តិធម៌។ បុគ្គល ដែលពាក់ព័ន្ធ ត្រូវបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ ឬអ្នកជំនួសនៅថ្ងៃបន្ទាប់ពីការចាប់ខ្លួន ក្នុងករណី ពុំអាចធ្វើដូចនេះបាន ជនសង្ស័យត្រូវបានសួរដោយព្រះរាជអាជ្ញានៅកន្លែងឃុំខ្លួន។ ព្រះរាជអាជ្ញា ត្រូវធ្វើកំណត់ហេតុស្តាប់ចម្លើយ ដែលត្រូវបញ្ជូនទៅឱ្យចៅក្រមស៊ើបសួរ[80]។

កាលណា បុគ្គលណាម្នាក់ដែលត្រូវបានចាប់ខ្លួន ដោយអនុវត្តតាមដីកាបង្គាប់ឱ្យចាប់ខ្លួន ត្រូវបានឃុំខ្លួន នោះថិរវេលា នៃការឃុំខ្លួននោះត្រូវរាប់បញ្ចូលទៅក្នុងថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នប្រសិនបើមាន[81]។

ការអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវប្រគល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌។ នៅក្នុងករណីបន្ទាន់ ដីកាបង្គាប់ឱ្យចាប់ខ្លួនត្រូវផ្សព្វផ្សាយទៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថតាមគ្រប់មធ្យោបាយ ហើយដើមដីកាត្រូវប្រគល់ក្នុងរយៈពេលខ្លីបំផុតឱ្យដល់មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកនូវដីកាបង្គាប់ឱ្យចាប់ខ្លួននោះ។ ករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចចូលទៅក្នុងលំនៅឋានរបស់បុគ្គល ដែលពាក់ព័ន្ធមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ ល្ងាច បានឡើយ។ នៅគ្រប់ការលំបាករបស់ខ្លួននៅពេលអនុវត្តដីកាបង្គាប់ឱ្យចាប់ខ្លួននេះ មន្ត្រីនគរបាលនគរបាលយុត្តិធម៌ ត្រូវតែរាយការណ៍ជូនទៅចៅក្រមស៊ើបសួរ ដែលជាអ្នកចេញដីកា។ ក្នុងករណីចាំបាច់ ដីកាបង្គាប់ឱ្យចាប់ខ្លួនអាចផ្សព្វផ្សាយជាអន្តរជាតិ តាមរយៈក្រសួងយុត្តិធម៌ ដោយប្រើយន្តការនានា ដែលមានប្រសិទ្ធភាព។ ម៉្យាងទៀត ការបង្ហាញដីកាបង្គាប់ឱ្យចាប់ខ្លួន ជាបញ្ជាឱ្យប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវទទួល និងឃុំខ្លួនជនត្រូវចោទដែលជាកម្មវត្ថុនៃដីកាបង្គាប់ឱ្យចាប់ខ្លួន។ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនរក្សាទុកនូវដើមដីកា ឬចុងដីកាដែលមានបញ្ជាក់ត្រឹមត្រូវតាមច្បាប់ដើម[82]។

### ៣.១.២.៤. ដីកាបង្គាប់ឱ្យឃុំខ្លួន

ដីកាបង្គាប់ឱ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឱ្យទទួល និងឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរ អាចនឹងចេញដីកាបង្គាប់ឱ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុ នៃដីកាសម្រេចឱ្យឃុំខ្លួនបណ្តោះអាសន្ន[83]។ ខ្លឹមសារ នៃចំណុចនេះ គឺវាឆ្លុះបង្ហាញឱ្យឃើញថា មានការហាមឃាត់មិនឱ្យជនត្រូវចោទមានសេរីភាពនៅក្នុងការដើរហើរ ព្រោះជាគោលការណ៍ជនត្រូវចោទត្រូវមានសេរីភាព។ ក៏ប៉ុន្តែ នៅក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវបានឃុំខ្លួន

[80]- មាត្រា២០១-៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[81]- មាត្រា២០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[82]- សៀវភៅ នីតិវិធីព្រហ្មទណ្ឌរបស់ អនុបណ្ឌិត អៀង សំណាង បោះពុម្ពឆ្នាំ២០១៥ ទំព័រ១១៣

[83]- មាត្រា២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

បណ្តោះអាសន្នបាន នេះជាបញ្ញត្តិ ដែលចែងពីអំណាចរបស់ចៅក្រមស៊ើបសួរ ដែលខ្លួនត្រូវទទួលបាននូវសិទ្ធិនេះ ដើម្បីជាជំនួយដល់ការស្វែងរកនូវការពិត។ ទន្ទឹមនឹងនេះ មិនមែនមានន័យថា គ្រប់ជនត្រូវចោទ សុទ្ធតែត្រូវបានធ្វើការឃុំខ្លួនបណ្តោះអាសន្នឡើយ។ មានន័យថា ការឃុំខ្លួនបណ្តោះអាសន្ន អាចអនុវត្តបានតែនៅក្នុងករណីចោទប្រកាន់ពី បទឧក្រិដ្ឋ ឬបទមជ្ឈិម ដែលច្បាប់បានកំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើស ១ ឆ្នាំប៉ុណ្ណោះ។

**ក. គោលបំណង នៃការឃុំខ្លួនបណ្តោះអាសន្ន**

ការឃុំខ្លួនបណ្តោះអាសន្នធ្វើឡើងក្នុងគោលបំណងដូចខាងក្រោមៈ

-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី

-ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។

-ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ

-ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី

-ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ

-ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ដែលបណ្តាលមកពីបទល្មើស។ ទាំងនេះ ជាមូលហេតុនៃ ការឃុំខ្លួនបណ្តោះអាសន្ន ទោះបីចៅក្រមស៊ើបសួរធ្វើការជ្រើសរើសយក នូវហេតុផលណាមួយនៅក្នុងចំណោមចំណុចខាងលើ គឺសុទ្ធតែអាចជាមូលហេតុ នៃការឃុំខ្លួនបណ្តោះអាសន្នបានទាំងអស់។

ដីកាបង្គាប់ឱ្យឃុំខ្លួនត្រូវមានចុះនិទ្ទេសដូចតទៅៈ

-អត្តសញ្ញាណរបស់ជនត្រូវចោទ

-ប្រភេទបទល្មើស ដែលចោទប្រកាន់ និងអត្ថបទច្បាប់ ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ។

-ឈ្មោះ និងឋានៈរបស់ចៅក្រម ដែលចេញដីកា។

ដីកាបង្គាប់ឱ្យឃុំខ្លួនត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ[84]។

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនត្រូវតែទទួល និងឃុំខ្លួនបុគ្គល ដែលមានដីកាបង្គាប់ឱ្យឃុំខ្លួនរហូតទាល់តែបានទទួលការឱ្យដំណឹងអំពីការដោះលែងឱ្យមានសេរីភាពវិញ។

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវរក្សាទុកនូវដើមដីកាបង្គាប់ឱ្យឃុំខ្លួន ឬចុងដីកានេះដែលបញ្ជាក់ថាត្រឹមត្រូវតាមច្បាប់ដើម[85]។

[84]- មាត្រា២២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**ខ. នីតិវិធី នៃការឃុំខ្លួនបណ្តោះអាសន្ន**

ជាគោលការណ៍ នៅក្នុងករណី ដែលចៅក្រមស៊ើបសួរសម្រេចធ្វើការឃុំខ្លួនបណ្តោះអាសន្ន ដោយគំនិតរបស់ខ្លួនផ្ទាល់ ឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាក៏ដោយ ចៅក្រមស៊ើបសួរត្រូវឱ្យដំណឹងពីដីកាសម្រេចនេះដល់ជនត្រូវចោទ និងទទួលការកត់សំគាល់របស់ជនត្រូវចោទនេះ។ កាលណា ជនត្រូវចោទមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញនូវមធ្យោបាយការពារខ្លួនឱ្យកូនក្តីរបស់ខ្លួន។ ចៅក្រមស៊ើបសួរ សម្រេចឃុំខ្លួនបណ្តោះអាសន្នតាមដីកា ដែលមានសំអាងហេតុ ហើយត្រូវឱ្យដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ។

ដីកាបង្គាប់ឱ្យឃុំខ្លួនត្រូវមានចុះនិទ្ទេសដូចតទៅ៖

-អត្តសញ្ញាណរបស់ជនត្រូវចោទ

-ប្រភេទបទល្មើស ដែលចោទប្រកាន់ និងអត្ថបទច្បាប់ ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ

-ឈ្មោះ និងឋានៈរបស់ចៅក្រម ដែលចេញដីកា

ដីកាបង្គាប់ឱ្យឃុំខ្លួនត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផងដែរ[86]។

**គ. ថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្ន**

**គ.១. ចំពោះអនីតិជន**

ជាគោលការណ៍ថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នរបស់អនីតិជន គឺមានលក្ខណៈខុសគ្នាទៅនឹងនីតិជន។ អនីតិជនចែកចេញជា ៣ ប្រភេទដូចខាងក្រោម៖

➢ **អនីតិជនមានអាយុក្រោម ១៤ ឆ្នាំ**

អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ មិនអាចត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ។ វិធានបែបបង្ខំតែមួយគត់ ដែលអាចសម្រេចដោយចៅក្រមស៊ើបសួរចំពោះអនីតិជនប្រភេទនេះ គឺការបញ្ជូនខ្លួនពួកគេទៅឱ្យអាណាព្យាបាល ឬឪពុក ម្តាយ។ ក្នុងករណី គ្មានអាណាព្យាបាលទេ ត្រូវប្រគល់ទៅឱ្យមជ្ឈមណ្ឌលអប់រំថែរក្សាបណ្តោះអាសន្នរង់ចាំសេចក្តីសម្រេចរបស់តុលាការ [87]។

➢ **អនីតិជនមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៦ឆ្នាំ**

អនីតិជន ដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ ត្រូវបានគេចោទប្រកាន់ពីបទឧក្រិដ្ឋថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ ខែបានទេ។

[85]- មាត្រា២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[86]- មាត្រា២២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[87]- មាត្រា២១២, ២២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

អនីតិជន ដែលមានអាយុចាប់ពី ១៤ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ ត្រូវបានគេចោទប្រកាន់ពីបទមជ្ឈិមថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ២ ខែបានទេ[88]។

➢ **អនីតិជនមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ**

អនីតិជន ដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ត្រូវបានគេចោទប្រកាន់ពីបទឧក្រិដ្ឋថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៦ ខែបានទេ។

អនីតិជន ដែលមានអាយុចាប់ពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ ត្រូវបានគេចោទប្រកាន់ពីបទមជ្ឈិមថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្ន មិនអាចលើសពី ៤ ខែបានទេ[89]។

ថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នខាងលើនេះ មិនត្រូវឱ្យលើសពីពាក់កណ្តាល នៃអប្បបរមា នៃទោស ដែលច្បាប់បានចែងសម្រាប់អនីតិជនឡើយ[90]។

**គ.២. ចំពោះនីតិជន**

ក្នុងករណី បទឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្ន មិនត្រូវឱ្យលើសពី ៦ ខែ បានទេ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរ អាចពន្យាពេលការឃុំខ្លួនបណ្តោះអាសន្នម្តងបាន ៦ ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចពន្យាពេលការឃុំខ្លួនបណ្តោះអាសន្នបានតែ ២ ដងគត់[91]។

ចំពោះនីតិជន ដែលត្រូវបានចោទប្រកាន់ពី បទមជ្ឈិម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ៤ ខែបានទេ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះចៅក្រមស៊ើបសួរអាចធ្វើការពន្យាការឃុំខ្លួនបណ្តោះអាសន្នម្តងបាន ២ ខែ ដោយមានដីកាសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។

ចំពោះ បទមជ្ឈិម ថិរវេលា នៃការឃុំខ្លួនបណ្តោះអាសន្នមិនត្រូវលើសពីពាក់កណ្តាល នៃអប្បបរមា នៃទោស ដែលច្បាប់បានកំណត់ឡើយ។

ក្នុងករណី ដែលមានការចោទប្រកាន់ពី បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ បទឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី ១ ឆ្នាំ បានទេចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះចៅក្រមស៊ើបសួរអាចពន្យាការឃុំខ្លួនបណ្តោះអាសន្នបាន ម្តង ១ ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យពន្យាពេល នៃការឃុំខ្លួនបណ្តោះអាសន្ននេះបានតែ ២ ដងគត់[92]។ ក្នុងករណី ដែល

[88]- មាត្រា២១៣, ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[89]- មាត្រា២១៣, ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[90]- មាត្រ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[91]- មាត្រា២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[92]- មាត្រា២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចៅក្រមស៊ើបសួរសម្រេចថាពន្យាពេល នៃការឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលនូវការកត់សម្គាល់ពីជននេះ។ កាលណា ជនត្រូវចោទមានមេធាវីអមនោះ មេធាវីត្រូវបង្ហាញនូវមធ្យោបាយការពារកូនក្តីរបស់ខ្លួន។

**ឃ. ការសម្រេចមិនឃុំខ្លួន**

ទន្ទឹមនឹងការឃុំខ្លួនបណ្ដោះអាសន្ន ចៅក្រមស៊ើបសួរ ក៏មានអំណាចចេញដីកាសម្រេចមិនឃុំខ្លួនដែរ។ កាលណា ចៅក្រមស៊ើបសួរ ដែលទទួលពាក្យបណ្ដឹងតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដែលសុំឱ្យឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ន មិនព្រមធ្វើតាមការសុំនោះទេ ចៅក្រមស៊ើបសួរត្រូវចេញដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងរយៈពេល ៥ ថ្ងៃ ដោយមិនចាំបាច់មានសំអាងហេតុទេ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកប្ដឹងសុំ។ ករណីដែលចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥ ថ្ងៃទេ ព្រះរាជអាជ្ញា មានសិទ្ធិប្ដឹងទៅសភាស៊ើបសួរសាលាឧទ្ធរណ៍ ដែលនឹងធ្វើការសម្រេចជំនួសចៅក្រមស៊ើបសួរបាន[93]។

**ង. ការដោះលែងជនត្រូវចោទឱ្យស្ថិតនៅក្រៅឃុំ**

ជាគោលការណ៍ការដោះលែងជនត្រូវចោទឱ្យស្ថិតនៅក្រៅឃុំធ្វើឡើងតាមរយៈការសម្រេចរបស់ចៅក្រមស៊ើបសួរ ឬបណ្ដឹងរបស់ព្រះរាជអាជ្ញា ឬបណ្ដឹងរបស់ជនត្រូវចោទ។

**ង.១. ការដោះលែងតាមរយៈការសម្រេចរបស់ចៅក្រមស៊ើបសួរ**

នៅក្នុងករណី ដែលចៅក្រមស៊ើបសួរយល់ឃើញថា ធាតុផ្សំបទល្មើសមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីធ្វើការចោទប្រកាន់ទេនោះ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទឱ្យនៅក្រៅឃុំបានគ្រប់ពេលវេលា។ ករណីនេះ មុននឹងចេញដីកាដោះលែងជនត្រូវចោទ ចៅក្រមស៊ើបសួរត្រូវជូនពត៌មាននេះទៅព្រះរាជអាជ្ញា ដើម្បីសុំយោបល់ ហើយបញ្ជូនសំណុំរឿងឱ្យទៅព្រះរាជអាជ្ញាពិនិត្យ ដោយព្រះរាជអាជ្ញាត្រូវផ្ដល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ ថ្ងៃ បន្ទាប់ពីបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ នៅក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យដោះលែងជនត្រូវចោទភ្លាម ដោយមិនរង់ចាំយោបល់របស់ព្រះរាជអាជ្ញា ដោយត្រូវចង្អុលប្រាប់ពីមូលហេតុ នៃការបន្ទាន់នោះ នៅក្នុងដីកាសម្រេចរបស់ខ្លួន[94]។

**ង.២. ការដោះលែងតាមរយៈបណ្ដឹងរបស់ព្រះរាជអាជ្ញា**

ព្រះរាជអាជ្ញា អាចសុំឱ្យដោះលែងជនត្រូវចោទបានគ្រប់ពេលវេលា ដូចជាចៅក្រមស៊ើបសួរដែរ។ ករណីនេះ ចៅក្រមស៊ើបសួរត្រូវធ្វើការសម្រេចនៅក្នុងរយៈពេល ៥ ថ្ងៃ។ ករណី ដែលចៅក្រម

---

[93]- មាត្រា២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[94]- មាត្រា២១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥ ថ្ងៃទេ ព្រះរាជអាជ្ញាអាចប្តឹងសុំទៅសភាស៊ើបសួរដែលអាចសម្រេចជំនួសចៅក្រមស៊ើបសួរបាន។ ផ្ទុយទៅវិញ ករណីមិនព្រមដោះលែងត្រូវមានសំអាងហេតុ ដែលមានបង្ហាញនៅក្នុងដីកាសម្រេចនោះ[95]។

### ខ.៣. ការដោះលែងតាមរយៈបណ្តឹងរបស់ជនត្រូវចោទ

ក្នុងករណី ដែលជនត្រូវចោទត្រូវបានឃុំខ្លួននោះ ជនត្រូវចោទមានសិទ្ធិផ្ទាល់មានសិទ្ធិដាក់ពាក្យសុំឱ្យដោះលែងនៅក្រៅឃុំបានគ្រប់ពេលវេលា។ កាលណា ពាក្យបណ្តឹងត្រូវបានដាក់ទៅចៅក្រមស៊ើបសួរ ចៅក្រមស៊ើបសួររូបនេះ ត្រូវបញ្ជូនពាក្យប្តឹងនោះទៅព្រះរាជាអាជ្ញាភ្លាមដើម្បីផ្តល់យោបល់ និងធ្វើការបញ្ជូនសំណុំរឿងទៅដើម្បីពិនិត្យ។ ក្រោយពីទទួលបាននូវពាក្យបណ្តឹង ហើយ ព្រះរាជអាជ្ញានឹងផ្តល់យោបល់នៅក្នុងរយៈពេលខ្លីបំផុត ហើយចៅក្រមស៊ើបសួរអាចសម្រេចយ៉ាង យូរបំផុតរយៈពេល ៥ ថ្ងៃ បន្ទាប់ពីបានបញ្ជូនពាក្យបណ្តឹងទៅព្រះរាជអាជ្ញា។

កាលណា ជនត្រូវចោទត្រូវបានបដិសេធមិនឱ្យស្ថិតនៅក្រៅឃុំ ជនត្រូវចោទមានសិទ្ធិដាក់ពាក្យសុំនៅក្រៅឃុំសារជាថ្មីម្តងទៀតទៅចៅក្រមស៊ើបសួរ ឬទៅសភាស៊ើបសួរក្នុងរយៈពេល ១ខែ បន្ទាប់ពីមានសេចក្តីបដិសេធពាក្យសុំលើកមុន ករណីនេះ ចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរត្រូវសម្រេចលើពាក្យស្នើសុំនេះនៅក្នុងរយៈពេល ៥ ថ្ងៃក្រោយពីបានទទួលពាក្យស្នើសុំ[96]។

### ច. ការដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

កាលណា ជនត្រូវចោទត្រូវបានចោទប្រកាន់អំពីបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារនោះ ចៅក្រមស៊ើបសួរ អាចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលា។

ការត្រួតពិនិត្យតាមផ្លូវតុលាការ មានអានុភាពបង្គាប់ជនត្រូវចោទគោរព នូវកាតព្វកិច្ចមួយ ឬច្រើនដូចខាងក្រោម៖

-មិនត្រូវចេញក្រៅព្រំប្រទល់ដែនកំណត់ដោយចៅក្រមស៊ើបសួរ

-មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ

-មិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយចៅក្រមស៊ើបសួរ

-ត្រូវបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

-ត្រូវឆ្លើយតប នឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយចៅក្រមស៊ើបសួរ

[95]- មាត្រា២១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[96]- មាត្រា២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

-ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជី នៅគ្រប់ឯកសារបញ្ជាក់ពីអត្តសញ្ញាណ

-មិនត្រូវបើកបររថយន្ត

-មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួនដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ

-ដាក់ប្រាក់ធានា ដែលចំនួនទឹកប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរដោយផ្អែកលើធនធានរបស់ជនត្រូវចោទ

-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធ ដែលជនត្រូវចោទកាន់កាប់

-ប្រគល់ខ្លួនឱ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុដាក់ឱ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ

-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈ។

អនីតិជន ដែលមានអាយុតិចជាង ១៤ ឆ្នាំ មិនត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការឡើយ[97]។

កាលណា ចៅក្រមស៊ើបសួរ ធ្វើការសម្រេចដោយត្រូវដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះ ដែលការសម្រេចនេះ អាចជាគំនិតផ្តួចផ្តើមរបស់ខ្លួន ឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា។ ករណីនេះ ចៅក្រមស៊ើបសួរត្រូវមានបញ្ជាក់ពីកាតព្វកិច្ច ដែលតម្រូវទៅលើជនត្រូវចោទ។

ដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះ ចៅក្រមស៊ើបសួរត្រូវជូនដំណឹងទៅព្រះរាជអាជ្ញា និងជនត្រូវចោទឱ្យបានដឹងពីការសម្រេចនេះ។ ជាមួយគ្នានេះដែរ នៅក្នុងករណី ដែលចៅក្រមស៊ើបសួរទទួលពាក្យបណ្តឹងពីសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាដោយសុំឱ្យដាក់ជនត្រូវចោទស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ តែចៅក្រមស៊ើបសួរមិនព្រមតាមការសុំនោះ ចៅក្រមស៊ើបសួរត្រូវចេញដីកាបដិសេធនៅក្នុងរយៈពេល ៥ ថ្ងៃ។ ដីកាសម្រេចបដិសេធនេះ ត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា។ ករណីដែលចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥ ថ្ងៃទេនោះ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្តឹងទៅសភាស៊ើបសួរ ដែលមានសិទ្ធិសម្រេចជំនួសចៅក្រមស៊ើបសួរបាន។

## ៣.២.វិធានការណ៍ស្រាវជ្រាវរបស់ចៅក្រមស៊ើបសួរ

### ៣.២.១. កិច្ចដាបឋមនៃការស្រាវជ្រាវ

ក្នុងករណី ដែលជនត្រូវចោទត្រូវបានចៅក្រមស៊ើបសួរចេញនូវសេចក្តីសម្រេចដាក់ជននោះឱ្យស្ថិតនៅក្រមការត្រួតពិនិត្យតាមផ្លូវតុលាការ ជាបឋម នៅពេលចូលបង្ហាញខ្លួនជាលើកដំបូង

[97]- សៀវភៅនីតិវិធីព្រហ្មទណ្ឌ របស់អនុបណ្ឌិត អៀង សំណាង បោះពុម្ពឆ្នាំ២០១៥ ទំព័រ ១២២

ចៅក្រមស៊ើបសួរពិនិត្យអត្តសញ្ញាណជនត្រូវចោទ ដោយប្រាប់ជននេះឱ្យដឹងពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើស ដែលកំណត់ដោយច្បាប់។ នៅក្នុងចំណាត់ការនេះចៅក្រមស៊ើបសួរនឹងប្រាប់ជនត្រូវចោទថា ខ្លួនមានសិទ្ធិឆ្លើយ ឬមិនឆ្លើយបានដោយសេរី ចំណែកឯនិទ្ទេសស្តីពីការប្រាប់នេះ ត្រូវចុះក្នុងកំណត់ហេតុនៅពេល ដែលជនត្រូវចោទចង់ឆ្លើយនោះ ចៅក្រមស៊ើបសួរ ត្រូវតែទទួលចម្លើយនោះភ្លាម។

ចៅក្រមស៊ើបសួរ ត្រូវប្រាប់ជនត្រូវចោទ ឱ្យបានដឹងអំពីសិទ្ធិរបស់ខ្លួននៅក្នុងការជ្រើសរើសមេធាវី ឬក្នុងការស្នើសុំឱ្យមានមេធាវីឱ្យខ្លួន ដោយត្រូវអនុវត្តតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។ ចំពោះជនត្រូវចោទ ដែលជាអនីតិជនត្រូវមានមេធាវីអមជានិច្ច នៅក្នុងករណី ដែលមិនមានការជ្រើសរើសដោយជនត្រូវចោទជាអនីតិជនទេនោះ មេធាវីនឹងត្រូវធ្វើការចាត់តាំងនៅក្នុងលក្ខខណ្ឌ ដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។

ចំពោះជនត្រូវចោទ ដែលនៅក្រៅឃុំ ក្រោយពីការចូលរួមបង្ហាញខ្លួនលើកទីមួយ ជននេះត្រូវប្រកាសឱ្យចៅក្រមស៊ើបសួរបានដឹងអំពីអាសយដ្ឋានរបស់ខ្លួន នៅពេលដែលខ្លួនផ្លាស់ប្តូរអាសយដ្ឋាននោះក៏ត្រូវជូនពត៌មាននេះឱ្យចៅក្រមស៊ើបសួរបានដឹងផងដែរ ដោយការជូនដំណឹងនេះ ត្រូវចាត់ទុកថាបានធ្វើឡើងដោយសាមីខ្លួនផ្ទាល់។ ម៉្យាងទៀត ការឱ្យដំណឹង ព្រមទាំងការប្រកាសស្តីពី ការផ្លាស់ប្តូរអាសយដ្ឋាននោះ ត្រូវចុះនៅក្នុងកំណត់ហេតុនៅពេលបង្ហាញខ្លួនជាលើកដំបូង។

ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរត្រូវហៅអ្នកបកប្រែ។ មុននឹងបំពេញការងារអ្នកបកប្រែត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថានឹងជួយដល់តុលាការ ដោយធ្វើការបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងអស់ ហើយអ្នកបកប្រែនេះ មិនអាចត្រូវបានជ្រើសរើសនៅក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ ភាគី ឬសាក្សី ទោះជាក្នុងករណីណាក៏ដោយ[98]។

### ៣.២.២. ការសួរចម្លើយជនត្រូវចោទ

ការសួរចម្លើយជនត្រូវចោទ គឺសំដៅទៅលើការសួរចម្លើយបុគ្គល ដែលត្រូវបានដាក់ពិរុទ្ធរួចហើយ និងចោទសួរបុគ្គលនោះគ្រប់សំណួរចាំបាច់ក្នុងការបង្ហាញការពិត។ ការសួរចម្លើយនេះ ធ្វើឡើងក្រោយការសួរចម្លើយនៅពេល ដែលបង្ហាញខ្លួនលើកដំបូង។

នៅក្នុងករណី ដែលកំពុងបំពេញកិច្ចរបស់ខ្លួន ចៅក្រមស៊ើបសួរមានសិទ្ធិសួរចម្លើយជនត្រូវចោទបាន ដោយចៅក្រមស៊ើបសួរ អាចត្រូវសួរចម្លើយបានតែនៅចំពោះមុខមេធាវីតែប៉ុណ្ណោះ។ ដូច្នេះ ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីយ៉ាងតិចបំផុតចំនួន ៥ ថ្ងៃ មុនការសួរចម្លើយជនត្រូវ

[98]- សៀវភៅ នីតិវិធីព្រហ្មទណ្ឌរបស់ អនុបណ្ឌិត អៀង សំណាង បោះពុម្ពឆ្នាំ២០១៥ ទំព័រ៩៥, ៩៦

ចោទ ដោយនៅក្នុងចិរវេលានេះអាចឱ្យមេធាវីពិនិត្យមើលនូវសំណុំរឿងបាន។ នៅក្នុងករណីនេះ នៅពេលដែលចៅក្រមស៊ើបសួរបានកោះហៅមេធាវីបានត្រឹមត្រូវហើយ ប៉ុន្តែ មេធាវីមិនបានចូលបង្ហាញខ្លួននៅក្នុងថ្ងៃ និងម៉ោង ដែលបានកំណត់នោះទេ ចៅក្រមស៊ើបសួរអាចសួរចម្លើយជនត្រូវចោទដោយគ្មានវត្តមានមេធាវីបាន ហើយនិទ្ទេសស្តីពី អវត្តមានរបស់មេធាវីនេះ ត្រូវចុះនៅក្នុងកំណត់ហេតុសួរចម្លើយរបស់ជនត្រូវចោទ។

ក្នុងករណីពិសេស ចៅក្រមស៊ើបសួរ អាចសួរចម្លើយជនត្រូវចោទដោយមិនចាំបាច់ធ្វើការកោះហៅមេធាវី ប្រសិនបើ ជនត្រូវចោទបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីរបស់ខ្លួន។ ការបោះបង់នេះ ត្រូវចុះនៅក្នុងកំណត់ហេតុមួយផ្សេងទៀតពីកំណត់ហេតុសួរចម្លើយ និងត្រូវចុះហត្ថលេខាដោយជនត្រូវចោទ។ ជាមួយគ្នានេះដែរ នៅក្នុងករណីបន្ទាន់មួយទៀត ចៅក្រមស៊ើបសួរធ្វើការសួរចម្លើយជនត្រូវចោទ ដោយមិនបាច់កោះហៅមេធាវីបានដែរនៅក្នុងករណី ដែលមានភាពបន្ទាន់។ ភាពបន្ទាន់នេះ ត្រូវតែបណ្តាលមកពីគ្រោះថ្នាក់រហូតដល់ស្លាប់ ឬបណ្តាលមកពីការភ័យខ្លាចបាត់បង់នូវតម្រុយ នៃភស្តុតាង។ ប្រភេទ នៃភាពបន្ទាន់ ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[99]។ ទន្ទឹមនឹងនេះ នៅក្នុងពេលដែលចៅក្រមស៊ើបសួរកំពុងសួរចម្លើយជនត្រូវចោទ ព្រះរាជអាជ្ញា និងមេធាវី ក៏អាចលើកជាសំណួរបានដែរ ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ[100]។

សំណុំរឿងស៊ើបសួរអាចពិនិត្យមើលបានដោយមេធាវី ដែលដើរតួជាអន្តរការីជាដាច់ខាតរវាងសំណុំរឿង និងជនត្រូវចោទ។ មេធាវី ឬលេខាធិការរបស់មេធាវី ត្រូវបានអនុញ្ញាតដោយចៅក្រមស៊ើបសួរ ឱ្យធ្វើការថតសម្លេង ដោយខ្លួនជាអ្នកចេញសោហ៊ុយ និងក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី[101]។

### ៣.២.៣. ការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ក្រៅពីបានសួរចម្លើយជនត្រូវចោទនៅក្នុងការបំពេញកិច្ចរបស់ខ្លួននោះ ចៅក្រមស៊ើបសួរក៏មានសិទ្ធិស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីផងដែរ។ នៅក្នុងនីតិវិធីនេះ គឺដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានអមដោយមេធាវីនៅពេលដែលត្រូវផ្តល់ចម្លើយដល់ចៅក្រមស៊ើបសួរ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវកោះហៅមេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណីយ៉ាងតិចបំផុត ៥ ថ្ងៃ មុនការស្តាប់ចម្លើយ។ នៅក្នុងចិរវេលានេះ មេធាវីអាចពិនិត្យសំណុំរឿងនៃនីតិវិធីបាន។ ដើមបណ្តឹងរដ្ឋប្បវេណីអាចត្រូវបានគេស្តាប់ចម្លើយតែនៅចំពោះមុខមេធាវីរបស់ខ្លួនប៉ុណ្ណោះ។ ប៉ុន្តែ ប្រសិនបើមេធាវីដែល

[99]- មាត្រា១៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[100]- មាត្រា១៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[101]- មាត្រា១២៩ វាក្យខណ្ឌទី៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ត្រូវបានកោះហៅយ៉ាងត្រឹមត្រូវ ហើយមិនចូលមកបង្ហាញខ្លួននៅថ្ងៃ និងម៉ោង តាមកំណត់ទេ ចៅក្រមស៊ើបសួរ អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយគ្មានវត្តមានរបស់មេធាវី។ និទ្ទេសស្តីពីអវត្តមាន ត្រូវចុះនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ។ ក្នុងករណីពិសេស ចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីបាន ដោយមិនបាច់កោះហៅមេធាវី ប្រសិនបើ ដើមបណ្តឹងរដ្ឋប្បវេណីបោះបង់ចោលយ៉ាងជាក់លាក់នូវវត្តមានមេធាវីរបស់ខ្លួន។ ការបោះបង់ចោលនេះ ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុមួយដោយឡែកពីកំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងត្រូវចុះហត្ថលេខាដោយដើមបណ្តឹងរដ្ឋប្បវេណី។ ក្នុងករណី បន្ទាន់ចៅក្រមស៊ើបសួរក៏អាចស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណីដោយមិនចាំបាច់កោះហៅមេធាវីបានដែរ។ ភាពបន្ទាន់នេះ ត្រូវបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបណ្តាលមកពីភ័យខ្លាយបាត់បង់តម្រុយភស្តុតាង។ ប្រភេទនៃភាពបន្ទាន់ត្រូវតែចុះនិទ្ទេសនៅក្នុងកំណត់ហេតុ។ ម៉្យាងទៀត ចៅក្រមស៊ើបសួរក៏អាចហៅរកអ្នកបកប្រែបានក្នុងករណីចាំបាច់[102]។

នៅក្នុងពេលស្តាប់ចម្លើយព្រះរាជអាជ្ញា និងមេធាវីអាចលើកជាសំណួរបាន ដោយមានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។ ក្នុងករណីមិនអនុញ្ញាត ករណីនោះត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ[103]។

### ៣.២.៤. ការស្តាប់ចម្លើយសាក្សី

ដើម្បីឱ្យការស៊ើបសួរទទួលបាននូវការពិត ក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្តល់សិទ្ធិឱ្យចៅក្រមស៊ើបសួរអាចស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលខ្លួនគិតថាមានប្រយោជន៍ដល់ការស្រាវជ្រាវស្វែងរកការពិត[104]។

ចៅក្រមស៊ើបសួរស្តាប់ចម្លើយសាក្សីដាច់ពីគ្នា ដោយគ្មានវត្តមានជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរ ក៏អាចសួរតទល់គ្នារវាងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីផងដែរ។ ក្នុងករណីនេះ បុគ្គលគ្រប់រូប ដែលត្រូវបានចៅក្រមស៊ើបសួរកោះហៅក្នុងឋានៈជាសាក្សីត្រូវតែមកបង្ហាញខ្លួន។ ប៉ុន្តែ ប្រសិនបើ បុគ្គលនោះរឹងទទឹងចៅក្រមស៊ើបសួរអាចសុំឱ្យកងកម្លាំងសាធារណៈបង្ខំសាក្សីនោះឱ្យចូលមកបង្ហាញខ្លួនបាន។ ចៅក្រមស៊ើបសួរ ចេញបញ្ជាឱ្យចូលមកបង្ហាញខ្លួន។ បញ្ជានេះ ត្រូវមានអត្តសញ្ញាណរបស់សាក្សី ហើយត្រូវចុះកាលបរិច្ឆេទ និង

[102]- មាត្រា១៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[103]- មាត្រា១៥១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[104]- មាត្រា១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[105]។ មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីម្នាក់ៗត្រូវធ្វើសម្បថស្របតាមសាសនា ឬជំនឿរបស់ខ្លួនថានិយាយតែការពិត[106]។

ក្នុងករណីចាំបាច់ ចៅក្រមស៊ើបសួរអាចហៅរកអ្នកបកប្រែ ដើម្បីស្តាប់ចម្លើយសាក្សី។ អ្នកបកប្រែនោះដែរ មុននឹងបំពេញការងារត្រូវតែធ្វើសម្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយដល់តុលាការ ដោយធ្វើការបកប្រែឱ្យបានត្រឹមត្រូវតាមចម្លើយទាំងអស់។ ម្យ៉ាងវិញទៀត អ្នកបកប្រែនេះ មិនអាចត្រូវបានជ្រើសរើសក្នុងចំណោម ចៅក្រម ក្រឡាបញ្ជី នគរបាលកងរាជអាវុធហត្ថ ភាគី ឬ សាក្សី ទោះបីក្នុងករណីណាក៏ដោយ[107]។

តាមគោលការណ៍មុននឹងផ្តល់ចម្លើយសាក្សីទាំងអស់ត្រូវធ្វើសម្បថជាមុនសិន។ ប៉ុន្តែ មានករណីលើកលែងមួយចំនួន ដែលសាក្សីត្រូវបានស្តាប់ចម្លើយដោយមិនចាំបាច់ធ្វើសម្បថ។

សាក្សីទាំងនោះមានដូចខាងក្រោម៖

-ឪពុក ម្តាយ និងបុព្វជនគ្រប់រូបរបស់ជនត្រូវចោទ

-កូនប្រុស កូនស្រី និងបច្ឆាជនគ្រប់រូបផ្សេងទៀតរបស់ជនត្រូវចោទ

-បង ប្អូនប្រុស ស្រី របស់ជនត្រូវចោទ

-បង ប្អូនថ្លៃប្រុស ស្រីរបស់ជនត្រូវចោទ

-ប្តី ឬប្រពន្ធរបស់ជនត្រូវចោទ ទោះបីបានលែងលះគ្នាក៏ដោយ

-កុមារអាយុតិចជាង១៤ ឆ្នាំ[108]។

ដើម្បីគោរពសិទ្ធិការពារខ្លួន ចៅក្រមស៊ើបសួរ មិនអាចស្តាប់ចម្លើយក្នុងឋានៈជាសាក្សីនូវបុគ្គលណាមួយ ដែលមានតម្រុយពិរុទ្ធភាពថាបានប្រព្រឹត្តបទល្មើសនោះទេ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរ ត្រូវផ្តល់ដំណឹងឱ្យជននោះបានដឹងអំពីការដាក់ជននោះ ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យបានបកស្រាយខាងលើ[109]។

ប្រសិនបើ សាក្សីឈឺ ឬមិនអាចធ្វើដំណើរបាន ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី អាចចុះទៅកាន់លំនៅឋាន ឬទីកន្លែងដែលសាក្សីនោះនៅដើម្បីទទួលចម្លើយ[110]។

---

[105]- មាត្រា១៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[106]- មាត្រា១៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[107]- មាត្រា១៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[108]- មាត្រា១៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[109]- មាត្រា១៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[110]- មាត្រា១៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៣.២.៥. ការឆែកឆេរ និងការចាប់យកវត្ថុតាង

ចៅក្រមស៊ើបសួរ អាចចុះទៅដល់កន្លែងកើតហេតុជាមួយក្រឡាបញ្ជីរបស់ខ្លួននៅលើវិសាលភាព នៃសមត្ថកិច្ចដែនដី នៃតុលាការជាន់ដំបូង ដើម្បីបំពេញកិច្ចស៊ើបសួរ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ជាអាទិ៍ ការពិនិត្យសម្ភារៈ ការឆែកឆេរ និងការចាប់យកវត្ថុតាង[111]។

ចំពោះ នីតិវិធី នៃការឆែកឆេរ ចៅក្រមស៊ើបសួរត្រូវឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទីកន្លែងទេ ត្រូវធ្វើនៅចំពោះមុខសាក្សី ២ នាក់ ដែលខ្លួនចាត់តាំង។ សាក្សីមិនអាចជានគរបាល ឬជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ។

ចៅក្រមស៊ើបសួរ មិនអាចផ្តើមឆែកឆេរមុនម៉ោង ៦ ព្រឹក និងក្រោយម៉ោង ១៨ ល្ងាចបានទេ លើកលែងតែមានករណីដូចខាងក្រោម៖

-ក្នុងករណីឆែកឆេរនៅទីកន្លែងដែលបើកចំហរដល់សាធារណៈជន

-ក្នុងករណី ដែលឆែកឆេរនៅគ្រប់ទីកន្លែង ផលិត រក្សាទុក ជួញដូរ ចែកចាយប្រើប្រាស់គ្រឿងញៀន។

ការឆែកឆេរ នៅក្នុងការិយាល័យមេធាវី ចៅក្រមស៊ើបសួរអាចធ្វើការឆែកឆេរនៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី។ ចៅក្រមស៊ើបសួរ ត្រូវធ្វើកំណត់ហេតុស្តីពីការឆែកឆេរដោយមានចុះហត្ថលេខារបស់ខ្លួន និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សី ២ នាក់។

កំណត់ហេតុ ត្រូវចុះនិទ្ទេសអំពីអត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ។ កាលបើការឆែកឆេរប្រព្រឹត្តទៅនៅក្នុងការិយាល័យមេធាវី កំណត់ហេតុត្រូវចុះនិទ្ទេសអំពីវត្តមានរបស់ប្រធានគណៈមេធាវី ឬរបស់ប្រតិភូ នៃប្រធានគណៈមេធាវីនេះ[112]។

#### ៣.២.៥.១. ការបិទស្លាកបោះត្រាលើវត្ថុតាង

ចៅក្រមស៊ើបសួរអាចចាប់យកវត្ថុតាងបាន។ ចៅក្រមស៊ើបសួរ ត្រូវតែបិទស្លាកបោះត្រាលើវត្ថុតាង។ ក្រោយពីបានបង្ហាញវត្ថុ ដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីទាំងពីរនាក់រួចមក ចៅក្រមស៊ើបសួរធ្វើកំណត់ហេតុស្តីពីការចាប់ ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក។ កំណត់ហេតុស្តីពីការចាប់យកនេះ ត្រូវមានចុះហត្ថលេខារបស់ចៅក្រមស៊ើបសួរ និងក្រឡាបញ្ជី រួមជាមួយអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់ ហើយកំណត់ហេតុនេះ ត្រូវចុះនិទ្ទេសអំពីអត្តសញ្ញាណ នៃអ្នកកាន់កាប់ទីកន្លែង ឬសាក្សីនីមួយៗ[113]។

---

[111]- មាត្រា១៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[112]- មាត្រា១៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[113]- មាត្រា១៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៣.២.៥.២. ការប្រគល់វត្ថុ ដែលចាប់យកឱ្យម្ចាស់ដើមវិញ

នៅពេលដែលមិនទាន់ចេញដីកាដំណោះស្រាយរឿងនៅឡើយទេ ចៅក្រមស៊ើបសួរមានសមត្ថកិច្ចប្រគល់សងទៅម្ចាស់ដើមវិញនូវវត្ថុដែលចាប់បាន កាលណា កម្មសិទ្ធិនេះគ្មានការជំទាស់អ្វីប្រាកដប្រជាទេ។ ចៅក្រមស៊ើបសួរសម្រេចតាមដីកា ដែលមានសំអាងហេតុ ក្រោយពីបានទទួលមតិពីព្រះរាជអាជ្ញា។ ដីកាសម្រេច ត្រូវឱ្យដំណឹងជាបន្ទាន់ដល់អ្នកប្តឹង និងមេធាវីនៃអ្នកប្តឹងប្រសិនបើមាន។ ប្រសិនបើ វត្ថុដែលចាប់បាន ជាវត្ថុដែលអាចបង្កជាឧបសគ្គដល់ការសំដែងឱ្យឃើញការពិត មិនអាចត្រូវបានប្រគល់ឱ្យអ្នកប្តឹងសុំវិញទេ។ មួយវិញទៀត វត្ថុដែលមានគ្រោះថ្នាក់ដល់បុគ្គល ឬទ្រព្យសម្បត្តិ ដូចជាអាវុធ ឬជាតិផ្ទុះ ព្រមទាំងវត្ថុ ដែលការកាន់កាប់មិនស្របច្បាប់ មិនអាចត្រូវបានប្រគល់សងទៅឱ្យសាមីខ្លួនបានទេ។ វត្ថុទាំងនេះត្រូវរឹមអូសជាកម្មសិទ្ធិរបស់រដ្ឋ[114]។

### ៣.២.៦. កោសលវិច័យ

កោសលវិច័យ គឺជាការពិនិត្យធ្វើឡើងដោយអ្នកជំនាញចាត់តាំងដោយចៅក្រមស៊ើបសួរ ដែលសុំយោបល់បំភ្លឺលើបញ្ហាបច្ចេកទេសសុទ្ធសាធ លើវិស័យផ្សេងៗដូចជា វេជ្ជសាស្ត្រ ពេទ្យវិជ្ជា ពន្ធុវិជ្ជា ជីវសាស្ត្រ ចិត្តសាស្ត្រ អង្គុលីលេខ ពត៌មានវិទ្យា។

នៅក្នុងករណី ដែលមានបញ្ហាបច្ចេកទេសចោទឡើង ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យធ្វើកោសលវិច័យដោយឯកឯង ឬតាមពាក្យសុំរបស់ព្រះរាជអាជ្ញារបស់ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ផ្ទុយទៅវិញ កាលណា ចៅក្រមស៊ើបសួរបដិសេធមិនព្រមធ្វើតាមពាក្យសុំធ្វើកោសលវិច័យទេ ចៅក្រមស៊ើបសួរ ត្រូវសម្រេចតាមដីកាដោយមានសំអាងហេតុ។ ដីកាត្រូវសម្រេចក្នុងរយៈពេល ៥ ថ្ងៃ ប្រសិនបើ ពាក្យសុំនោះចេញមកពីព្រះរាជអាជ្ញា និង ១ ខែ ប្រសិនបើពាក្យសុំនោះចេញពីជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណី។ ដីកាសម្រេចនេះ ត្រូវជូនដំណឹងឱ្យដល់អ្នកប្តឹងសុំជាបន្ទាន់[115]។

អ្នកជំនាញ ត្រូវបានជ្រើសរើសក្នុងបញ្ជីអ្នកជំនាញជាតិ ដែលរៀបចំឡើងដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ បែបបទ នៃការចុះឈ្មោះ ឬលុបឈ្មោះចេញពីបញ្ជីត្រូវកំណត់ដោយប្រកាស។ អ្នកជំនាញ ដែលត្រូវបានចុះឈ្មោះនៅក្នុងបញ្ជីថ្នាក់ជាតិ ត្រូវស្បថនៅមុខសាលាឧទ្ធរណ៍ភ្នំពេញស្របតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងផ្តល់ជំនួយដោយស្មោះត្រង់ ដល់ការស្វែងរកយុត្តិធម៌។ អ្នកជំនាញ ដែលត្រូវបានចុះឈ្មោះក្នុងបញ្ជីមិនចាំបាច់ស្បថសាជាថ្មីទៀតទេ នៅពេលណាខ្លួនត្រូវបានគេចាត់តាំងឱ្យធ្វើកោសលវិច័យ[116]។

---

[114]- មាត្រា១៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[115]- មាត្រា១៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[116]- មាត្រា១៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

ចៅក្រមស៊ើបសួរ ត្រូវចាត់តាំងអ្នកជំនាញតាមរយៈដីកាសម្រេចរបស់ខ្លួន ដោយដីកានេះត្រូវមានបញ្ជាក់នូវបេសកកម្មនោះ ហើយបេសកកម្មនោះដែរ អាចទាក់ទងទៅនឹងបញ្ហា ដែលមានលក្ខណៈបច្ចេកទេសតែប៉ុណ្ណោះ។ ក្នុងករណី ចៅក្រមស៊ើបសួរយល់ថាជាការគួរ ចៅក្រមស៊ើបសួរប្រគល់នូវវត្ថុ ដែលខ្លួនចាប់បានមួយផ្នែក ឬទាំងអស់នោះជូនទៅអ្នកជំនាញ។ ចៅក្រមស៊ើបសួរត្រូវធ្វើកំណត់ហេតុស្ដីពីការចាប់យកវត្ថុតាង ដែលចាប់បាននោះ ហើយអ្នកជំនាញមានសិទ្ធិអាចបំបែកស្លាក ដែលបិទដើម្បីធ្វើកោសលវិច័យបាន។ ប្រសិនបើ ធ្វើកោសលវិច័យអាចឱ្យមានការខូចខាត ឬវិនាសដល់វត្ថុ ដែលចាប់យកនោះ អ្នកជំនាញត្រូវជូនពត៌មាននេះដល់ចៅក្រមស៊ើបសួរ និងសុំការអនុញ្ញាតពីចៅក្រមស៊ើបសួរមុននឹងចាប់ផ្ដើមប្រតិបត្តិការរបស់ខ្លួន[117]។

### ៣.២.៧. ការស្ដាប់ទូរស័ព្ទ

ដើម្បីសម្ដែងឱ្យឃើញនូវការពិត ចៅក្រមស៊ើបសួរអាចបង្គាប់ឱ្យស្ដាប់ និងថតការសន្ទនាតាមទូរស័ព្ទបាន។ ម៉្យាងទៀត ចៅក្រមស៊ើបសួរក៏អាចបង្គាប់ឱ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នាតាមមធ្យោបាយទូរគមនាគមន៍ផងដែរដូចជា សារតាមទូរសារ ឬសារតាមអិនធើណែត។ ចៅក្រមស៊ើបសួរអាចសុំឱ្យគ្រប់អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការជំនាញ តាំងឧបករណ៍បច្ចេកទេស និងធ្វើការថត។ ចៅក្រមស៊ើបសួរបញ្ជាក់នៅក្នុងដីកាសម្រេចរបស់ខ្លួនអំពីប្រភេទ នៃទំនាក់ទំនងដែលត្រូវចាប់ ព្រមទាំងអំពីរយៈពេល នៃបេសកកម្ម។

អង្គភាពសាធារណៈ មន្ត្រីរាជការ ដែលចាត់តាំងត្រូវបំពេញតាមពាក្យសុំរបស់ចៅក្រមស៊ើបសួរ។ នៅក្នុងពេលអនុវត្តបេសកកម្ម អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការ ដែលចាត់តាំងត្រូវជូនពត៌មានដល់ចៅក្រមស៊ើបសួរអំពីការប្រព្រឹត្តទៅ នៃបេសកកម្ម ជាអាទិ៍ អំពីការលំបាកជាយថាហេតុ។ កាលណា បេសកកម្មត្រូវបានបំពេញរួចហើយ អង្គភាពសាធារណៈ ឬគ្រប់មន្ត្រីរាជការនោះត្រូវចម្លងជាលាយលក្ខណ៍អក្សរនូវសម្លេង ដែលថតបាន។ ការធ្វើឱ្យទៅជាលាយលក្ខណ៍អក្សរនេះត្រូវឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនូវខ្លឹមសារ នៃសម្លេង ដែលថតបាន។ សម្លេងដែលថតបាននេះត្រូវប្រគល់ជូនចៅក្រមស៊ើបសួរ និងបិទស្លាក។

គ្រប់ពេលវេលា ចៅក្រមស៊ើបសួរអាចចុះទៅកាន់ទីកន្លែងដែលធ្វើការចាប់ និងថតនោះ។ ការចូលទៅក្នុងទីកន្លែងទាំងនោះ មិនអាចត្រូវបានហាមឃាត់ដល់ចៅក្រមស៊ើបសួរដោយសំអាងលើមូលហេតុអ្វីបានទេ ទោះបីជាទីកន្លែងយោធាក៏ដោយ។ ចៅក្រមស៊ើបសួរ ក៏អាចធ្វើកិច្ចការនេះតាមដីកាចាត់ឱ្យស៊ើបសួរជំនួសបានដែរ[118]។

[117]- សៀវភៅនីតិវិធីព្រហ្មទណ្ឌរបស់អនុបណ្ឌិត អៀង សំណាង បោះពុម្ពឆ្នាំ២០១៥ ទំព័រ១០៥

[118]- មាត្រា១៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៣.២.៨. ដីកាចាត់ឱ្យស៊ើបសួរជំនួស

តាមរយៈដីកាចាត់ឱ្យស៊ើបសួរជំនួស ចៅក្រមស៊ើបសួរ អាចផ្ទេរអំណាចស៊ើបសួររបស់ខ្លួនទៅឱ្យចៅក្រមស៊ើបសួរផ្សេងទៀត ឬមន្ត្រីនគរបាលយុត្តិធម៌បាន ដើម្បីបំពេញកិច្ចស៊ើបសួរ។

ដីកាចាត់ឱ្យស៊ើបសួរជំនួសបញ្ជាក់អំពីប្រភេទ នៃកិច្ចដែលត្រូវធ្វើ។ កិច្ចនោះត្រូវតែមានទំនាក់ទំនងដោយផ្ទាល់ជាមួយបទល្មើស ដែលចោទប្រកាន់។ ដីកាចាត់ឱ្យស៊ើបសួរជំនួសមិនអាចមានលក្ខណៈជាទូទៅបានទេ ត្រូវណែនាំឱ្យបានច្បាស់លាស់។

ចៅក្រមស៊ើបសួរកំណត់ថិរវេលា ដែលត្រូវអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។ ដីកាចាត់ឱ្យស៊ើបសួរជំនួស ត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខា ដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង។ ចៅក្រមស៊ើបសួរ អាចដកហូតដីកាចាត់ឱ្យស៊ើបសួរជំនួសបានគ្រប់ពេលវេលា[119]។

#### ៣.២.៨.១. ដីកាចាត់ឱ្យស៊ើបសួរជំនួសទៅឱ្យចៅក្រមស៊ើបសួរម្នាក់ទៀត

កាលណា ដីកាចាត់ឱ្យស៊ើបសួរជំនួសត្រូវបានចេញឱ្យដល់ចៅក្រមណាម្នាក់ ចៅក្រមរូបនោះប្រើប្រាស់អំណាចទាំងអស់របស់ចៅក្រមស៊ើបសួរ[120]។

#### ៣.២.៨.២. ដីកាចាត់ឱ្យស៊ើបសួរជំនួសទៅមន្ត្រីនគរបាលយុត្តិធម៌

នៅពេលដែលមន្ត្រីនគរបាលយុត្តិធម៌អនុវត្តនូវដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ ហើយត្រូវរាយការណ៍ជូនចៅក្រមស៊ើបសួរតែប៉ុណ្ណោះ[121]។ ក្នុងការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ត្រូវបំពេញកិច្ចដែលមានចែងក្នុងដីកាចាត់ឱ្យស៊ើបសួរជំនួសនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន លើកលែងតែមានការពន្លាតសមត្ថកិច្ចដែនដី ដែលគោលការណ៍នេះមានបញ្ញត្តិនៅក្នុងមាត្រា ៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយផ្អែកទៅលើស្ថានភាពចាំបាច់ ព្រមទាំងមាននូវការអនុញ្ញាតពីចៅក្រមស៊ើបសួរដែលជាអ្នកចេញដីកា[122]។

មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្ដីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន នៅពេលអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស[123]។

ចៅក្រមស៊ើបសួរ អាចផ្ទេរអំណាចឱ្យស៊ើបសួរទៅមន្ត្រីនគរបាលយុត្តិធម៌បានក៏ពិតមែន ប៉ុន្តែមិនអាចផ្ទេរអំណាចទាំងអស់របស់ខ្លួនបានទេ។ អំណាចដែលមិនអាចផ្ទេរទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌នោះ គឺអំណាចសួរចម្លើយជនត្រូវចោទឬស្តាប់ចម្លើយដើមបណ្ដឹងរដ្ឋប្បវេណី [124]។

---

[119]- មាត្រា១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[120]- មាត្រា១៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[121]- មាត្រា១៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[122]- មាត្រា១៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[123]- មាត្រា១៧៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

អំណាច ដែលអាចផ្ទេរទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌មានដូចខាងក្រោម៖

-កោះហៅ និងស្តាប់ចម្លើយសាក្សី បើក្នុងពេលស្តាប់មានលេចចេញ នូវតម្រុយពិរុទ្ធភាពប្រឆាំងនឹងសាក្សី ការស្តាប់ចម្លើយត្រូវបញ្ចប់ ដើម្បីឱ្យមន្ត្រីនគរបាលយុត្តិធម៌ផ្តល់ដំណឹងភ្លាមទៅចៅក្រមស៊ើបសួរ[125]។

-ឆែកឆេរ និងចាប់យកវត្ថុតាង នៅក្នុងលក្ខខណ្ឌ ដែលមានចែងនៅក្នុងមាត្រា ៩១ (ការឆែកឆេរ) និងមាត្រា៩២(ការបិទស្លាកបោះត្រាលើវត្ថុតាង) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧[126]។

-ឃាត់ខ្លួន ចំពោះបទបញ្ញត្តិ នៃមាត្រា ៩៦ (ការឃាត់ខ្លួន) ដល់មាត្រា១០២ (ការបញ្ជូនខ្លួនបុគ្គល ដែលត្រូវបានឃាត់ខ្លួន) ស្តីពីការឃាត់ខ្លួនត្រូវយកមកអនុវត្តនៅក្នុងក្របខ័ណ្ឌនៃការអនុវត្តដីកាចាត់ឱ្យស៊ើបសួរជំនួស។ ប៉ុន្តែ អំណាច ដែលប្រគល់ដោយមាត្រាទាំងនេះដល់ព្រះរាជអាជ្ញាត្រូវបានប្រើប្រាស់ដោយចៅក្រមស៊ើបសួរ។ សម្រាប់ការអនុវត្តនូវ មាត្រា ១០៣ (ការបញ្ជូនខ្លួន ឬបុគ្គលដែលត្រូវបានឃាត់ខ្លួន) និងមាត្រា ១០៤ (រយៈពេល នៃការបញ្ជូនខ្លួន) នៃក្រមនីតិវិធីព្រហ្មទណ្ឌនៅពេលផុតកំណត់ នៃការឃាត់ខ្លួនជន ដែលត្រូវបានឃាត់ខ្លួនត្រូវតែនាំទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ[127]។

-ស្តាប់ និងថតសម្លេងតាមទូរស័ព្ទ កាលណា ដីកាចាត់ឱ្យស៊ើបសួរជំនួសបានចែងអំពីការស្តាប់ និងការថត ការសន្ទនាតាមទូរស័ព្ទ ឬការចាប់ និងការថតគ្រប់ការឆ្លើយឆ្លងតាមមធ្យោបាយ ទូរគមនាគមន៍ ដូចជាសារតាមទូរសារ ឬសារតាមអិនធឺណែត មន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់អំណាច ដែលប្រគល់ឱ្យចៅក្រមស៊ើបសួរ ដោយវាក្យខណ្ឌទី២ កថាខណ្ឌទី១ និងកថាខណ្ឌទី២នៃ មាត្រា១៧២ (ការស្តាប់ទូរស័ព្ទ ជាអាទិ៍ ដែលបង្គាប់ដោយចៅក្រមស៊ើបសួរ) នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧[128]។

### ៣.៣. ការបិទការស៊ើបសួរ

យោងតាមស្មារតី នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ការបិទការស៊ើបសួរអាចត្រូវបានបិទតាមរយៈវិធីពីរយ៉ាងគឺ៖

- ដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា
- ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ។

---

124- មាត្រា១៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

125- មាត្រា១៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

126- មាត្រា១៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

127- មាត្រា១៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

128- មាត្រា១៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៣.៣.១. ការបិទការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានស្ថាពររបស់ព្រះរាជអាជ្ញា

កាលណា ចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួរបានបញ្ចប់ ចៅក្រមស៊ើបសួរត្រូវជូនពត៌មាននេះដល់ព្រះរាជអាជ្ញាឱ្យបានជ្រាប ព្រមទាំងជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងមេធាវីបានដឹងលឺផងដែរ។ ពីរថ្ងៃក្រោយមក ចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងទៅឱ្យព្រះរាជអាជ្ញាពិនិត្យ ប្រសិនបើ ព្រះរាជអាជ្ញាយល់ឃើញថាចាំបាច់ត្រូវធ្វើកិច្ចស៊ើបសួរជាថ្មីទៀតនោះ ព្រះរាជអាជ្ញាមានសិទ្ធិស្នើសុំឱ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយ ដែលខ្លួនយល់ថាមានប្រយោជន៍ នៅគ្រប់ពេលវេលា នៃកិច្ចស៊ើបសួរ។ ក្នុងករណីនេះ ព្រះរាជអាជ្ញាមានរយៈពេល ១៥ ថ្ងៃ ប្រសិនបើជនត្រូវចោទត្រូវឃុំខ្លួន និង១ខែ ប្រសិនបើ ជនត្រូវចោទនៅក្រៅឃុំ ដើម្បីបង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ ដោយមានដីកាសន្និដ្ឋានស្ថាពរភ្ជាប់ជាមួយផង។ ចិរវេលានេះ គិតចាប់ពីថ្ងៃដែលព្រះរាជអាជ្ញាបាទទួលសំណុំរឿង។

ប្រសិនបើ ព្រះរាជអាជ្ញាយល់ឃើញដូចចៅក្រមស៊ើបសួរដែរថា ការស៊ើបសួរត្រូវបញ្ចប់នោះ ព្រះរាជអាជ្ញាធ្វើដីកាសន្និដ្ឋានស្ថាពរជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ព្រះរាជអាជ្ញាអាចប្តឹងសុំចៅក្រមស៊ើបសួរសម្រេចបញ្ជូនខ្លួនជនត្រូវចោទទៅកាន់តុលាការជំនុំជម្រះ ឬលើកលែងការចោទប្រកាន់[129]។

### ៣.៣.២. ការបិទការស៊ើបសួរតាមរយៈដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ

កាលណា ចៅក្រមស៊ើបសួរយល់ឃើញថាការស៊ើបសួរត្រូវបញ្ចប់នោះ ចៅក្រមស៊ើបសួរបិទការស៊ើបសួរតាមរយៈដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយនេះអាចជាដីកាបញ្ជូនរឿងទៅជំនុំជម្រះ ឬក៏ដីកាលើកលែងចោទប្រកាន់។

#### ៣.៣.២.១. ដីកាសម្រេចលើកលែងការចោទប្រកាន់

ចៅក្រមស៊ើបសួរអាចសម្រេចចេញដីកាលើកលែងការចោទប្រកាន់បាន នៅក្នុងករណីដូចខាងក្រោម៖

-អំពើប្រព្រឹត្ត មិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ

-ជនដែលប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់

-គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ[130]។

[129]- មាត្រា២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[130]- មាត្រា២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

### ៣.៣.២.២. ដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

ប្រសិនបើ យល់ឃើញថាអំពើនោះជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ចៅក្រមស៊ើបសួរ សម្រេចបញ្ជូនជនត្រូវចោទទៅមុខតុលាការជំនុំជម្រះ។ ដីកាសម្រេចនេះ ត្រូវរៀបរាប់ពីអំពើ ដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់កំណត់។

ដីកាបញ្ជូនទៅជំនុំជម្រះ ក៏ដូចជាដីកាលើកលែងចោទប្រកាន់ដែរ ដោយដកសមត្ថកិច្ចចៅក្រមស៊ើបសួរទៅឱ្យតុលាការ ដែលសំណុំរឿងត្រូវបានបញ្ជូនទៅចៅក្រមជំនុំជម្រះ ដើម្បីជំនុំជម្រះ។ ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះពុំមានថែងពីចិរវេលា ដើម្បីបើកសវនការទេ។ ដីកានេះបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ និងការឃុំខ្លួនជាបណ្ដោះអាសន្ន។ ប៉ុន្តែ យោងតាមសេចក្ដីសម្រេចដោយឡែក នៃដីកាដំណោះស្រាយ និងក្រោមលក្ខខណ្ឌមួយចំនួន ចៅក្រមស៊ើបសួរអាចសម្រេចរក្សាជនត្រូវចោទ ឱ្យនៅជាប់ឃុំរហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខចៅក្រមជំនុំជម្រះ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរត្រូវមានសំអាងហេតុ ទៅលើសេចក្ដីសម្រេចរក្សាទុកជនត្រូវចោទឱ្យនៅក្នុងឃុំ ដោយមូលហេតុណាមួយក្នុងចំណោមមូលហេតុទាំងអស់ ដូចជា ដើម្បីបញ្ចប់បទល្មើស ឬដើម្បីបង្ការកុំឱ្យបទល្មើសកើតជាថ្មី រារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬរារាំងកុំឱ្យមានការត្រូវរូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត ដើម្បីរក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី និងដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ ជាពិសេសដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈ កុំឱ្យមានភាពច្របូកច្របល់ដែលបណ្ដាលមកពីបទល្មើស[131]។

សេចក្ដីសម្រេចរក្សាជនត្រូវចោទក្នុងឃុំបណ្ដោះអាសន្ន លែងមានអានុភាពក្នុងរយៈពេល ៤ ខែ ប្រសិនបើ ជនត្រូវចោទមិនត្រូវបាននាំចូលទៅបង្ហាញខ្លួនចំពោះមុខចៅក្រមជំនុំជម្រះ ក្នុងរយៈពេល ៤ ខែ នោះទេ ជនត្រូវចោទត្រូវបានដោះលែងឱ្យនៅក្រៅឃុំដោយឯកឯង[132]។

កាលណា ចៅក្រមស៊ើបសួរ សម្រេចចេញដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ចៅក្រមស៊ើបសួរត្រូវបញ្ជូនសំណុំរឿងជាបន្ទាន់ទៅប្រធានតុលាការ ដើម្បីកំណត់ពេលវេលាសវនាការជំនុំជម្រះ[133]។

---

[131]- មាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[132]- មាត្រា១៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

[133]- មាត្រា២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

# សេចក្តីសន្និដ្ឋាន

ក្រោយពីបានបញ្ចប់ការសិក្សាទៅលើច្បាប់ ដែលចូលជាធរមានក៏ដូចជាច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលបានតាក់តែងឡើងដោយមានការអនុម័តពីអង្គការនីតិបញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជារួចមក បានឱ្យនាងខ្ញុំយល់ដឹងអំពីសមត្ថកិច្ច សិទ្ធិ អំណាច និងតួនាទី របស់នគរបាលយុត្តិធម៌ អង្គការអយ្យការ និងចៅក្រមស៊ើបសួរក្នុងការអនុវត្តមុខងាររបស់ខ្លួន។

ចំណេះដឹងទាំងអស់នេះបានតម្រូវឱ្យនាងខ្ញុំចងក្រងជាសារណាមួយក្រោមប្រធានបទស្តីពី **"នីតិវិធីស៊ើបអង្កេត បទល្មើសព្រហ្មទណ្ឌ"** ដើម្បីបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ។

តាមរយៈសារណានេះ បានបង្ហាញយ៉ាងច្បាស់អំពីទំនាក់ទំនងកិច្ចការងារ រវាងនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរ ដែលមានភាពប្រទាក់ក្រឡាជាប់ឥតដាច់ក្នុងការស៊ើបអង្កេតស្វែងរកការពិតនៃរឿង។ យ៉ាងណាមិញ ការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ គឺមានគោលបំណងធ្វើឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាជនទូទៅ។ ហេតុដូចនេះទាមទារឱ្យមន្ត្រី ដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតទាំងអស់ ត្រូវតែបំពេញមុខងាររបស់ខ្លួនឱ្យបានត្រឹមត្រូវ និងគោរពទៅតាមបទបញ្ញត្តិ ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។ ចាប់តាំងពីដំណាក់កាលដំបូង នៃការស៊ើបអង្កេតស្វែងរកបទល្មើស ដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌នោះ មន្ត្រីនគរបាលយុត្តិធម៌ អាចបើកការស៊ើបអង្កេតស្វែងរកភស្តុតាង ដើម្បីឱ្យការពិតលេចចេញមក ដោយធ្វើការសាកសួរទៅជនជាប់សង្ស័យក៏ដូចជាជន ដែលជាប់ពាក់ព័ន្ធ និងធ្វើកំណត់ហេតុ ដើម្បីកសាងសំណុំរឿងបញ្ជូនទៅព្រះរាជអាជ្ញា។ នៅក្នុងដំណាក់កាលនេះ មន្ត្រីនគរបាលយុត្តិធម៌ គឺជាតួអង្គសំខាន់ ដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត ហេតុនេះហើយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែធ្វើការស្វែងយល់អំពីតួនាទី និងសិទ្ធិអំណាចរបស់ខ្លួនឱ្យបានច្បាស់ ដើម្បីបង្កាកុំឱ្យមានកំហុស ដែលកើតមានឡើងដោយប្រការណាមួយនៅក្នុងការស៊ើបអង្កេត ដែលជាហេតុធ្វើឱ្យនីតិវិធី នៃការស៊ើបអង្កេត មានភាពមិនប្រក្រតី។ ចំណែកឯ ដំណាក់កាលបន្តពីការស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺជាដំណាក់កាលធ្វើចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌ។ បន្ទាប់ពី មន្ត្រីនគរបាលយុត្តិធម៌ បានធ្វើកំណត់ហេតុកសាងសំណុំរឿងរួចមក មន្ត្រីនគរបាលយុត្តិធម៌ធ្វើការបញ្ជូនសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីធ្វើចំណាត់ការ ព្រមទាំង នាំខ្លួនជនជាប់សង្ស័យឱ្យទៅបង្ហាញខ្លួននៅចំពោះមុខព្រះរាជអាជ្ញាផងដែរ។ ព្រះរាជអាជ្ញាធ្វើចំណាត់ការទៅលើសំណុំរឿង ដោយតម្កល់រឿងទុកឥតចាត់ការ ឬសម្រេចធ្វើការចោទប្រកាន់ទៅលើជនល្មើស ដោយផ្អែកលើមូលដ្ឋានច្បាប់។ ដើម្បីឱ្យចំណាត់ការទទួលបាននូវភាពត្រឹមត្រូវ ព្រះរាជអាជ្ញាត្រូវធ្វើការសាកសួរទៅលើជនសង្ស័យ និងបុគ្គល ដែលជាប់ពាក់ព័ន្ធ

ដើម្បីឱ្យដឹងការពិតនៃរឿង ថាបុគ្គលណាបានប្រព្រឹត្តបទល្មើស បុគ្គលណា ដែលមិនបានប្រព្រឹត្ត បទល្មើស និងបុគ្គលណា ដែលចូលរួមប្រព្រឹត្តបទល្មើស។ បន្ទាប់មកទៀត ត្រូវធ្វើការពិនិត្យមើលទៅលើធាតុផ្សំ នៃបទល្មើស រួមមាន ធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត ដើម្បីធ្វើការថ្លឹងថ្លែង មុននឹងសម្រេចធ្វើការ ចោទប្រកាន់ ឬតម្កល់រឿងទុកឥតចាត់ការ។ ហេតុនេះ គឺទាមទារឱ្យព្រះរាជអាជ្ញាត្រូវតែធ្វើការស៊ើបអង្កេតឱ្យបានម៉ត់ចត់បំផុតមុននឹងធ្វើចំណាត់ការ ដើម្បីឱ្យចំណាត់ការប្រកបដោយភាពត្រឹមត្រូវ និងយុត្តិធម៌ ព្រោះថាព្រះរាជអាជ្ញា គឺជាតួអង្គតំណាងឱ្យសង្គម ជាអ្នកធានាឱ្យបាននូវសណ្តាប់ធ្នាប់សាធារណៈ ដូចនេះ ព្រះរាជអាជ្ញាត្រូវតែគោរពទៅតាមតួនាទីរបស់ខ្លួន ដែលកំណត់ដោយច្បាប់ ដើម្បីបង្ការ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌនៅក្នុងសង្គម។ ក្នុងករណី បទមជ្ឈិម ឬបទលហុតូចតាច ដែលព្រះរាជអាជ្ញាយល់ឃើញថា សំណុំរឿងមានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបាន ព្រះរាជអាជ្ញា ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តែម្តង។ ប៉ុន្តែ កាលណាសំណុំរឿងដែលមានភាពស៊ាំញ៉ាំ មិនទាន់ច្បាស់លាស់ ព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ទៅចៅក្រមស៊ើបសួរ។ ដូចនេះ ការស៊ើបអង្កេតត្រូវឆ្លងកាត់ដំណាក់កាលមួយទៀត គឺដំណាក់កាល នៃការស៊ើបសួរ ដែលធ្វើឡើងដោយចៅក្រមស៊ើបសួរ។ ចៅក្រមស៊ើបសួរត្រូវមានអព្យាក្រឹត្យក្នុងការស៊ើបសួរប្រមូលភស្តុតាង ទាំងដាក់បន្ទុក និងដោះបន្ទុក ដើម្បីធានាឱ្យមានតុល្យភាពរវាងការបង្ក្រាប និងការគោរពសិទ្ធិជនត្រូវចោទ ព្រមទាំងលើកស្ទួយសិទ្ធិជនរងគ្រោះស្របតាមរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងស្របតាមគោលការណ៍ឯករាជ្យរបស់តុលាការ នៃកតិកាសញ្ញាជាសកលស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ របស់អង្គការសហប្រជាជាតិ ឆ្នាំ១៩៦៦ និងសេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ១៩៤៨ ដែលរដ្ឋធម្មនុញ្ញបានទទួលស្គាល់ផងដែរ ដើម្បីចូលរួមចំណែកពង្រឹងប្រព័ន្ធយុត្តិធម៌នៅកម្ពុជាឱ្យកាន់តែប្រសើរឡើង។

សរុបមក នៅក្នុងនីតិវិធី នៃការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ពិតជាមានសារសំខាន់ខ្លាំងណាស់ ព្រោះវា គឺជានីតិវិធី ដែលធ្វើឡើង ដើម្បីស្វែងរកការពិតនៃរឿង មុននឹងបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ។ ការស៊ើបអង្កេតនេះ គឺធ្វើឡើងដោយម៉ត់ចត់ និងត្រឹមត្រូវ ក្នុងគោលបំណងធ្វើឱ្យមានប្រសិទ្ធិខ្ពស់ ដើម្បីស្វែងរកការពិត យុត្តិធម៌ ដោយអាចធានាបាននូវការគោរពសិទ្ធិ និងសេរីភាពរបស់ប្រជាពលរដ្ឋ ស្របតាមបទបញ្ញត្តិ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ នៃព្រះរាជាណាចក្រកម្ពុជា។

# អនុសាសន៍

យោងទៅតាមការសង្កេតឃើញសកម្មភាពអនុវត្ត នីតិវិធីស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌសព្វថ្ងៃនេះ គឺមានភាពល្អប្រសើរច្រើនដោយសារតែមន្ត្រី ដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតភាគច្រើនបានគោរពតាមតួនាទីរបស់ខ្លួនយ៉ាងល្អ និងប្ដេជ្ញាចិត្តធ្វើការបម្រើប្រជាពលរដ្ឋនៅតាមដែនដីរបស់ខ្លួន ដើម្បីធានាដល់ការបង្ការកុំឱ្យមានបទល្មើស និងបង្ក្រាបបទល្មើសផ្សេងៗ ដែលកើតមានក្នុងសង្គម ដោយអនុវត្តទៅតាមក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ នៃព្រះរាជាណាចក្រកម្ពុជា។

ទន្ទឹមនឹងមានភាពល្អប្រសើរ ក្នុងនោះក៏នៅមានភាពខ្វះចន្លោះផងដែរ។

ដូចនេះ ដើម្បីឱ្យការស៊ើបអង្កេតស្វែងរកបទល្មើសទទួលបាននូវភាពល្អប្រសើរ និងប្រកបដោយប្រសិទ្ធិភាពខ្ពស់នោះ រាជរដ្ឋាភិបាលត្រូវតែធ្វើការកែលំអរ និងបំពេញទៅលើចំណុចខ្វះខាតដែលមានដូចតទៅ៖

១. រៀបចំបង្កើតឱ្យមានការបណ្ដុះបណ្ដាលជំនាញ និងវិធីសាស្ត្រល្អៗក្នុងការស៊ើបអង្កេតដល់មន្ត្រី ដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត ដើម្បីឱ្យការស៊ើបអង្កេតទទួលបាននូវប្រសិទ្ធភាព និងច្បាស់លាស់។

២. ផ្ដល់ជាសំភារៈ ឬឧបករណ៍បច្ចេកទេស សម្រាប់ធ្វើកោសលវិច័យដល់មន្ត្រី ដែលមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត សម្រាប់ធ្វើការស្រាវជ្រាវស្វែងរកភស្តុតាង។

<u>ឧទាហរណ៍:</u> ឧបករណ៍សម្រាប់ស្កេនក្រយៅដៃជាដើម។

៣. ផ្ដល់ប្រាក់ឧបត្ថម្ភ ជាកញ្ចប់សម្រាប់បេសកកម្មចុះទៅធ្វើការស្រាវជ្រាវផ្សេងៗ របស់នគរបាល ក៏ដូចជាមន្ត្រីពាក់ព័ន្ធក្នុងការស៊ើបអង្កេត ដើម្បីឱ្យការស៊ើបអង្កេតមានភាពសកម្មក៏ដូចជា ការលើកទឹកដល់មន្ត្រីពាក់ព័ន្ធ ដែលមានស្នាដៃក្នុងការបំពេញមុខងាររបស់ខ្លួនបានល្អ។

៤. តំឡើងប្រាក់បៀវត្សឱ្យមន្ត្រី ដែលមានសមត្ថកិច្ច ក្នុងការស៊ើបអង្កេតឱ្យបានសមរម្យដើម្បីឱ្យការអនុវត្តមុខងារប្រកបដោយទំនួលខុសត្រូវខ្ពស់ និងអនុវត្តការដាក់ពិន័យទៅលើមន្ត្រីណាដែលមិនគោរពតាមតួនាទី និងភារកិច្ចរបស់ខ្លួនក្នុងការស៊ើបអង្កេត ឱ្យបានតឹងរឹង។

ម្យ៉ាងទៀត ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរត្រូវតែធ្វើការស៊ើបសួរដោយផ្ទាល់ ចៀសវាងឱ្យក្រឡាបញ្ជីជាអ្នកស៊ើបសួរជំនួស ជាពិសេសនោះ គឺត្រូវគោរពតួនាទីរបស់ខ្លួនទៅតាមបទបញ្ញត្តិដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

ប្រសិនបើ ចំណុចទាំងអស់ខាងលើនេះត្រូវបានបំពេញពិតជាល្អខ្លាំងណាស់។ នាងខ្ញុំជឿជាក់ថា ការស៊ើបអង្កេតស្វែងរកជនល្មើស ប្រាកដជាទទួលបានលទ្ធផលល្អ ហើយប្រជាពលរដ្ឋច្បាស់ជាទទួលបាន នូវភាពយុត្តិធម៌ ពិសេសជាងនេះទៅទៀតនោះ គឺសង្គមទទួលបាននូវភាពល្អប្រសើរ ដោយគ្មានការរំលោភលើសិទ្ធិគ្នា កាត់បន្ថយអំពើល្មើសនៅក្នុងសង្គម ដែលធ្វើឱ្យសង្គមមានសុវត្ថិភាព សន្តិភាព និងប្រកបទៅដោយភាពរីកចម្រើនជាមិនខាន។